# ព្រះធម្មយានាធិប្បាយ

ជំនួយធម្មវិន័យថ្នាក់ឯក

រៀបរៀងដោយ

**ភិក្ខុ សិរីបញ្ញា ខុក ~ ណែម**

**អរញ្ញិការាម**

**ព.ស. ២៥០៥ គ.ស. ១៩៦២**

អំណោយពីលោក ខៅ ឃុនសិរីយ៉ ដល់ការិយាល័យ
សម្រាប់ដាក់ទុកក្នុង elibrary of Cambodia.

# ព្រះធម្មយានាធិប្បាយ

ជំនួយធម្មវិន័យថ្នាក់ឯក

រៀបរៀងដោយ

ភិក្ខុ សិរីបញ្ញា ឱក - ណែម

អរញ្ញិការាម

ព.ស ២៥០៥ គ.ស ១៩៦២

# មាតិកានុក្រម


| | ទំព័រ | បន្ទាត់ |
|---|---|---|
| អារម្ភកថា . . . . . . . . . | ក | ១ |
| ឧទ្ទិសកថា . . . . . . . . . | ង | ១ |

## ព្រះធម្មយាឈពិប្បាយ

| | ទំព័រ | បន្ទាត់ |
|---|---|---|
| លំនាំដើម . . . . . . . . . | ១ | ៥ |
| អរិយមគ្គស័ត្វ . . . . . . . . . | ២ | ១៣ |
| អរិយមគ្គបុគ្គល . . . . . . . . . | ៥ | ១០ |
| អគ្គបរិឲ្យហ៊ាន . . . . . . . | ១៤ | ១៣ |
| អគ្គរបស់អរិយមគ្គ ៨ . . . . . . . | ១៨ | ៤ |
| អធិប្បាយអគ្គមគ្គទី ១ . . . . . . . | " | ៩ |
| កាយសក្ខិ ៤ . . . . . . . | ១៩ | ១ |
| អធិប្បាយអគ្គមគ្គទី ២ . . . . . . . | ៥៤ | ៣ |
| " អគ្គមគ្គទី ៣ . . . . . . . | ៦៤ | ១ |
| " អគ្គមគ្គទី ៤ . . . . . . . | ៧១ | ១៦ |
| " អគ្គមគ្គទី ៥ . . . . . . . | ៧៧ | ៧ |
| " អគ្គមគ្គទី ៦ . . . . . . . | ៨២ | ១២ |
| សម្មប្បធាន ៤ . . . . . . . | ៨៣ | ១៥ |
| អនុបស្សនា ៧ . . . . . . . | ៨៩ | ២ |
| សមាបត្តិ ៨ . . . . . . . | ៩៤ | ១០ |

# មាតិកានុក្រម


| | ទំព័រ | បន្ទាត់ |
|---|---|---|
| អធិប្បាយអង្គមគ្គទី ៧ . . . . . | ១០៨ | ៤ |
| សតិប្បដ្ឋាន ៤ . . . . . | ១០៧ | ១ |
| បព្វៈ ១១ . . . . . . . | ១០៩ | ១៦ |
| អធិប្បាយអង្គមគ្គទី ៨ . . . . . | ១១៣ | ១៣ |
| សមាធិ ៣ យ៉ាង . . . . . | ១១៤ | ៤ |
| សង្ស័យ ១៦ យ៉ាង . . . | ១៤៤ | ១៨ |
| សោតាបន្នបុគ្គល ៣ ពួក . . | ១៣០ | ១៣ |

# អារម្ភកថា

បុព្វហេតុដែលនាំឲ្យកើតបានជាសៀវភៅព្រះធម្មយាត្រាពិបក្ខយនេះ ឡើង គឺដោយសារលោកគ្រូ ទក-វណ្ណម និង លោកគ្រូសូត្រ ដែលជាអ្នកមានសទ្ធាក្នុងព្រះពុទ្ធសាសនា បានគាំពារយោគព្យាយាមរៀបរៀងឡើង ដើម្បីជាប្រយោជន៍ដល់ពុទ្ធបរិស័ទអ្នកមានបំណងក្នុងការចេញមកពីផ្ទះជាទីធ្វើដំណើរទៅកាន់ព្រះនិព្វាន ជាស្ពានបរមសុខប្រសើរបំផុតនោះឯង ។

យើងអ្នករៀបរៀងមានសេចក្ដីសង្ឃឹមថា កាលបើពុទ្ធបរិស័ទទាំងឡាយរៀនបានតាម ឬប្រតិបត្តិតាមគោលធម៌ដែលយើងបានរៀបរៀងទុកក្នុងសៀវភៅនេះ តាមលំដាប់ត្រូវហើយ ក្រែងដល់ចប់ ក៏មុខជានឹងបានជួបប្រទះ ឬយល់ច្បាស់នូវផ្លូវជាទីធ្វើដំណើរទៅកាន់ព្រះនិព្វាន ដោយបញ្ញាចក្ខុមិនខាន ។ ហេតុនេះ បានជាយើងទំនុកក្នុងការរៀបរៀងសៀវភៅនេះតាំងពីដើមឆ្នាំ ១៩៥៩ រហូតមកដល់ថ្ងៃព្រហស្បតិ៍ ៥ កើត ខែបុស្ស ឆ្នាំជូតទោស័ក ព.ស. ២៥០៤ គ. ស. ១៩៦០ ទើបបានចប់សព្វគ្រប់ ។

ចាប់តាំងពីនោះមក យើងបានប្រគល់ឲ្យចៅហ្វៃ លី-គ្រោច ព្រមទាំងអ្នកស្រី ចៅហ្វៃឡុង-គីមសួន ព្រមទាំងអ្នកស្រី ប៊ីងចៅហ្វៃ ខូច-តង់ ព្រមទាំងអ្នកស្រី ដោយចៅហ្វៃទាំង ៣ រូបនេះ ជាអ្នកមានបសាទសទ្ធា ថ្លា-ថ្លាគឺជួយចេញទុនគាំទ្រក្នុងការបោះពុម្ពផ្សាយ តែដោយនៅមិនទាន់អស់សេចក្ដីសង្ស័យក្នុងការរៀបរៀង ទើបនាំសៀវភៅនេះទៅប្រគេនចំពោះព្រះតេជគុណព្រះធម្មលិខិត ប៊ុង-សែស ជាចៅអធិការ វត្តបហាចគ្រី

ដើម្បីឲ្យលោកជួយពិនិត្យកែតម្រូវតទៅទៀត តែលោកមានធុរៈមិនបាន ពិនិត្យផ្ទាល់ព្រះអង្គឯងទេ លោកបានចាត់ឲ្យព្រះបាលដ្ឋបរិវេណ ឡុង-គីម មីនព្រះមហាបរិយត្តិមន្ទីរសិក្សា ប៉ុន្ន-សាយ (ហៅមាន) ឲ្យជួយផ្ទៀងផ្ទាត់ ។

ព្រះបាល័ដ្ឋបរិវេណ៍ និងព្រះមហាបរិយត្តិមន្ទីរសិក្សាទាំងពីរអង្គនេះ ក៏បានជួយផ្ទៀងផ្ទាត់ដោយយកចិត្តទុកដាក់ អស់រយៈកាល ១ឆ្នាំគត់ទើបចប់ រួចហើយទើបប្រគល់ឲ្យយើងតែទាំង ៣ រូបដែលមាននាមនៅខាងលើនេះ ឲ្យចាត់ការបោះពុម្ពផ្សាយជាថ្មីបាន ចំនួន ១០០០ច្បាប់ នៅថ្ងៃ១៧ ខែកក្កដា ឆ្នាំ១៩៦៤ ។

នៅវេលាឡើងកាត់ពុម្ព លោក អ៊ុច-រស់ ម្ចាស់រោងពុម្ព ពាក បានជួយពិនិត្យកែសម្រួលខ្លះៗក្នុងវិធីសរសេរ តាមពាក្យអញ្ជើញរបស់អ្នកចាត់ការបោះពុម្ព ។

## ឧទ្ទិសគាថា

ដោយគោលបំណងរបស់យើងខ្ញុំអ្នករៀបរៀង ព្រមទាំងលោកអ្នកឧបត្ថម្ភការបោះពុម្ពនេះថា សូមឲ្យសៀវភៅព្រះធម្មយាគាធិប្បាយនេះ គង់នៅប្រព្រឹត្តទៅដល់គ្រប់ ៥០០០ ព្រះវស្សា មួយវិញទៀត យើងខ្ញុំសូមឲ្យបានសម្រេចព្រះនិព្វានក្នុងអនាគតជាតិ ។

ធម្មយាគាធិប្បាយតេជេន សុចិត្តា ហោន្តុ បាណិនោ
តិសុ អត្ថេសុ តិដ្ឋន្តុ សហា សព្វេហិ ញាតិភិ៖

ដោយតេជៈនៃព្រះធម្មយាគាធិប្បាយ (នេះ) សូមឲ្យសត្វទាំងឡាយ បានប្រកបដោយសុចិត្ត សូមឲ្យបានសម្រេចប្រយោជន៍ទាំង ៣ ប្រការគឺ (ប្រយោជន៍ក្នុងមនុស្ស ១, ទេវតា ១, ព្រះនិព្វាន ១) ព្រមទាំងញាតិសាលោហិតទាំងអស់គ្នា កុំបីប្រែក្លាយដោយការៈផ្សេងឡើយ ។

### វគ្គប្រណាម

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្ការ ថ្វាយបង្គំចំពោះព្រះអរហន្តសម្មាសម្ពុទ្ធ មានព្រះភាគអង្គនោះ ដោយសេចក្ដីគោរព ។

---

# ធម្មយាត្រាធិប្បាយ

## លំនាំដើម

នៅកាលមុន ព.ស. ៤៥ ឆ្នាំ មានមហាបុរសមួយព្រះអង្គ ព្រះនាមសមណគោតម ជាអរហន្តសម្មាសម្ពុទ្ធ បានឃើញវិសេសមួយ ដែលបរិបូណ៌ដោយសេចក្ដីសុខ-ចំរើន, ឥតមានភ័យព្រួយលំបាកអំពីការកើត, ចាស់, ឈឺ, ស្លាប់ ទីនោះមានឈ្មោះហៅថា "និព្វាន" ។

ព្រះមហាបុរស បានសង្កេតពិនិត្យមើលនូវទីនោះ ដោយសព្វគ្រប់ ឃើញថាសុខស្រួលឥតមានភ័យព្រួយលំបាកអំពីការកើត, ចាស់, ឈឺ, ស្លាប់ ពិតមែន លុះឃើញដូច្នោះហើយ ក៏ទ្រង់មានព្រះទ័យករុណា អាសូរដល់ពួកសត្វនិករដែលកំពុងវេទនាក្នុងត្រៃលោក ។ ព្រះអង្គក៏ទ្រង់បើកទ្វារព្រះនិព្វាននោះចំហគ្រប់ទិសទាំង ៤ ហើយប្រកាសប្រាប់ដល់ពួកសត្វនិករទាំងឡាយ ឲ្យចូលទៅនៅក្នុងទីនោះជាមួយព្រះអង្គផង ។ មិនគ្រាន់តែប្រកាសប្រាប់ប៉ុណ្ណោះទេ ថែមទាំងបានណែនាំ ព្រមទាំងបង្ហាញប្រាប់ផ្លូវសំរាប់ដើរទៅកាន់ទីនោះទៀត ។

តាំងពីសម័យនោះមកដល់សព្វថ្ងៃនេះ ពុទ្ធសករាជកន្លងទៅបាន ២៥០៣ ឆ្នាំហើយ តែព្រះនិព្វានដែលព្រះមហាបុរសបានលើកតម្កល់ទុក ហើយនោះក្តី ផ្លូវសំរាប់ដើរទៅកាន់ទីនោះក្តី ក៏ស្ថិតនៅគង់វង្សដដែលពុំបាត់បង់ទៅណាឡើយ តាំងពីព្រះមហាបុរសនោះសោរ ក៏ចេះស្ថិតនៅក្នុងទីនោះតែសព្វថ្ងៃ ។

ព្រោះហេតុនោះ យើងទាំងឡាយជាសត្វមានភ័ព្វសំណាង បានកើតមកទាន់សម័យល្អ គួរតែខំដើរតាមផ្លូវដែលព្រះមហាបុរសជាបរមគ្រូរបស់យើងបានសំដែងហើយ ដើម្បីដើរទៅកាន់ព្រះនិព្វាននោះ ដូចជាព្រះអង្គដែរ ។

ផ្លូវដែលព្រះបរមគ្រូរបស់យើង បានសំដែងទុកមកហើយនោះ មានឈ្មោះប្រាកដថា អរិយមគ្គ ឬ អដ្ឋង្គិកមគ្គ ដូចមានសេចក្តីអធិប្បាយតទៅនេះ :

អរិយមគ្គសច្ច ឬ អដ្ឋង្គិកមគ្គសច្ច

ពាក្យថា "អរិយមគ្គ ឬ អដ្ឋង្គិកមគ្គ" នេះ ប្រែថា ផ្លូវដ៏ប្រសើរ ឬ ផ្លូវប្រកបដោយអង្គ ៨ (គឺជាផ្លូវដ៏ត្រង់, ផ្លូវមានបែបបទល្អ, ផ្លូវឥតមានទោស) ។

មគ្គ: ដែលប្រែថាផ្លូវក្នុងទីនេះ សំដៅយកផ្លូវដែលទៅកាន់ព្រះនិព្វាន ។

ម្យ៉ាងទៀត មគ្គសព្ទនេះ ប្រែថា សភាវៈស្វែងរកនូវព្រះនិព្វាន ឬ សភាវៈដែលបុគ្គលអ្នកត្រូវការដោយព្រះនិព្វាន តែងស្វែងរក ឬថាសភាវៈសម្លាប់នូវកិលេសប្រព្រឹត្តទៅ ។

ព្រោះមានបទវិគ្រោះថា : "និព្វានំ មគ្គតិ និព្វានត្ថិកេហិ វា មគ្គិយតីតិ មគ្គោ កិលេសេ វា មារេន្តោ គច្ឆតីតិ មគ្គោ" ដូច្នេះ ។

អរិយមគ្គនេះ មានអង្គ ៨ ប្រការ ព្រះសម្មាសម្ពុទ្ធជាបរមសាស្ដាទ្រង់ត្រាស់ហៅថា អដ្ឋង្គិកមគ្គ ប្រែថា ផ្លូវប្រកបដោយអង្គ ៨ គឺ៖

សម្មាទិដ្ឋិ សេចក្ដីយល់ត្រូវ១, សម្មាសង្កប្បៈ សេចក្ដីត្រិះរិះត្រូវ១, សម្មាវាចា សំដីត្រូវ១, សម្មាកម្មន្តោ ការងារត្រូវ១, សម្មាអាជីវោ ការចិញ្ចឹមជីវិតត្រូវ១, សម្មាវាយាមោ សេចក្ដីព្យាយាមត្រូវ១, សម្មាសតិ សេចក្ដីរលឹកត្រូវ១, សម្មាសមាធិ ការដំកល់ចិត្តត្រូវ១ ។

ពាក្យថា អដ្ឋង្គិកមគ្គនេះ ក្នុងអដ្ឋកថាបដិសម្ភិទាមគ្គប្រាប់ថា បើមិនប្រកបដោយអង្គ ៨ ប្រការគ្រប់គ្រាន់ទេ មិនហៅថា អដ្ឋង្គិកមគ្គដូច្នេះ ពុំបានឡើយ ប្រៀបដូចពាក្យថា ចតុរង្គសេនា សេនាប្រកបដោយអង្គ ៤ គឺ ហត្ថានិកៈ កងទ័ពដំរី១, អស្សានិកៈ កងទ័ពសេះ១, រថានិក. កងទ័ពរថ ឬរទេះ១, បត្តានិកៈ កងទ័ពថ្មើរជើង១ ។ លុះតែប្រកបដោយអង្គទាំង ៤ នេះគ្រប់គ្រាន់ទើបហៅថា ចតុរង្គសេនា ។ ពុំនោះដូចពាក្យថា បញ្ចង្គិកតូរ្យតន្ត្រី តូរ្យតន្ត្រី ដែលប្រកបដោយអង្គ ៥

អាតតំ ស្គរដែលគេពាសស្បែកតែម្ខាង១, វិតតំ ស្គរដែលគេពាសស្បែកទាំងពីរខាង១, អាតតវិតតំ គ្រឿងតន្ត្រីដែលគេដោយខ្សែមានទ្រោកជាដើម១, សុសិរំ គ្រឿងផ្លុំមានស្រឡៃជាដើម១, ឃនំ គណ្តឹងឈឹង ឬ ក្រាប់១, លុះណាតែប្រគំដោយអង្គទាំង ៥ នេះគ្រប់គ្រាន់ទើបហៅថា: បញ្ចង្គិកតូរ្យតន្ត្រី យ៉ាងណាមិញ ឯពាក្យថា អដ្ឋង្គិកមគ្គនេះ ក៏យ៉ាងនោះដែរ ។

ក្នុងធម្មចក្កប្បវត្តនសូត្រ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ហៅ អដ្ឋង្គិកមគ្គនេះថា មជ្ឈិមាបដិបទា ព្រោះជាសេចក្តីប្រតិបត្តិយ៉ាងកណ្តាល មិនតឹងពេកមិនធូរពេក ជាសេចក្តីប្រតិបត្តិដើម្បីប្រព្រឹត្តទៅ, ដើម្បីរម្ងាប់កិលេស, ដើម្បីស្គាល់ច្បាស់នូវអរិយសច្ច, ដើម្បីត្រាស់ដឹង, ដើម្បីព្រះនិព្វាន ។

ក្នុងមហាសីហនាទសូត្រ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅអដ្ឋង្គិកមគ្គនេះថា បុព្វភាគបដិបទា ព្រោះជាសេចក្តីប្រតិបត្តិជាបំណែកខាងដើមនៃព្រះនិព្វាន ។

ក្នុងមហាគោវិន្ទសូត្រ ព្រះជិនស្រីទ្រង់ត្រាស់ហៅ អដ្ឋង្គិកមគ្គនេះថា ព្រហ្មចរិយធម៌ ព្រោះជាធម៌ប្រព្រឹត្តទៅដើម្បីនឿយណាយ, ដើម្បីប្រាសចាករាគៈ, ដើម្បីរលត់កិលេស, ដើម្បីស្ងប់រម្ងាប់, ដើម្បីដឹងច្បាស់, ដើម្បីត្រាស់ដឹង, ដើម្បីព្រះនិព្វានតែម្យ៉ាង ។

ម្យ៉ាងទៀត ក្នុងគម្ពីរសំយុត្តនិកាយ មហាវគ្គ ព្រះសម្មាសម្ពុទ្ធ

ទ្រង់ឲ្យឈ្មោះ អដ្ឋង្គិកមគ្គនេះថា ព្រហ្មយាន ឬ ធម្មយានក៏បាន ថា សង្គ្រាមវិជយយានក៏បាន, ដែលឈ្មោះថាព្រហ្មយាននោះ ព្រោះព្រះអរិយៈទាំងឡាយដែលចង់ធ្វើដំណើរទៅកាន់ទីរលត់ទុក្ខគឺព្រះនិព្វាន តែងទៅអាស្រ័យយានគឺអរិយមគ្គនេះឯង ព្រោះអរិយមគ្គនេះ ជាយានដ៏ប្រសើរ អាចដឹកនាំសត្វឲ្យព្រាសចាកទោសគ្រប់យ៉ាង ។ ដែលឈ្មោះថា ធម្មយាននោះ ព្រោះអរិយមគ្គនេះ ជាយានពោលគឺធម៌សំរាប់ដឹកសត្វទៅដល់ត្រើយ ពោលគឺព្រះនិព្វានជាទីបំផុត ៗ ដែលឈ្មោះថា សង្គ្រាមវិជយយាននោះ ព្រោះអរិយមគ្គនេះ ជាយានធម៌អាចញុំាងសឹកសង្គ្រាម គឺពួកកិលេសឲ្យបរាជ័យទៅបាន ។

*

## អរិយមគ្គុប្បត្តិ

### ការកើតឡើងនៃអរិយមគ្គ ឬ អដ្ឋង្គិកមគ្គ

អរិយមគ្គ ឬ អដ្ឋង្គិកមគ្គនេះដែលនឹងកើតមានឡើងចំពោះតែក្នុងពុទ្ធកាល គឺកាលដែលមានព្រះសម្មាសម្ពុទ្ធទ្រង់ឧប្បត្តិឡើងក្នុងលោក បើវៀរចាកពុទ្ធកាលហើយពុំដែលមានឡើយ ។ ក្នុងពុទ្ធកាលនេះកើតឡើងនាបឋមពោធិកាល គឺកាលដែលព្រះសម្មាសម្ពុទ្ធស្តេចយាងទៅប្រោសបញ្ចវគ្គិយភិក្ខុ នៅឯព្រៃឥសិបតនមិគទាយវ័នទៀបក្រុងពារាណសី ។

តាមរឿងក៏ដែលមានក្នុងគម្ពីរមហាវគ្គថា: សម័យនោះព្រះសម្មាសម្ពុទ្ធជាម្ចាស់ទើបបានត្រាស់ដឹងជាដំបូង ទ្រង់គង់ក្រោមម្លប់ពោធិព្រឹក្ស

ក្បែរស្ទឹងនេរញ្ជរា ក្នុងឧរុវេលប្រទេស ទ្រង់សោយវិមុត្តិសុខអស់ ៧ ថ្ងៃ (១ សប្តាហ៍) ។ លុះសប្តាហ៍ទី ១ កន្លងទៅ ព្រះមានព្រះភាគទ្រង់ក្រោកចាកសមាធិ ហើយទ្រង់ចេញពីម្លប់ពោធិព្រឹក្សយាងចូលទៅគង់ក្រោមម្លប់អជបាលនិគ្រោធព្រឹក្ស សោយវិមុត្តិសុខអស់ ៧ ថ្ងៃ (២ សប្តាហ៍) ។ លុះសប្តាហ៍ទី ២ កន្លងទៅហើយ លំដាប់នោះព្រះមានព្រះភាគទ្រង់ក្រោកចាកសមាធិនោះ ហើយយាងចេញអំពីម្លប់អជបាលនិគ្រោធព្រឹក្ស ចូលទៅគង់ក្រោមម្លប់ដើមកំនៃក្បែរលំនៅនៃមុជ្ជលិន្ទនាគរាជ ទ្រង់សោយវិមុត្តិ-សុខអស់ ៧ ថ្ងៃ (៣ សប្តាហ៍) ។ លុះសប្តាហ៍ទី ៣ កន្លងទៅហើយព្រះមានព្រះភាគទ្រង់ក្រោកចេញចាកសមាធិនោះ ហើយយាងចេញពីម្លប់ដើមកំនុ ចូលទៅគង់ក្រោមម្លប់ដើមកែស ទ្រង់សោយវិមុត្តិសុខអស់ ៧ ថ្ងៃ (៤ សប្តាហ៍) ។ លុះសប្តាហ៍ទី ៤ កន្លងទៅហើយ ព្រះមានព្រះភាគទ្រង់ក្រោកចាកសមាធិនោះ ហើយយាងត្រឡប់ចូលទៅគង់នៅក្រោមម្លប់អជបាលនិគ្រោធវិញ (៥ សប្តាហ៍) ។

លំដាប់នោះ ព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់គង់សម្ងំនៅក្នុងទីស្ងាត់តែព្រះអង្គឯង ទើបទ្រង់មានព្រះតម្រិះយ៉ាងនេះថា ៖ " ធម៌ដែលតថាគត បានត្រាស់ដឹងហើយនេះ គម្ភីរោ ជាធម៌ជ្រាលជ្រៅ, ទុទ្ទសោ ជាធម៌គឺសត្វឃើញបានដោយកម្រ, ទុរនុពោធោ ជាធម៌គឺសត្វដឹងបានដោយក្រ, សន្តោ ជាធម៌រម្ងាប់ទុក្ខ, បណីតោ ជាធម៌ដ៏ឧត្តម,

អតក្កាវចរោ ជាធម៌ដែលសត្វមិនគប្បីស្ទង់ប្រមើលមើលដោយតម្រិះបាន, និបុណោ ជាធម៌ដ៏ល្អិត, បណ្ឌិតវេទនីយោ ជាធម៌ល្មុះតែអ្នកប្រាជ្ញទើបត្រាស់ដឹងបាន; ក៏ឯពួកសត្វទាំងឡាយនេះ សុទ្ធតែនៅក្នុងរីករាយ, ក្នុងត្រេកត្រអាល, ក្នុងស្រើបស្រាលក្នុងសេចក្តីអាល័យចំពោះកាមនៅឡើយ ក៏ធម៌សម្រាប់ស្ងប់បង់នូវសង្ខារទាំងពួង សម្រាប់លះពោលនូវឧបធិ គឺកាមគុណ ៥ ទាំងអស់ ជាទីអស់ទៅនៃតណ្ហា ជាទីណាយចាក កតៈ ជាទីរលត់ទុក្ខ គឺនិព្វាន ធម៌ទាំងអម្បាលនេះ ជាហេតុដែលពួកសត្វឃើញបានដោយកម្រក្រពេក បើទុកជាតថាគតសំដែងទៅក៏គង់សត្វទាំងឡាយ មិនអាចនឹងត្រាស់ដឹងនូវធម៌របស់តថាគតបានឡើយ ព្រោះហេតុនោះ សេចក្តីលំបាកនឹងការនឿយព្រួយមុខជានឹងមានដល់តថាគតជាមិនខានឡើយ" ។

កាលបើព្រះមានព្រះភាគទ្រង់ពិចារណាឃើញដោយហេតុដូច្នេះ ហើយព្រះហឫទ័យក៏បង្អោនទៅដើម្បីសេចក្តីខ្វល់ខ្វាយតិច មិនបង្អោនទៅដើម្បីសំដែងធម៌ឡើយ ។

លំដាប់នោះ សហម្បតិព្រហ្ម ដឹងនូវសេចក្តីត្រិះរិះក្នុងព្រះហឫទ័យរបស់ព្រះមានព្រះភាគដោយចិត្តរបស់ខ្លួនហើយ ទើបពោលដូច្នេះថា: អើហ្ន៎ ព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ មានព្រះទ័យបង្អោនទៅដើម្បីសេចក្តីខ្វល់ខ្វាយតិច មិនបង្អោនទៅដើម្បីសំដែងធម៌យ៉ាងនេះ, ឱហ្ន៎! សត្វ-

លោកវិនាសហើយតើ ។ គ្រានោះ សហម្បតិព្រហ្មក៏បាត់អំពីព្រហ្ម-លោក មកប្រាកដខ្លួនចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ ១ រំពេច ។ សហម្បតិព្រហ្មធ្វើនូវសំពត់ឧត្តរាសង្គៈទៀងស្មាម្ខាង(ពាឆា) ហើយលុតចុះនូវមណ្ឌលជង្គង់ខាងស្តាំលើផែនដី ប្រណម្យអញ្ជលីថ្វាយបង្គំចំពោះព្រះមានព្រះភាគ ទើបពោលពាក្យនេះនឹងព្រះមានព្រះភាគថា : បពិត្រព្រះអង្គដ៏ចំរើន សូមព្រះអង្គសំដែងធម៌ សូមព្រះសុគតសំដែងធម៌ ព្រោះសត្វទាំងឡាយដែលមានធូលីគឺកាមចក្ខុលេសដ៏ស្រាលស្តើង ក៏ការមិនស្តាប់ធម៌ ក៏មុខជានឹងសាបសូន្យមិនខាន សត្វទាំងឡាយអ្នកបំរុងនឹងត្រាស់ដឹងនូវធម៌ ក៏គង់មានដែរ ។

លុះពោលពាក្យនេះហើយ ក៏ពោលពាក្យដទៃទៀតថា: ពីមុនរៀងមក ធម៌ដែលជនទាំងឡាយ អ្នកប្រកបដោយមន្ទិលតែងគិត ជាធម៌មិនបរិសុទ្ធ កើតប្រាកដហើយក្នុងដែនមគធៈ សូមព្រះអង្គបើកទ្វារនៃព្រះនិព្វាននុ៎ះ សត្វទាំងឡាយប្រុងស្តាប់ធម៌ព្រះអង្គដែលជាអ្នកត្រាសចាកមន្ទិលហើយត្រាស់ដឹងតាមលំដាប់នៃព្រះពុទ្ធគុណ ។ ប្រៀបដូចជាបុរសអ្នកមានចក្ខុល្អ ឈរនៅលើកំពូលភ្នំថ្មសុទ្ធ ហើយក្រឡេកមើលមកប្រជុំជនដោយជុំវិញយ៉ាងណាមិញ ។ បពិត្រព្រះអង្គអ្នកមានបញ្ញាដ៏ល្អ មានសមន្តចក្ខុដ៏ល្អ ព្រះអង្គជាអ្នកមានសេចក្តីសោកទៅប្រាសហើយ សូមទ្រង់ឡើងកាន់ប្រាសាទកែវគឺធម៌ ពិចារណានូវប្រជុំ

ជន អ្នកប្រឡាក់ទៅដោយសេចក្តីសោក ដែលជាតិ ជរ កំពុងគ្របសង្កត់ កំហើងនោះផង ៗ បពិត្រព្រះអង្គអ្នកមានព្យាយាម អ្នកឈ្នះសង្គ្រាមហើយ ជានាយកនៃពួកសត្វ អ្នកមិនជំពាក់បំណុលគេគាម សូមព្រះអង្គក្រោកឡើង ហើយសំដែងធម៌, សត្វទាំងឡាយអ្នកបំរុងក្រាស់ដឹងនូវធម៌ក៏គង់មានខ្លះដែរ ៗ

ព្រោះនោះ ព្រះមានព្រះភាគទ្រង់ជ្រាបច្បាស់នូវសេចក្តីអារាធនារបស់សហម្បតិព្រហ្មផង ទ្រង់អាស្រ័យនូវសេចក្តីករុណាចំពោះសត្វទាំងឡាយផង ទើបទ្រង់ប្រមើលមើលនូវសត្វលោកដោយពុទ្ធចក្ខុ ៗ ទ្រង់បានឃើញសត្វទាំងឡាយ ដែលមានធូលីគឺរាគាទិក្កិលេសតិចខ្លះ, ច្រើនខ្លះ, មានឥន្ទ្រិយល្អខ្លះ, អាក្រក់ខ្លះ, ជាសត្វដែលព្រះអង្គគួរឲ្យក្រាស់ដឹងបានដោយងាយខ្លះ, ដោយកម្រខ្លះ, ជាអ្នកឃើញបរលោកនឹងទោសគួរខ្លាចខ្លះ លុះទ្រង់ឃើញហើយ ទើបទ្រង់សំដែងជាបទគាថា នឹងសហម្បតិព្រហ្មថា:

អបារុតា តេ អមតស្ស ទ្វារា
យេ សោតវន្តោ បមុញ្ចន្តុ សទ្ធំ ។
វិហឹសសញ្ញី បគុណំ ន ភាសឹ
ធម្មំ បណីតំ មនុជេសុ ព្រហ្មេ ។

ទ្វារនៃព្រះនិព្វានទាំងនោះបើកហើយ សត្វទាំងឡាយណាមានសោតប្រសាទ សត្វទាំងឡាយនោះចូរបញ្ចេញនូវសទ្ធា ៗ ម្នាលមហា-

ព្រហ្ម តថាគតគ្មានសំគាល់ក្នុងការបៀតបៀនទេ សំដែងធម៌ក្នុងសំណាក់មនុស្សទាំងឡាយ ចំពោះតែធម៌ដែលតថាគតស្គាល់ហើយ ជាធម៌ដ៏ក្តួយៗ

គ្រានោះ មហាព្រហ្មតបថា : ខ្ញុំអញជាបុគ្គលគំព្រះមានព្រះភាគយល់ព្រមដើម្បីសំដែងធម៌ហើយ គឺថ្វាយបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយបាត់អំពីទីនោះមួយរំពេចទៅ ។

ជាចំណោតខាងក្រោយមក ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ព្រះតម្រិះយ៉ាងនេះថា : តថាគតគួរសំដែងធម៌ដល់អ្នកណាមុនគេហ្ន៎ ! អ្នកណាកេបដឹងនូវធម៌នេះឆាប់ហ័ស ។ លំដាប់នោះ ទើបទ្រង់ព្រះតម្រិះទៀតថា : អាឡារតាបស កាលាមគោត្រនេះជាបណ្ឌិត ជាអ្នកឆ្លៀវឆ្លាសវាងវៃ ជាអ្នកមានបញ្ញា មានធូលីគឺកាមរាគៈលស់តិចមកយូរហើយ បើដូច្នេះ គួរតថាគតសំដែងធម៌ដល់អាឡារតាបស កាលាមគោត្រជាមុនចុះ តាបសនោះនឹងត្រាស់ដឹងធម៌នេះឆាប់ហ័សបាន ។ គ្រានោះ មានទេវតាមួយអង្គ មានរូបមិនប្រាកដ ក្រាបទូលព្រះមានព្រះភាគថា : បពិត្រព្រះអង្គដ៏ចំរើន អាឡារតាបស ធ្វើមរណកាលទៅអស់៧ថ្ងៃហើយ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ព្រះតម្រិះទៀតថា: តថាគតគួរសំដែងធម៌ដល់អ្នកណាជាមុនគេ: អ្នកណានឹងត្រាស់ដឹងធម៌នោះឆាប់ហ័សបាន ។ ក៏ទ្រង់ព្រះតម្រិះក្នុងលំដាប់នោះទៀតថា : ឧទ្ទកតាបស រាមបុត្រ ជាបណ្ឌិត ជាអ្នកមានបញ្ញា មានធូលីគឺកាមរាគៈលស់តិចមកយូរហើយ បើដូច្នេះ

គួរតថាគតសំដែងធម៌ដល់ឧទ្ទកតាបស កាមបុត្រជាមុនចុះ តាបសនោះទីន
ត្រាស់ដឹងធម៌នេះឆាប់រហ័សបាន ៗ គ្រានោះ មានទេវតាមួយអង្គ មាន
រូបមិនប្រាកដ ក្រាបទូលព្រះមានព្រះភាគថា : បពិត្រព្រះអង្គដ៏ចំរើន ឧទ្ទ-
កតាបសធ្វើមរណកាលអំពីពេលព្រលប់ទៅហើយ ៗ ព្រះមានព្រះ
ភាគក៏ទ្រង់ជ្រាបដូច្នោះដែរ ៗ ទើបទ្រង់ព្រះតម្រិះតទៅទៀតថា: បញ្ច-
វគ្គិយភិក្ខុទាំងឡាយមានឧបការៈច្រើនដល់តថាគត ព្រោះបានបំរើតថាគត
ក្នុងកាលដែលកំពុងបញ្ចូនចិត្តទៅក្នុងការព្យាយាម បើដូច្នេះ គួរតថាគត
សំដែងធម៌ដល់បញ្ចវគ្គិយភិក្ខុទាំងឡាយជាមុនចុះ ៗ គ្រានោះ ទ្រង់មាន
ព្រះតម្រិះទៀតថា : បញ្ចវគ្គិយភិក្ខុនៅក្នុងទីណា ! ក៏ទ្រង់ជ្រាបថា: នៅក្នុង
ឥសិបតនមិគទាយវ័ន ទៀបក្រុងពារាណសី ដោយទិព្វចក្ខុដ៏បរិសុទ្ធ ៗ
គ្រានោះ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងឧរុវេលប្រទេសតាមសមគួរ
ដល់ព្រះអធ្យាស្រ័យហើយ ទើបទ្រង់យាងទៅកាន់ចារិក សំដៅទៅរក
ក្រុងពារាណសី លុះចូលទៅដល់ក្រុងពារាណសីហើយ ទ្រង់យាងទៅឯ
ឥសិបតនមិគទាយវ័ន សំដៅទៅរកកន្លែងដែលបញ្ចវគ្គិយភិក្ខុគង់នៅ ៗ
បញ្ចវគ្គិយភិក្ខុ បានឃើញព្រះមានព្រះភាគយាងមកអំពីចម្ងាយហើយ
ក៏តិតគ្នាថា : ម្នាលអាវុសោ សមណគោតមនេះ ជាអ្នកប្រតិបត្តិដើម្បី
លាភ ឃ្លាតចាកព្យាយាមហើយ ឥឡូវនេះ គាត់និមន្តមក យើងទាំង
អស់គ្នាមិនគួរថ្វាយបង្គំ មិនគួរក្រោកទទួលគាត់ទេ មិនគួរទទួលយក

បាត្រ ទឹកចានរបស់គាត់ឡើយ ប៉ុន្តែយើងត្រូវក្រាលអាសនៈបំរុងទុក ចុះ បើគាត់ចង់គង់ក៏គង់ចុះ ។ លុះព្រះមានព្រះភាគចូលទៅដល់ហើយ បញ្ចវគ្គិយភិក្ខុទាំងអស់នោះ ក៏មិនអាចដើម្បីនឹងស្ថិតនៅក្នុងពាក្យកតិការបស់ខ្លួនដោយប្រការនោះ ៗ បានឡើយ, ត្រូវតែក្រោកឡើងក្រាលអាសនៈថ្វាយ ខ្លះដងទឹកលាងព្រះបាទ យកតាំងសម្រាប់ទងព្រះបាទ នឹងជ្រញ់ទងព្រះបាទមកថ្វាយ ។ ព្រះមានព្រះភាគក៏គង់លើអាសនៈដែលបញ្ចវគ្គិយភិក្ខុបានរៀបចំទុក លុះគង់ស្រួលបួលហើយ ទើបបញ្ចវគ្គិយភិក្ខុហៅព្រះមានព្រះភាគដោយចំព្រះនាមផង ដោយពាក្យថាអាវុសោផង ។

ព្រះមានព្រះភាគទ្រង់មានព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងអស់គ្នាកុំហៅតថាគតដោយចំឈ្មោះ នឹងដោយពាក្យថា អាវុសោឡើយ ម្នាលភិក្ខុទាំងឡាយ តថាគតជាអរហន្តសម្មាសម្ពុទ្ធហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរប្រុងស្តាប់ចុះ តថាគតនឹងប្រៀនប្រដៅនូវអមតធម៌ដែលតថាគតបានត្រាស់ដឹងហើយដល់អ្នក , ក៏កុលបុត្រទាំងឡាយ ដែលចេញចាកផ្ទះមកបួសក្នុងភាពជាអ្នកគ្មានការងារក្នុងផ្ទះ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌អរហត្តផលឯណា អ្នកទាំងឡាយកាលបើបានប្រតិបត្តិតាមពាក្យប្រដៅតថាគតហើយ កុំយូរប៉ុន្មានឡើយមុខជានឹងបានធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញារបស់ខ្លួនឯងក្នុងបច្ចុប្បន្ននេះ ចំពោះ

អនុត្តរធម៌ជាទីបំផុតនៃមគ្គព្រហ្មចរិយៈពុំខាន ។ កាលព្រះមានព្រះភាគមានព្រះពុទ្ធដីកាយ៉ាងនេះហើយ បញ្ចវគ្គិយភិក្ខុក៏ពោលពាក្យនេះនឹងព្រះមានព្រះភាគថា: បពិត្រព្រះគោតមដ៏មានអាយុ ព្រះអង្គមិនទាន់បានត្រាស់ដឹងនូវឧត្តរិមនុស្សធម៌ដ៏វិសេស ដោយញាណទស្សនៈដ៏ឧត្តម អាចកំចាត់បង់នូវកិលេស ដោយកិរិយាប្រព្រឹត្តនោះផង, ដោយសេចក្ដីប្រតិបត្តិនោះផង, ដោយអំពើដែលជនដទៃធ្វើកម្របានដោយកម្រនោះផង, ឥឡូវនេះព្រះអង្គប្រតិបត្តិដើម្បីលោភច្រើន ឃ្លាតចាកព្យាយាមហើយវិលត្រឡប់ដើម្បីលោភច្រើន នឹងបានត្រាស់ដឹងឧត្តរិមនុស្សធម៌ជាធម៌ដ៏វិសេស ដោយញាណទស្សនៈដ៏ឧត្តម អាចកំចាត់បង់នូវកិលេសដូចម្ដេចបាន ។ កាលបើបញ្ចវគ្គិយភិក្ខុពោលពាក្យយ៉ាងនេះអស់វារៈបីដងហើយ ព្រះមានព្រះភាគទ្រង់មានព្រះពុទ្ធដីកាថា: ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរពិចារណាមើលនូវពាក្យរបស់តថាគតឥឡូវនេះ ដូចគ្នានឹងកាលមុនដែរឬទេ ។ បញ្ចវគ្គិយភិក្ខុតបថា បពិត្រព្រះអង្គដ៏ចំរើន ពាក្យហ្នឹងព្រះអង្គមិនដែលពោលទេ ។ ក្នុងពេលនោះ ព្រះមានព្រះភាគមិនអាចនឹងញុំាងបញ្ចវគ្គិយភិក្ខុឲ្យយល់ច្បាស់បានឡើយ ។ លុះគ្រាខាងក្រោយមក បញ្ចវគ្គិយភិក្ខុក៏ផ្ចង់ចិត្តដើម្បីស្ដាប់ព្រះមានព្រះភាគ ផ្ទៀងនូវសោតប្រសាទស្ដាប់ហើយផ្ចង់ចិត្តដើម្បីដឹងច្បាស់ ។

គ្រានោះ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅបញ្ចវគ្គិយភិក្ខុទាំងឡាយ

មកហើយត្រាស់ថា “ទ្វេមេ ភិក្ខវេ អន្តា បព្វជិតេន ន សេវិតព្វា” ម្នាលភិក្ខុទាំងឡាយ អន្តធម៌ គឺធម៌ដ៏លាមកទាំងពីរនេះ បព្វជិតមិនគួរសេពគប់ឡើយ ។

ក៏ឯធម៌ដ៏លាមកទាំងពីរនោះគឺ ៖

១- កាមសុខល្លិកានុយោគោ កិរិយាប្រកបរឿយៗដោយកាមសុខក្នុងវត្ថុកាមទាំងឡាយ ដែលជាធម៌ថោកទាប, ជាធម៌អ្នកស្រុក, ជារបស់បុថុជ្ជន មិនមែនជារបស់អរិយបុគ្គល, មិនប្រកបដោយប្រយោជន៍ ។

២- អត្តកិលមថានុយោគោ កិរិយាប្រកបរឿយៗដោយកិរិយាញ៉ាំងខ្លួនឲ្យក្តៅសព្វ នឹងកិរិយាផុតកោលខ្លួនដោយជុំវិញ, ជាធម៌ប្រកបដោយសេចក្តីទុក្ខ មិនមែនជាធម៌មិនមានទោស គឺជាជាធម៌ប្រកបដោយទោស ឬថា ជាធម៌គឺព្រះអរិយៈមិនគប្បីសេព, ជាធម៌មិនប្រកបដោយប្រយោជន៍ ។

## អធិប្បាយអំពីអន្តធម៌ទាំងពីរយ៉ាង

ទី១- កាមសុខល្លិកានុយោគៈ កិរិយាប្រព្រឹត្តធ្វើសីលដោយកាមសុខ, ប្រព្រឹត្តធ្វើសមាធិកម្មដ្ឋានប្រកបដោយកាមសុខ ។ ប្រព្រឹត្តធ្វើសីលប្រកបដោយកាមសុខនោះ គឺយល់ឃើញថាសីលនេះឲ្យផលមកមានរូបល្អ, មានសម្បត្តិក៏ច្រើន, មានអាយុគង់វែង, ម្ល៉ោះហើយក៏ខំប្រព្រឹត្តធ្វើសីលមិនឲ្យដាច់ធ្លុះធ្លាយ ចិត្តកាន់យកសម្បត្តិនោះមកជាអារម្មណ៍

ខ្លះ, យករូបល្អនោះមកជាអារម្មណ៍ខ្លះ, យកអាយុវែងនោះមកជាអារម្មណ៍ខ្លះ ហើយក៏ខំព្យាយាមប្រព្រឹត្តប្រតិបត្តិ ដូចបានអធិប្បាយមកយ៉ាងនេះ ហៅថាកាមសុខល្លិកានុយោគៈ ព្រោះគ្រាន់តែនឹងវត្ថុកាម ។ ប្រព្រឹត្តបម្រើនព្រះកម្មដ្ឋានបានសម្រេចបឋមជ្ឈាន១, បានទុតិយជ្ឈាន១, បានតតិយជ្ឈាន១, បានចតុត្ថជ្ឈាន១, ។ បម្រើនអារុប្បកម្មដ្ឋាន៤ បានសម្រេចអរូបជ្ឈាន៤ គឺអាកាសានញ្ចាយតនជ្ឈាន១, វិញ្ញាណញ្ចាយតនជ្ឈាន១, អាកិញ្ចញ្ញាយតនជ្ឈាន១ នេវសញ្ញានាសញ្ញាយតនជ្ឈាន១, ខំព្យាយាមបម្រើនរូបកម្មដ្ឋាន នឹងអារុប្បកម្មដ្ឋាន ព្រោះយល់ឃើញផលរបស់កម្មដ្ឋានថានឹងបានសម្រេចទៅកើតក្នុងស្ថានព្រហ្មលោក១៦ ជាន់ នឹងអរូបព្រហ្ម៤ ជាន់ ហើយមានសេចក្តីពេញចិត្តត្រេកអរនឹងអាយុវែង, ពណ៌សម្បុរល្អ, សេចក្តីសុខ នឹងបរិបូណ៌ដោយសម្បត្តិ យសស័ក្តិ នឹងមានរូបល្អស្អាតផង ម៉្យាងហើយក៏ខំប្រឹងប្រែងព្យាយាមបម្រើនកម្មដ្ឋានមិនឲ្យដាច់ ព្រោះចិត្តនោះកាន់យកសម្បត្តិ-សេចក្តីសុខ-អាយុវែង-ពណ៌សម្បុរល្អ នោះមកកំណត់ទុកក្នុងចិត្តជាអារម្មណ៍; ប្រព្រឹត្តធ្វើសមណធម៌ពិតមែន តែចិត្តនៅត្រេកអរកើតកាយសប្បាយក្នុងភពបី ប្រកបដោយតណ្ហានឹងទិដ្ឋិ យ៉ាងនេះ ឈ្មោះថា កាមសុខល្លិកានុយោគៈ ប្រកបខ្លួនឲ្យជាប់ជំពាក់នៅក្នុងអន្ទង់គឺឱឃៈទាំង៤ គឺកាមោឃៈ១, ភវោឃៈ១, ទិដ្ឋោឃៈ១, អវិជ្ជោឃៈ១; ឱឃៈទាំង៤នេះ ជាអន្ទង់របស់សត្វដែលជាប់ត្រាំនៅក្នុងភពបី រកទីចប់ រក

ចិបំផុតគ្មាន ប្រៀបដូចត្រីដែលដេកត្រាំនៅក្នុងមហាសមុទ្រសាគរ ក៏យ៉ាង នោះដែរ ។

ចប់កាមសុខល្លិកានុយោគៈ ទី ១ តែប៉ុណ្ណេះ ។

ទី ២– អត្តកិលមថានុយោគៈ ការប្រព្រឹត្តធ្វើខ្លួនឲ្យលំបាកគ្មានបាន ផលប្រយោជន៍អ្វីពីការដែលប្រព្រឹត្តខុសនោះឡើយ ។ គឺប្រព្រឹត្តតែង តែងពេក ខុសបាកធម៌ វិន័យក្នុងសាសនា ពាក្យប្រដៅរបស់ព្រះសម្ពុទ្ធ បរមគ្រូជាម្ចាស់ស្រឡះពេក ។ គឺប្រព្រឹត្តធ្វើសីល ហើយកម្មមិនស្លុត ដោយព្រោះខ្លាចដាច់សីល, កម្មមិនហ៊ានស៊ីសាច់ព្រោះខ្លាចដាច់សីល, ពិចារណាឃើញទោសទុក្ខរបស់បញ្ចក្ខន្ធទាំង៥ មានរូបក្ខន្ធជាដើម ហើយក្បាយ៉ាមុយកភ្លើងមកដុតរូបចោល ព្រោះយល់ឃើញថារូបនេះមិនបានជា ការប្រយោជន៍អ្វី ។ ពិចារណាឃើញថារូបកាយនេះមានទុក្ខទោសច្រើន យ៉ាង ព្រោះកើតហើយចាស់ ។ ហើយឈឺ ។ ហើយស្លាប់, ទំស្វែងរក អាហារមកផប់លៀងគិតថាឲ្យរូបនៀងគាំងនៅ មិនដូច្នោះ រូបនោះក៏ចេះ តែចាស់គ្រាំគ្រាជកខ្ទុះក្រោមស្បែកស្រពោនទៅជាធម្មតា មានធ្មេញបាក់ សក់ស្កូវ សាច់ស្បែកជ្រួញជ្រីវយុរយារទុព្វលភាព ឃើញទោសរបស់រូប ដូច្នោះហើយ ក៏ឈប់ស្វែងរកអាហារបេកចរិភោគ ទំព្យាយាមចម្រើន សមណធម៌ អត់អាហាររហូតដល់តែអស់ជីវិតទៅ ព្រោះគំនិតយល់ឃើញថា អត់អាហារនេះបានសម្រេចមគ្គផល ។

បុគ្គលខ្លះយល់ថាយកភ្លើងមកដុតខ្លួន នឹងបានសម្រេចមគ្គផល, ខ្លះយល់ថាយកភ្លើងមកដុតហើយដេកផ្ងើរឲ្យស្ងួតកិលេស នឹងបានសម្រេចមគ្គផល ។ បើយល់ឃើញតាមន័យដែលបានអធិប្បាយមកនេះហៅថា អត្តកិលមថានុយោគៈ ។

អធិប្បាយសង្ខេបថា: បុគ្គលដែលប្រកបដោយរាគចរិតច្រើនប្រព្រឹត្តខ្ជិលៗ ធ្លាក់ចុះក្នុងផ្លូវកាមសុខល្លិកានុយោគៈ, បុគ្គលដែលប្រកបដោយទោសចរិតច្រើនប្រព្រឹត្តធម៌តឹងតែងពេកធ្លាក់ចុះក្នុងផ្លូវអត្តកិលមថានុយោគៈ ។

ម្នាលភិក្ខុទាំងឡាយ មជ្ឈិមាបដិបទាគឺសេចក្ដីប្រតិបត្តិយ៉ាងកណ្ដាល មិនប៉ះពាល់ដោយអន្តធម៌ទាំងពីរនោះ ដែលតថាគតបានត្រាស់ដឹងហើយ ជាសេចក្ដីប្រតិបត្តិដើម្បីឲ្យកើតបញ្ញាចក្ខុ គឺធ្វើឲ្យកើតសេចក្ដីចេះដឹង, ប្រព្រឹត្តទៅដើម្បីសេចក្ដីស្ងប់រម្ងាប់បាតកិលេស, ដើម្បីព្រះនិព្វានជាទីបំផុត ។ ម្នាលភិក្ខុទាំងឡាយ ចុះមជ្ឈិមាបដិបទា តើដូចម្ដេច? ម្នាលភិក្ខុទាំងឡាយ មជ្ឈិមាបដិបទានោះគឺ អរិយមគ្គ ប្រកបដោយអង្គ ៨ ប្រការ បានដល់ សេចក្ដីយល់ឃើញត្រូវ ១, សេចក្ដីត្រិះរិះត្រូវ ១, វាចាត្រូវ ១, ការងារត្រូវ ១, ការចិញ្ចឹមជីវិតត្រូវ ១, សេចក្ដីព្យាយាមត្រូវ ១, សេចក្ដីរលឹកត្រូវ ១, ការតាំងចិត្តត្រូវ ១, ។ ម្នាលភិក្ខុទាំងឡាយ មជ្ឈិមាបដិបទានេះឯង ដែលតថាគតបានត្រាស់ដឹងហើយ ជាសេចក្ដីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុ, តែងប្រព្រឹត្តទៅដើម្បីសេចក្ដីស្ងប់រម្ងាប់នូវកិលេស, ដើម្បី

ត្រាស់ដឹងនូវព្រះនិព្វាន (ជាទីបំផុត) ។ អរិយមគ្គ ឬ អដ្ឋង្គិកមគ្គ កើតឡើងប្រាកដក្នុងលោកតាំងសម័យនោះឯង ។

(ចប់ហេតុដែលនាំឲ្យកើតអរិយមគ្គ ឬ អដ្ឋង្គិកមគ្គតែប៉ុណ្ណេះ)

## អង្គរបស់អរិយមគ្គ ឬ អដ្ឋង្គិកមគ្គ

លំដាប់តទៅនេះ នឹងអធិប្បាយអំពីអង្គរបស់អរិយមគ្គ ឬ អដ្ឋង្គិកមគ្គ ទាំង ៨ ប្រការតទៅទៀត ។

អរិយមគ្គ ឬ អដ្ឋង្គិកមគ្គនេះមានអង្គ ៨ ប្រការគឺ ៖ សម្មាទិដ្ឋិ ១ ។ល។ សម្មាសមាធិ ១ ។

### អធិប្បាយអង្គមគ្គទី ១

សម្មាទិដ្ឋិ បានដល់បញ្ញាជាគ្រឿងយល់នូវធម៌ពិត ៤ យ៉ាងដែលហៅជាអរិយសច្ច គឺដឹងច្បាស់នូវកងទុក្ខទាំង ១៦ កងមានជាតិទុក្ខជាដើម ១, យល់ច្បាស់នូវកងតណ្ហាទាំង ៣ ប្រការមានកាមតណ្ហាជាដើម ជាទីប្រជុំនាំបណ្តាលឲ្យកើតទុក្ខ ក៏ជាហេតុនៃទុក្ខ ១, ដឹងច្បាស់នូវព្រះនិព្វានទាំងពីរប្រការមានសឧបាទិសេសនិព្វានជាដើម ជាធាតុរលត់ទុក្ខ ១, ដឹងច្បាស់នូវសេចក្តីប្រតិបត្តិតាមអរិយមគ្គប្រកបដោយអង្គទាំង ៨ ប្រការ ជាផ្លូវដើរទៅកាន់ទីរលត់ទុក្ខ ១ ។ សេចក្តីយល់ឃើញច្បាស់នូវធម៌ពិតទាំង ៤ យ៉ាងដូចពោលមកនេះហៅថា សម្មាទិដ្ឋិ ។

## អធិប្បាយអរិយសច្ច ៤

១ – ទុក្ខសច្ច បញ្ញាយល់ឃើញច្បាស់ក្នុងសង្ខារទាំង ៣ គឺបុញ្ញាភិសង្ខារ បានដល់ចេតនា ១៣ គឺកាមាវចរកុសលចេតនា ៨ និងរូបាវចរកុសលចេតនា ៥ ។ អបុញ្ញាភិសង្ខារ បានដល់អកុសលចេតនា១២, អនេញ្ជាភិសង្ខារ បានដល់អរូបាវចរកុសលចេតនា ៤; សង្ខារទាំង ៣ នេះ ជាអ្នកតាក់តែងជាតិកំណើតរបស់សត្វឲ្យកើតក្នុងភពបី គឺកាមភព, រូបភពនិងអរូបភព លុះសត្វនោះកើតឡើងហើយ តែងជួបប្រទះនឹងការសោកខ្សឹកខ្សួលជាដើម ឥតមានពេលឈប់ឈរឡើយ ។

បញ្ញា ពិចារណាឃើញច្បាស់ថា សង្ខារជាកុសលក្តី សង្ខារជាអកុសលក្តី, សង្ខារទាំងអស់នេះ សុទ្ធតែមិនទៀង មិនគង់នៅស្ថិតស្ថេរ, មិនមានការចម្រើនលូតលាស់ឡើយ, សង្ខារក៏មិនទៀងទាត់, ជាតិកំណើតដែលកើតមកអំពីសង្ខារនោះ ក៏មិនទៀងទាត់ដែរ; ធម៌ណាមិនទៀងទាត់ហើយ, ធម៌នោះតែងបង្កើតមក ឬនាំមកនូវសេចក្តីទុក្ខលំបាក ឥតស្រាកស្រាន្តឡើយ ព្រោះថា របស់ណាមិនទៀងទាត់ហើយ, របស់នុ៎ះជាទុក្ខ; របស់ណាជាទុក្ខហើយ, របស់នុ៎ះ ជាអនត្តា; របស់ណាជាអនត្តាហើយ, របស់នុ៎ះ បុគ្គលគប្បីដឹងដោយប្រាជ្ញា ថា នុ៎ះមិនមែនជារបស់អញទេ, នុ៎ះមិនមែនជាអញទេ, នុ៎ះមិនមែនជាខ្លួនរបស់អញទេ ។ សង្ខារទាំងឡាយទាំងក្នុងនេះ គឺគ្រាន់តែជាធាតុដី - ទឹក - ភ្លើង - ខ្យល់ - អាកាស

ប៉ុណ្ណោះឯង មិនមែនជាសត្វ, មិនមែនជាបុគ្គល, មិនមែនជាខ្លួនប្រាណ, មិនមែនគេ, មិនមែនយើង, មិនមែនស្រី, មិនមែនប្រុស, ជារបស់សោះសូន្យទទេ ។

បញ្ញាពិតណាឃើញច្បាស់ តាមសភាពធម៌ពិត ធម៌មែន ដូចបាន អធិប្បាយមកនេះ ហៅថា សម្មាទិដ្ឋិ ។

កន្ទុកទាំង ១៦ នោះ ពុំបានលើកយកមកអធិប្បាយឲ្យសព្វគ្រប់ទេ ព្រោះមានគន្ថច្បាប់អាយមគ្គាធិប្បាយ ទីងអាយសច្ចកថាសព្វគ្រប់ហើយ ។ កន្ទុកទាំងនេះទីងអធិប្បាយតែកន្ទុកដែលប្រជុំចុះចំពោះនៅលើខន្ធ៥, អាយតនៈ ១២, ការម្មណ៍ ៦ នឹងទ្វារ ៦ ។

ខន្ធ៥ នោះគឺ: រូបក្ខន្ធ ១, វេទនាខន្ធ ១, សញ្ញាខន្ធ ១, សង្ខារក្ខន្ធ ១, វិញ្ញាណក្ខន្ធ ១ ។

អាយតនៈ១២ នោះគឺ: ភ្នែក ១, ត្រចៀក ១, ច្រមុះ ១, អណ្តាត ១, កាយ ១, ចិត្ត ១, រូប ១, សំឡេង ១, ក្លិន ១, រស ១, ផ្សព្វផ្សាយ ១, ធម្មារម្មណ៍ ១ ត្រូវជា ១២ ។

ទ្វារ ៦ នោះគឺ: ចក្ខុទ្វារ ១, សោតទ្វារ ១, ឃានទ្វារ ១, ជិវ្ហាទ្វារ ១, កាយទ្វារ ១, មនោទ្វារ ១ ត្រូវជា ៦ ។

ការម្មណ៍ ៦ នោះគឺ: រូបារម្មណ៍ ១, សទ្ទារម្មណ៍ ១, គន្ធារម្មណ៍ ១, រសារម្មណ៍ ១, ផោដ្ឋព្វារម្មណ៍ ១, ធម្មារម្មណ៍ ១, ត្រូវជា ៦ ។

អធិប្បាយខ្ទង ៤

១)- រូបក្ខន្ធៈ គឺរូបទាំង ២៨ គឺមហាភូតរូប៤, ឧបាទាយរូប២៤ៗ

មហាភូតរូប ៤ នោះគឺ:

(១)- បឋវីធាតុរូប រូបគឺធាតុដី មាន ២០ គឺ កេសា សក់ទាំងឡាយ១, លោមា រោមទាំងឡាយ១, នខា ក្រចកទាំងឡាយ១, ទន្តា ធ្មេញទាំងឡាយ១, តចោ ស្បែក១, មំសំ សាច់១, នហារូ សរសៃទាំងឡាយ១, អដ្ឋី ឆ្អឹងទាំងឡាយ១, អដ្ឋិមិញ្ជំ ខួរក្នុងឆ្អឹង១, វក្កំ តប ឬតម្រងបស្សាវៈ១, ហទយំ បេះដូង១, យកនំ ថ្លើម១, កិលោមកំ វាវ១, បិហកំ ក្រពះ១, បប្ផាសំ សួត១, អន្តំ ពោះវៀនធំ១, អន្តគុណំ ពោះវៀនតូច១, ឧទរិយំ អាហារថ្មី១, ករីសំ អាហារចាស់១, មត្ថលុង្គំ ខួរក្បាល១ ត្រូវជាបឋវីធាតុរូប ២០ ៗ

(២) · អាបោធាតុរូប រូបធាតុទឹកមាន ១២ គឺ បិត្តំ ទឹកប្រមាត់១, សេម្ហំ ទឹកស្លេស្ម១, បុព្វោ ទឹកខ្ទុះ១, លោហិតំ ទឹកឈាម១, សេទោ ទឹកញើស១, មេទោ ខ្លាញ់ខាប់១, អស្សុ ទឹកភ្នែក១, វសា ខ្លាញ់រាវ១, ខេឡោ ទឹកមាត់១, សិង្ឃាណិកា ទឹកសម្បោរ១, លសិកា ទឹករំអិល១, មុត្តំ ទឹកមូត្រ១ ត្រូវជាអាបោធាតុរូប ១២ ៗ

(៣)- តេជោធាតុរូប រូបធាតុភ្លើងមាន ៤ គឺ សន្តប្បតិ ភ្លើងធាតុ ធប់ឲ្យក្តៅស្រួលផ្សាយទៅក្នុងកាយជាប្រក្រតី១, បរិណាមគ្គិ ភ្លើងធាតុ

ដុតកំដៅអាហារ ឲ្យទ្រុឌទ្រោមរលួយទៅ ១, បរិទយ្ហគ្គិ ភ្លើងធាតុដុតឲ្យក្តៅក្រហល់ក្រហាយទៅក្នុងកាយ ១, ជិរណគ្គិ ភ្លើងធាតុដុតកំដៅកងកាយឲ្យទុំទន់ទុក ភ្នែកងងឹត, ត្រចៀកថ្លង់, ធ្មេញបាក់, សក់ស្កូវ, សាច់ស្បែក - ជ្រួញជ្រីវជាដើម ១, ត្រូវជាតេជោធាតុរូប ៤ ។

(៤)- វាយោធាតុរូប រូបធាតុខ្យល់មាន ៦ គឺ ៖ ឧទ្ធង្គមាវាត ខ្យល់បក់ពីខាងលើផ្សាយចុះមកខាងក្រោម ១, អធោគមាវាត, ខ្យល់បក់ពីខាងក្រោមផ្សាយឡើងទៅខាងលើ ១, កុច្ឆិសយាវាត ខ្យល់បក់ក្រៅពោះវៀនក្នុងផ្ទៃ ១, កោដ្ឋាសយាវាត ខ្យល់បក់នៅក្នុងពោះវៀនធំ-តូច ១; អង្គមង្គានុសារីវាត ខ្យល់បក់ផ្សាយសព្វទៅក្នុងសរសៃធំ-តូច ១; អស្សាសបស្សាសវាត ខ្យល់សម្រាប់ដកដង្ហើមចេញនិងដកដង្ហើមចូល ១ ត្រូវជាវាយោធាតុរូប ៦ ។ រួមត្រូវជាមហាភូតរូប ៤ បើកប់កាយ ៤២ ។ ឯ ៖ ឧបាទាយរូប ២៤ នោះ ពុំបានអធិប្បាយទេ ។

មហាភូតរូប ៤ និង ៖ ឧបាទាយរូប ២៤ រួមត្រូវជា ២៨; រូបទាំង ២៨ នេះ ព្រះសម្ពុទ្ធទ្រង់ត្រាស់ហៅថា រូបក្ខន្ធ ។

បញ្ញត្តិណាឃើញច្បាស់ក្នុងរូបក្ខន្ធនេះ ថាជាធាតុដី-ទឹក ភ្លើង-ខ្យល់-អាកាស ដូចពោលមកនេះ ហៅថា សម្មតិ ។

២)- វេទនាខន្ធ: វេទនា ប្រែថា គឺជាកិរិយាសោយនូវអារម្មណ៍ ដូចពាក្យដែលព្រះសារីបុត្តត្រាស់ថែងថា វេទយតិ តិ ខោ អាវុ-

សោ តស្មា វេទនា'តិ វុច្ចតិ "ធម្មជាតិណាសោយនូវអារម្មណ៍ ធម្មជាតិនោះ ព្រះមានព្រះភាគត្រាស់ហៅថា វេទនា"; វេទនានេះ ជាតួចេតសិកធម៌មួយសម្រាប់ញ៉ាំងចិត្តឲ្យដឹងរសនៃអារម្មណ៍ បើអារម្មណ៍ជាសុខ, ជាទុក្ខ ឬ ជាឧបេក្ខាមកដល់ហើយ ចេតសិកធម៌គឺវេទនានេះ ក៏ទទួលដឹងនូវរសនៃអារម្មណ៍នោះៗ បានទាំងអស់ ព្រោះវេទនានេះជាសព្វចិត្តសាធារណចេតសិក ដូចគ្នានឹងផស្សៈដែរ បើចែកទៅតាមទីកន្លែងដែលកើត មាន ៦ ប្រការគឺ៖

(១)- ចក្ខុសម្ផស្សជា វេទនា វេទនាដែលកើតដោយចក្ខុសម្ផស្សៈ;

(២)- សោតសម្ផស្សជា វេទនា វេទនាដែលកើតដោយសោតសម្ផស្សៈ;

(៣)- ឃានសម្ផស្សជា វេទនា វេទនាដែលកើតដោយឃានសម្ផស្សៈ;

(៤)- ជិវ្ហាសម្ផស្សជា វេទនា វេទនាដែលកើតដោយជិវ្ហាសម្ផស្សៈ;

(៥)- កាយសម្ផស្សជា វេទនា វេទនាដែលកើតដោយកាយសម្ផស្សៈ;

(៦)- មនោសម្ផស្សជា វេទនា វេទនាដែលកើតដោយមនោសម្ផស្សៈ;

វេទនាខន្ធ បើចាត់តាមជាតិវិញ មាន ៣ យ៉ាងគឺ កុសលវេទនា ១, អកុសលវេទនា ១, អព្យាកតវេទនា ១, រួបរួមវេទនាទាំងអស់ ដូចបានរៀបរាប់មកប៉ុណ្ណោះជាដើមនេះ ហៅថា "វេទនាខន្ធ" ។

៣)- សញ្ញាខន្ធៈ សញ្ញា ប្រែថា ធម្មជាតិដឹង ឬ ស្គាល់ដោយប្រាកដ នូវអារម្មណ៍មានពណ៌ខៀវ លឿងជាដើម ឬ ថាធម្មជាតិចំណាំនូវ

អារម្មណ៍, ដូចពាក្យដែលព្រះសារីបុត្តត្ថេរសំដែងថា សញ្ជានាតិ' តិ ខោ អាវុសោ តស្មា សញ្ញា' តិ វុច្ចតិ "ម្នាលអាវុសោ ធម្មជាតិណាចំណាំនូវអារម្មណ៍ ធម្មជាតិនោះព្រះមានព្រះភាគត្រាស់ហៅថា "សញ្ញា" ។

សញ្ញានេះ បើចែកទៅតាមប្រភេទនៃអារម្មណ៍មាន ៦ យ៉ាងគឺ:

(១)- រូបសញ្ញា ធម្មជាតិសំគាល់នូវរូបារម្មណ៍ ;

(២)- សទ្ទសញ្ញា ធម្មជាតិសំគាល់នូវសទ្ទារម្មណ៍ ;

(៣)- គន្ធសញ្ញា ធម្មជាតិសំគាល់នូវគន្ធារម្មណ៍ ;

(៤) រសសញ្ញា ធម្មជាតិសំគាល់នូវរសារម្មណ៍ ;

(៥) ផោដ្ឋព្វសញ្ញា ធម្មជាតិសំគាល់នូវផោដ្ឋព្វារម្មណ៍ ;

(៦)- ធម្មសញ្ញា ធម្មជាតិសំគាល់នូវធម្មារម្មណ៍ ។

សញ្ញានេះ បើចែកតាមជាតិវិញមាន ៣ ប្រការគឺ កុសលសញ្ញា ១, អកុសលសញ្ញា ១, អព្យាកតសញ្ញា ១, ដូចគ្នានឹងវេទនាដែរ; រួបរួមសញ្ញាទាំងអស់ដូចបានរៀបរាប់មកប៉ុណ្ណោះជាដើមនេះ ព្រះសម្មាសម្ពុទ្ធត្រាស់ហៅថា "សញ្ញាខន្ធ" ។

៤) សង្ខារក្ខន្ធៈ សង្ខារ ប្រែថា ការតាក់តែង, គ្រឿងប្រកប, គ្រឿងប្រជុំ, គ្រឿងប្រមូលផ្ដុំ ចែកជា ៣ យ៉ាងគឺ:

(១)- បុញ្ញាភិសង្ខារ សភាវៈតាក់តែងសត្វឲ្យកើតក្នុងភាពជាទេវរូប

និងរូបាវចរភូមិ ។

(២)- អបុញ្ញាភិសង្ខារ សភាវៈតាក់តែងសត្វឲ្យកើតក្នុងអបាយភូមិទាំង ៤ មាននរកជាដើម ។

(៣)- អានេញ្ជាភិសង្ខារ សភាវៈតាក់តែងសត្វឲ្យកើតក្នុងអរូបព្រហ្ម (ព្រហ្មឥតរូប) ។

សង្ខារនៅចែកជា ៣ យ៉ាងទៀតគឺៈ

(១) កាយសង្ខារ សភាវៈជាគ្រឿងញុំាងអវយវៈឲ្យកំរើកដូចលើកដៃ, លើកជើង, ឈានដើរជាដើម ។

(២)- វចីសង្ខារ សភាវៈធ្វើឲ្យកម្រើកពាក្យនិយាយស្តី, សើច, យំជាដើម ។

(៣)- ចិត្តសង្ខារ សភាវៈជាគ្រឿងត្រិះរិះនូវអារម្មណ៍ផ្សេងៗ ។

សង្ខារក្ខន្ធនេះបើចែកទៅតាមជាតិវិញមាន ៣ យ៉ាងគឺ កុសលសង្ខារ១, អកុសលសង្ខារ១, អព្យាកតសង្ខារ១, ដូចគ្នានឹងវេទនាដែរ ។

រួបរួមសង្ខារទាំងអស់ ដូចបានរៀបរាប់មកប៉ុណ្ណោះជាដើមនេះ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ហៅថា "សង្ខារក្ខន្ធ" ។

៥)-- វិញ្ញាណក្ខន្ធៈ វិញ្ញាណ ប្រែថា ធម្មជាតដឹងច្បាស់នូវអារម្មណ៍ទាំងពួង គឺអារម្មណ៍ទាំង ៦ មានរូបារម្មណ៍ជាដើម ដែលមកប៉ះនឹងទ្វារទាំង ៦ មានចក្ខុទ្វារជាដើម, វិញ្ញាណនេះហៅថា "ចិត្ត" ក៏បាន

ព្រោះជាធម្មជាតដែលគិតសន្សំនូវអារម្មណ៍ទាំងពួង, ហៅថា "មនោ" ក៏បាន ព្រោះជាធម្មជាតដែលទន់ទោរទៅកាន់អារម្មណ៍ទាំងពួង ។

វិញ្ញាណនេះ បើចែកទៅតាមទ្វារជាទីកើតមាន ៦ យ៉ាងគឺ ៖

(១)-ចក្ខុវិញ្ញាណ ធម្មជាតដឹងច្បាស់នូវរូបារម្មណ៍ក្នុងចក្ខុទ្វារ ;

(២)-សោតវិញ្ញាណ ធម្មជាតដឹងច្បាស់នូវសទ្ទារម្មណ៍ក្នុងសោតទ្វារ ;

(៣)-ឃានវិញ្ញាណ ធម្មជាតដឹងច្បាស់នូវគន្ធារម្មណ៍ក្នុងឃានទ្វារ ;

(៤)-ជិវ្ហាវិញ្ញាណ ធម្មជាតដឹងច្បាស់នូវរសារម្មណ៍ក្នុងជិវ្ហាទ្វារ ;

(៥)-កាយវិញ្ញាណ ធម្មជាតដឹងច្បាស់នូវផោដ្ឋព្វារម្មណ៍ក្នុងកាយទ្វារ ;

(៦)-មនោវិញ្ញាណ ធម្មជាតដឹងច្បាស់នូវធម្មារម្មណ៍ក្នុងមនោទ្វារ ។

វិញ្ញាណនេះ បើចែកទៅតាមជាតិវិញមាន ៣ ប្រការគឺ កុសលវិញ្ញាណ ១, អកុសលវិញ្ញាណ ១, អព្យាកតវិញ្ញាណ ១, ដូចគ្នានឹងវេទនាដែរ ។

រូបរួមវិញ្ញាណទាំងអស់ ដូចបានរៀបរាប់មកប៉ុណ្ណេះជាដើមនេះ ព្រះសាស្តាជាម្ចាស់ទ្រង់ត្រាស់ហៅថា "វិញ្ញាណក្ខន្ធ" ។

ឯធម៌ជាដែនកើត នឹងធម៌ជាទីរលត់នៃបញ្ចក្ខន្ធនោះមាន ១០, ព្រះយោគាវចរកុលបុត្រជាបណ្ឌិត គប្បីពិចារណានូវបច្ច័យនេះ, ត្រៀមផ្ចង់សតិ គឺស្មារតីឲ្យដឹងច្បាស់ថា ក្នុងខន្ធទាំង៥នេះ ខន្ធមួយៗ មានធម៌ចំនួនប៉ុន្មាន?, ធម៌ដែលជាដែនកើតឡើងនឹងធម៌ជាទីរលត់ទៅវិញនៃខន្ធមួយ ៗ មានប៉ុន្មាន ?

គប្បីឲ្យដឹងច្បាស់គ្រប់ ៗ ខន្ធទាំងអស់ដូច្នេះគឺៈ រូបក្ខន្ធ គឺនូវរូបមាន ២៨ គឺ មហាភូតរូប៤, ឧបាទាយរូប២៤ ៗ (មានសព្វគ្រប់ក្នុងសៀវភៅអភិធម្មត្ថសង្គហៈហើយ) ។

ធម៌ជាដែនកើតនៃរូបក្ខន្ធមាន ៥ គឺ អវិជ្ជា១, តណ្ហា១, ឧបាទាន១, កម្ម១, អាហារ១ ។ បើធម៌ទាំង ៥ នេះរលត់ទៅពេលណា រូបក្ខន្ធក៏រលត់ទៅពេលនោះ ។

វេទនាខន្ធ១, សញ្ញាខន្ធ១, សង្ខារក្ខន្ធ១, វិញ្ញាណក្ខន្ធ១, ទាំង៤ នេះ បើចាត់តាមជាតិវិញមាន ៣ ៗ ដូចគ្នា គឺកុសល១, អកុសល១, អព្យាក្រឹត១ ។

ធម៌ជាដែនកើតនៃវេទនាខន្ធ, សញ្ញាខន្ធ និងសង្ខារក្ខន្ធ នេះមាន ៥ ៗ ដូចគ្នា គឺអវិជ្ជា១, តណ្ហា១, ឧបាទាន១, កម្ម១, ផស្សៈ១ ។ បើធម៌ទាំង ៥ នេះរលត់ទៅពេលណា វេទនាខន្ធ, សញ្ញាខន្ធ និងសង្ខារក្ខន្ធ ក៏រលត់ទៅក្នុងពេលនោះ ។

ឯធម៌ជាដែនកើតនៃវិញ្ញាណក្ខន្ធមាន ៥ គឺ អវិជ្ជា១, តណ្ហា១, ឧបាទាន១, កម្ម១, នាមរូប១ ។ បើធម៌ទាំង ៥ នេះរលត់ទៅពេលណា វិញ្ញាណក្ខន្ធ ក៏រលត់ទៅពេលនោះដែរ ។

ការពិចារណាឲ្យឃើញច្បាស់យ៉ាងនេះ ដើម្បីឲ្យចំរើនប្រាជ្ញាស្មារតី កុំឲ្យប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោក ។ រួបរួមសេចក្តីនៃធម៌ទាំងអស់

ដែលបានអធិប្បាយមកខាងលើនេះ ព្រះបរមសាស្ដាទ្រង់ត្រាស់ហៅថា ១៩៥ ។

## អាយតនៈ ១២

អាយតនៈ ប្រែថា លំនៅ, អណ្ដូង, សមោសរណដ្ឋាន, សញ្ជាតិ, ប្រទេស, ជាតិភូមិ, ប្រភព ; ចែកចេញជា ១២ គឺ: អាយតនៈ ខាងក្នុង ៦, អាយតនៈ ខាងក្រៅ ៦ ។

អាយតនៈខាងក្នុង ៦ គឺ:

(១)- ចក្ខាយតនៈ: អាយនៈ: គឺភ្នែក;

(២)- សោតាយតនៈ: អាយតនៈ: គឺត្រចៀក;

(៣). ឃានាយតនៈ: អាយតនៈ: គឺច្រមុះ;

(៤)- ជិវ្ហាយតនៈ: អាយតនៈ: គឺអណ្ដាត ;

(៥)- កាយាយតនៈ: អាយតនៈ: គឺកាយ ;

(៦)- មនាយតនៈ: អាយតនៈ: គឺចិត្ត ;

អាយតនៈខាងក្រៅ ៦ គឺ:

(១)- រូបាយតនៈ: អាយតនៈ: គឺរូប ;

(២)- សទ្ទាយតនៈ: អាយតនៈ: គឺសំឡេង ;

(៣)- គន្ធាយតនៈ: អាយតនៈ: គឺក្លិន ;

៤- រសាយតនៈ: អាយតនៈ: គឺរស ;

សង្ខតលក្ខណៈនេះ ចែកចេញជា ៣ យ៉ាងគឺ :

(១)- ឧប្បាទ គឺកិរិយាកើតឡើង ហៅថា ឧប្បាទលក្ខណៈ ;

(២)- វយោ គឺកិរិយាសាបសូន្យទៅ ហៅថា វយលក្ខណៈ ;

(៣)- ឋិតិ គឺកិរិយាស្ថិតនៅ ហៅថា ឋិតិលក្ខណៈ ។

ម្យ៉ាងទៀត ទុក្ខសច្ចនេះ ចាត់ជាកុសលផង, ជាអកុសលផង, ជាអព្យាក្រឹតផង ។

ទុក្ខសច្ច ដែលចាត់ជាកុសលនោះ សេចក្ដីថាកាលដែលបុរសបុគ្គល ខំប្រឹងប្រែងចម្រើនសមថកម្មដ្ឋាន ឬប្រព្រឹត្តនូវធុតង្គទាំង ១៣ ឬធ្វើនូវកុសលផ្សេងៗ មានសេចក្ដីលំបាកនឿយហត់ដោយខំប្រឹងប្រែងធ្វើអំពើទាំងនោះ ហៅថា ទុក្ខ ប៉ុន្តែអំពើទាំងនោះជាកុសល ទើបចាត់ថា ទុក្ខសច្ច ជាកុសល ។

ទុក្ខសច្ច ដែលចាត់ជាអកុសលនោះ សេចក្ដីថា កាលបើបុរសបុគ្គល ប្រព្រឹត្តធ្វើនូវបាបកម្មទាំងឡាយ មានបាណាតិបាតជាដើម លំបាកដោយក្រៀវក្រៀមខ្វល់ក្ដៅ ថែមទាំងភ័យខ្លាចគេចាប់ចង ព្រោះធ្វើបាបកម្មជាដើម យ៉ាងនេះហៅថា ទុក្ខ ថែមទាំងអំពើនោះ ជាអកុសលទៀត ទើបចាត់ថា ទុក្ខសច្ច ជាអកុសល ។

ទុក្ខសច្ច ដែលចាត់ជាអព្យាក្រឹតនោះ សេចក្ដីថា ព្រះអរិយៈទាំងឡាយ ដែលបានសម្រេចព្រះអរហត្តផល មានព្រះសម្ពុទ្ធជាដើម តែង

ប្រឹងប្រែងប្រតិបត្តិ មានកិច្ចវត្តផ្សេងៗ ពីទំសំដែងធម៌ព្រោះបសុត្ត លំបាកនឿយហត់ តែពុំបានមគ្គផលទៀតឡើយ យ៉ាងនេះជាដើម ហៅថា ទុក្ខសច្ចជាអព្យាក្រឹត ។

លក្ខណៈកិច្ច និងផលរបស់ទុក្ខសច្ចៈ

— ពីឡនលក្ខណំ ទុក្ខសច្ចមានកិរិយាបៀតបៀននូវបុគ្គលជាលក្ខណៈ ។

— សន្តាបនរសំ ទុក្ខសច្ចមានកិរិយាក្ដៅក្រហាយជាកិច្ច ។

— បវត្តិបច្ចុប្បដ្ឋានំ ទុក្ខសច្ចមានកិរិយាប្រព្រឹត្តទៅក្នុងភព ៣ ជាផល ។

សេចក្ដីឧបមារបស់ទុក្ខសច្ចមាន ៣ យ៉ាងគឺ:

(១)- ភារោ វិយ ទុក្ខសច្ចំ ទុក្ខសច្ចដូចជាគ្រឿងធ្ងន់នៅលើស្មា;

(២)- រោគោ វិយ ទុក្ខសច្ចំ ទុក្ខសច្ចដូចជារោគចាក់ដោតនៅក្នុងរូបកាយ ;

(៣)- ទុព្ភិក្ខំ ទុក្ខសច្ចំ ទុក្ខសច្ចដូចជាស្រុកទុព្ភិក្សអត់បាយ ។

ប្រភេទរបស់ទុក្ខសច្ចៈ

ទុក្ខសច្ចបើសំដែងដោយប្រភេទមួយ បានដល់ការញ៉ាំងវដ្តសង្សារឲ្យប្រព្រឹត្តទៅ ។ បើសំដែងដោយប្រភេទពីរ បានដល់នាម១, រូប១ ។ បើសំដែងដោយប្រភេទបី បានដល់កាមភព១, រូបភព១, ឧបបត្តិភព១ ។

បើសំដែងដោយប្រភេទ ៤ បានដល់អាហារ ៤ យ៉ាង មានកវឡិង្ការាហារ ជាដើម ។ បើសំដែងដោយប្រភេទ ៨ បានដល់ទុក្ខទាំង ៨ មានជាតិទុក្ខជាដើម ។ បើតាត់ជាសេចក្ដីសង្ខេបវិញ ទុក្ខសច្ច នេះជាបរិញ្ញាកិច្ច គឺកិច្ចដែលព្រះយោគាវចរគប្បីកំណត់ដឹង ។

២ – សមុទយសច្ច កំណើតនៃសេចក្ដីទុក្ខ ឬហេតុដែលនាំឲ្យកើតទុក្ខ ចាត់ជាអរិយសច្ចទី ២ ។ សមុទយអរិយសច្ចនេះ ព្រះអរហន្តសម្មាសម្ពុទ្ធ ទ្រង់សំដែងក្នុងសតិបដ្ឋានសូត្រថា :

កតមញ្ច ភិក្ខវេ ទុក្ខសមុទយោ អរិយសច្ចំ= ម្នាលភិក្ខុទាំងឡាយ ដូចម្ដេចហៅថា ទុក្ខសមុទយអរិយសច្ច ?

យាយំ តណ្ហា ពោនោព្ភវិកា នន្ទិរាគសហគតា តត្រ តត្រាភិនន្ទិនី សេយ្យថីទំ កាមតណ្ហា ភវតណ្ហា វិភវតណ្ហា ឥទំ វុច្ចតិ ភិក្ខវេ ទុក្ខសមុទយោ អរិយសច្ចំ=

តណ្ហាឯណា ដែលមានកិរិយាធ្វើនូវភពថ្មីជាប្រក្រតី កើតលក់ព្រម ដោយនន្ទិរាគ គឺសេចក្ដីត្រេកត្រអាលចំពោះអារម្មណ៍នោះៗ ឬចំពោះភព នោះៗ តណ្ហានោះដូចម្ដេច? គឺកាមតណ្ហា សេចក្ដីត្រេកត្រអាលចំពោះ កាមគត ឬចំពោះកាមគុណទាំង៥យ៉ាង១, ភវតណ្ហា សេចក្ដីត្រេកត្រអាល ចំពោះរូបភពនិងអរូបភព ឬអាល័យក្នុងឈាន មានតម្រេកក្នុងរូបភព

ធីនអប្បវត្តកប្រកបដោយសស្សតទិដ្ឋិ(១)។ តែតណ្ហាមានការប្រកបនូវប្បវត្ត ធីនអប្បវត្តកប្រកបដោយឧច្ឆេទទិដ្ឋិ(២) ។ ម្នាលភិក្ខុទាំងឡាយ នេះ ហៅថា ទុក្ខសមុទយអរិយសច្ច ។

ក្នុងផ្នែកពុទ្ធភាសិតនេះ ព្រះសម្ពុទ្ធទ្រង់ពាក់តណ្ហាទាំង ៣ នេះ ឲ្យឈ្មោះថា សមុទយអរិយសច្ច ព្រោះតណ្ហាទាំង ៣ នេះជាកំណើតនៃទុក្ខ ឬជាហេតុដែលនាំឲ្យកើតទុក្ខ ។

ពាក្យថា "តណ្ហា" ប្រែថា ស្តខ្ទក់ គឺថាចង់បាននូវសម្បត្តិដ៏លាមក ដោយមានបទវិគ្រោះក្នុងគម្ពីរសព្ទបញ្ចប់កាសុចថា តសតិ ទាប់ វត្តតិ តិ = តណ្ហា ប្រែថា ធម្មជាតិណាស្តខ្ទក់ គឺថា ចង់បាននូវសម្បត្តិដ៏លាមក (សម្បត្តិក្នុងត្រៃភព) ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា តណ្ហា ។

សេចក្តីថា៖ សម្បត្តិក្នុងត្រៃភព បានដល់សម្បត្តិក្នុងកាមភព, រូបភព អរូបភព, សម្បត្តិទាំងនេះសុទ្ធសឹងជាសម្បត្តិឥតខ្លឹមសារ ព្រោះមានសេចក្តីប្រែប្រួលជាធម្មតា ឥតមានកំណត់កាលវេលា ទើបលោកចាត់ថាជាសម្បត្តិដ៏លាមក ។ បុគ្គលណាយល់ឃើញសម្បត្តិក្នុងភពទាំង៣នេះដែលជាសម្បត្តិដ៏លាមកថាជាសម្បត្តិវិចិត្រដេះហើយ ក៏មិនបានគិតដល់សេចក្តី

---

• ១ យល់ឃើញថា សត្វដែលកើតក្នុងភពនេះ ស្លាប់ហើយកើតវិញជាធម្មតា ។ ២ យល់ឃើញថា សត្វដែលកើតក្នុងភពនេះ ស្លាប់ហើយសូន្យជាធម្មតា ។

វិនាសប្រែប្រួល នៃសម្បត្តិទាំងនោះសោះ ស្រាប់តែមានសេចក្តីយល់ខុសកើតឡើងថា ក្នុងកាមភពមានសេចក្តីសុខច្រើន ព្រោះប្រកបដោយទិព្វសម្បត្តិច្រើនប្រការ, ក្នុងរូបភពមានសេចក្តីសុខទៀងទាត់ ព្រោះមិនងាយជួបប្រទះនឹងសេចក្តីស្លាប់, ក្នុងអរូបភពមិនមានសេចក្តីទុក្ខដោយដាច់ខាត ព្រោះថាបើមិនមានរូបហើយក៏បានរួចផុតគ្រឿងនាំមកនូវសេចក្តីទុក្ខ ។ កាលបើសេចក្តីយល់ខុសកើតឡើងដូច្នេះហើយ ការចង់បាននូវសម្បត្តិទាំង ៣ គឺចង់ប្រាថ្នាចង់កើតក្នុងភពទាំង ៣ នោះក៏កើតឡើង, សេចក្តីប្រាថ្នារបស់បុគ្គលយ៉ាងនេះលោកហៅថា តណ្ហា ។

ម្យ៉ាងទៀត បើប្រាថ្នាជាព្រះពុទ្ធភូមិក្តី, បច្ចេកពុទ្ធក្តី, អគ្គសាវក ឬទុតិយសាវកក្តី, ជាពុទ្ធមាតា ឬ ពុទ្ធបិតាក្តី, ពុទ្ធបដ្ឋាកក្តី, ជាកន្ទៀសាពិជក្តី, ជាពុទ្ធបុត្រ ឬ គឺជាអសីតិមហាសាវកជាដើមក្តី, សេចក្តីប្រាថ្នាមានសភាពដូច្នេះ មិនចាត់ចូលក្នុងពាក្យថា តណ្ហា(១)ទេ ព្រោះព្រះពុទ្ធ, ព្រះបច្ចេកពុទ្ធ, អគ្គសាវក, ទុតិយសាវក, ពុទ្ធមាតា, ពុទ្ធបិតា និងកន្សែ កើតជាដើមនេះ សុទ្ធតែបំរុងនឹងបានសម្រេចមគ្គផល កន្លងនូវភពទាំង ៣ ផុតចាកវិស័យតណ្ហា ព្រោះហេតុនោះ ទើបមិនចាត់ចូលក្នុងតណ្ហា ។

តណ្ហានេះឯង មានន័យចែកជាច្រើនយ៉ាង គឺៈ ៦ ក៏មាន, ជា ៣

---

១ គេហៅថា សម្មាឆន្ទៈ សេចក្តីពេញចិត្តក្នុងការកុសល ។

ក៏មាន, ជា ១០៨ ក៏មាន តែក្នុងទីនេះមិនបានអធិប្បាយតាមន័យដែលចែកជា២, ជា៣, ជា ១០៨ នោះទេ ព្រោះមានសព្វគ្រប់ក្នុងអរិយមគ្គាធិប្បាយឯណោះហើយ ។ ក្នុងទីនេះនឹងអធិប្បាយបន្ថែមតែអំពីពាក្យថា "តណ្ហា" តាមន័យដែលបានសំដែងមកខាងលើ ដូចតទៅនេះ ៖

បញ្ញាឃើញច្បាស់ថាក្នុងទុក្ខទាំងអស់នេះមានមកតែអំពីតណ្ហាជាហេតុនាំបណ្ដាលឲ្យកើតទុក្ខ ព្រួយលំបាកគ្រប់យ៉ាង, មានទុក្ខអំពីការកើតឡើងនៃខន្ធទាំង ៥ ជាដើម ។ តណ្ហានោះមាន ៣ ប្រការដូចបានពោលមកខាងលើមួយសាហើយ គឺកាមតណ្ហា សេចក្ដីប្រាថ្នាក្នុងកាមគុណ ៥ ហើយត្រេកអរ ញៀនញាម ជាប់ចិត្តនឹងរូប-សំឡេង-ក្លិន-រស-ផ្សព្វផ្សាយប្រាថ្នាចង់តែបាន, ចង់តែមាន បើបានហើយក៏មានសេចក្ដីត្រេកអររីករាយ, បើមិនបានក៏កើតជាសេចក្ដីទុក្ខព្រួយលំបាកយ៉ាងក្រៃលែង; សេចក្ដីចំណង់ចង់បាននេះក៏កើតទុក្ខ ព្រោះធ្វើខ្លួនឲ្យលំបាកទៅតាមចំណង់ប្រាថ្នានោះឯង ។ កាមតណ្ហានេះជាហេតុនាំបណ្ដាលឲ្យកើតទុក្ខ ។ ភវតណ្ហាតណ្ហាដែលធ្វើចិត្តរបស់សត្វឲ្យជាប់ស្អិតលង់លិចនៅក្នុងអទ្ធន៍ គឺកាមគុណ ៥, ជាប់ស្អិតនៅក្នុងខន្ធ៥, ជាប់ស្អិតនៅក្នុងអាយតនៈ១២, ទ្វារ៦, អារម្មណ៍ ៦ ប្រការជាប់ស្អិតនៅក្នុងអំណាចកាមគុណ ៥ ថាជារបស់វិសេស, ជារបស់ទៀង-សុខ-ចំរើន, ប្រកាន់ជាប់ស្អិតមិនចង់ឲ្យវិនាសព្រាត់ប្រាសបាត់បង់ទៅ, ម្ល៉ោះហើយក៏ខំថែទាំរក្សា ការពារឲ្យតាំងនៅទៀងទាត់; យ៉ាង

នេះហៅថា ភវតណ្ហា, ភវតណ្ហានេះជាហេតុនាំបណ្ដាលឲ្យកើតទុក្ខ ១ ។ វិភវតណ្ហា តណ្ហាដែលប្រាថ្នា មិនចង់ឲ្យជួបប្រទះនឹងរូបដែលមិនត្រេកចិត្ត, មិនគាប់ចិត្ត, មិនពេញចិត្ត, គឺរូបចាស់ទ្រុឌទ្រោមគ្រាំគ្រាទុព្វលភាព, រូបដែលមានអាពាធរោគឈឺចុកចាប់ជាធម្មតា, រូបស្លាប់, រូបវិនាស, រូបថោកទាប, រូបអាក្រក់, រូបជាទុក្ខ, មិនចង់ឲ្យជួបប្រទះនឹងការព្រាត់ប្រាសចាកកាមគុណទាំង៥ មានរូបជាដើម, មិនចង់ឲ្យជួបប្រទះនឹងការវិនាសបែកធ្លាយចាកខន្ធទាំង៥នេះឡើយ, យ៉ាងនេះហៅថា វិភវតណ្ហា ។

តណ្ហាទាំង ៣ នេះប្រកបដោយលោភៈ, ទោសៈ, មោហៈ នឹងទិដ្ឋិទាំងពីរ ។ កាមតណ្ហានឹងភវតណ្ហាទាំងពីរនេះ ប្រកបដោយសស្សតទិដ្ឋិ នឹងលោភៈ ទោសៈ ។ វិភវតណ្ហា ប្រកបដោយឧច្ឆេទទិដ្ឋិ នឹងទោសៈ មោហៈ ។

បញ្ញាឃើញច្បាស់នូវសមុទយសច្ចគឺតណ្ហាទាំង ៣ ប្រការមានកាម-តណ្ហាជាដើមនេះ ថាជាហេតុនាំបណ្ដាលឲ្យកើតនូវកងទុក្ខទាំង ១២ កង មានជាតិទុក្ខជាដើមដូចបានពោលពណ៌នាមកនេះ ព្រះសព្វញ្ញុពុទ្ធទ្រង់ត្រាស់ហៅថាសមុទយៈ ។ សមុទយអរិយសច្ចនេះ គឺជាប្រភពរបស់ជាតិ, ជរា, ព្យាធិ, មរណៈ, សោកៈ, បរិទេវៈ, ទុក្ខៈ, ទោមនស្សៈ នឹងឧបា-យាសៈ ។

រូបរូបសេចក្ដីទាំងអស់ដែលបានអធិប្បាយមកខាងលើនេះ ហៅថា

សមុទយសច្ច ចាត់ជាអរិយសច្ចទី ២ ។

ក្នុងគម្ពីរវិសុទ្ធិមគ្គប្រាប់ថា សមុទយសច្ចនេះ មានអត្ថ ២ យ៉ាងគឺ ៖

១). អាយូហនត្ថ មានអត្ថថា កៀរគរសេចក្ដីទុក្ខឲ្យកើត ;

២). និទានត្ថ មានអត្ថថា នាំយកសេចក្ដីទុក្ខមកប្រគល់ឲ្យដល់ខ្លួន ;

៣). សំយោគត្ថ មានអត្ថថា ញ៉ាំងសត្វឲ្យប្រកបដោយសេចក្ដីទុក្ខក្នុងសង្សារ គឺជាចងសត្វឲ្យជាប់ដោយសំសារទុក្ខ ;

៤). បលិពោធត្ថ មានអត្ថថា ធ្វើឲ្យសត្វកង្វល់រាំងខចិត្តស្ទាក់ស្ទើរដំណើរមិនឲ្យបាននូវមគ្គផល ។

ក្នុងគម្ពីរបដិសម្ភិទាមគ្គប្រាប់ថា សមុទយសច្ចនេះ ចាត់ជាសង្ខតលក្ខណៈ គឺជាសច្ចធម៌មានបច្ច័យប្រជុំតាក់តែងជាលក្ខណៈ ។ សង្ខតលក្ខណៈនេះចែកចេញជា ៣ យ៉ាងគឺ ៖

១). ឧប្បាទ កិរិយាកើតឡើង ហៅថា ឧប្បាទលក្ខណៈ ;

២). វយ កិរិយាសាបសូន្យទៅ ហៅថា វយលក្ខណៈ ;

៣). ឋិតិ កិរិយាតាំងនៅ ហៅថា ឋិតិលក្ខណៈ ;

សមុទយសច្ចនេះចាត់ជាអកុសលសុទ្ធ ព្រោះជាប្រភពជាដែនកើតនៃអកុសលទាំងពួង ។

## លក្ខណៈ កិច្ចនិងផលរបស់សមុទយសច្ច

លក្ខណៈ– បភវលក្ខណំ សមុទយសច្ចមានភាពជាដែនកើតនៃទុក្ខជាលក្ខណៈ ។

កិច្ច– អនុបច្ឆេទករណរសំ សមុទយសច្ចមានកិរិយាមិនធ្វើនូវការដាច់បង់នូវភពជាកិច្ច ។

ផល– បលិពោធបច្ចុបដ្ឋានំ សមុទយសច្ចមានសេចក្ដីកង្វល់តោងជាផល ។

## សេចក្ដីឧបមារបស់សមុទយសច្ចមាន ៣ គឺ:

១). ភារាទានូបមំ សមុទយសច្ចំ(១) សមុទយសច្ចដូចជាការកាន់យកនូវភារៈធ្ងន់ ;

២). រោគនិទានូបមំ សមុទយសច្ចំ សមុទយសច្ចដូចជាហេតុរបស់រោគ ;

៣). ទុព្ភិក្ខ វិយ សមុទយសច្ចំ សមុទយសច្ចដូចជាវេលាគ្មានភ្លៀង ។

## ប្រភេទរបស់សមុទយសច្ច

សមុទយសច្ច បើសំដែងដោយប្រភេទមួយ បានដល់ការដែលញ៉ាំងទុក្ខឲ្យប្រព្រឹត្តទៅ ។ សំដែងដោយប្រភេទពីរ បានដល់ទិដ្ឋិតាំងពីរប្រការគឺ

---

១ ភារាទាន <ភារ + អាទាន, អាទាន បានដល់បដិសន្ធិ ព្រោះលោកធ្វើនូវសេចក្ដីអធិប្បាយជាការកាន់យក អំពីភារៈដើមនូវគ្រឿងធ្ងន់ គឺខន្ធ ។

សស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ ។ សំដែងដោយប្រភេទបី បានដល់តណ្ហាទាំងបីគឺ កាមតណ្ហា, ភវតណ្ហា និងវិភវតណ្ហា ។ សំដែងដោយប្រភេទបួន បានដល់កិច្ចដែលព្រះយោគីត្រូវលះបង់សមុទយសច្ច ដោយមគ្គបួនគឺ សោតាបត្តិមគ្គ, សកទាគាមិមគ្គ, អនាគាមិមគ្គ, អរហត្តមគ្គ ។ សំដែងដោយប្រភេទប្រាំ បានដល់កិរិយាត្រេកអរចំពោះខន្ធទាំងប្រាំមានរូបក្ខន្ធជាដើម ។ សំដែងដោយប្រភេទប្រាំមួយ បានដល់តណ្ហាដែលប្រព្រឹត្តទៅតាមទ្វារប្រាំមួយ មានចក្ខុទ្វារជាដើម ។ សមុទយសច្ចនេះ បើតាំងជាសោឡសកិច្ចវិញជាបហានកិច្ច គឺកិច្ចដែលព្រះយោគីគប្បីលះបង់ ។

៣- និរោធសច្ច សេចក្ដីរលត់ទុក្ខ ឬធម៌សម្រាប់រលត់ទុក្ខ ចាត់ជាអរិយសច្ចទី៣ ។ និរោធសច្ចនេះ ក្នុងសតិបដ្ឋានសូត្រ ព្រះមានព្រះភាគទ្រង់ត្រាស់សំដែងថា:

កតមញ្ច ភិក្ខវេ ទុក្ខនិរោធោ អរិយសច្ចំ = ម្នល ភិក្ខុទាំងឡាយ ដូចម្ដេចហៅថា ទុក្ខនិរោធអរិយសច្ច ?

យោ តស្សាយេវ តណ្ហាយ អសេសវិរាគនិរោធោ ចាគោ បដិនិស្សគ្គោ មុត្តិ អនាលយោ ឥទំ វុច្ចតិ ភិក្ខវេ ទុក្ខនិរោធោ អរិយសច្ចំ = កិរិយារលត់ទៅនៃតណ្ហានោះ មិនមានសេសសល់ ដោយអរិយមគ្គឯណា, កិរិយាលះបង់នូវតណ្ហានោះឯណា,

កិរិយាលះបង់ចេញនូវតណ្ហានោះឯណា, កិរិយារួចនូវតណ្ហានោះឯណា, សេចក្តីមិនអាល័យក្នុងតណ្ហានោះឯណា, ម្នាលភិក្ខុទាំងឡាយ នេះតថាគតឲ្យឈ្មោះថាទុក្ខនិរោធអរិយសច្ច ។

ព្រះមានភាគទ្រង់សំដែងអំពីទីលះបង់នឹងទីរលត់នៃតណ្ហានោះថា :

សា ខោ បនេសា ភិក្ខវេ តណ្ហា កត្ថ បហិយ្យ-មានា បហិយ្យតិ កត្ថ និរុជ្ឈមានា និរុជ្ឈតិ =,

ម្នាលភិក្ខុទាំងឡាយ ចុះតណ្ហានោះឯង កាលដែលបុគ្គលលះបង់ តើលះបង់ក្នុងទីណា ? កាលដែលរលត់ទៅ តើរលត់ទៅក្នុងទីណា ?

យំ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហិយ្យមានា បហិយ្យតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ =.

អារម្មណ៍ណាក្នុងលោក ដែលមានសភាពគួរស្រឡាញ់, មានសភាពគួរត្រេកអរ តណ្ហានោះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងអារម្មណ៍នុ៎ះ, កាលដែលរលត់ទៅ ក៏រលត់ទៅក្នុងអារម្មណ៍នុ៎ះ ។

អារម្មណ៍ដែលមានសភាពគួរស្រឡាញ់, មានសភាពគួរត្រេកអរ នោះគឺ: ចក្ខុ, សោតៈ, ឃានៈ, ជិវ្ហា, កាយ, មនោ ដែលជាទីស្រឡាញ់, ជាទីត្រេកអរ; តណ្ហានោះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងចក្ខុ, សោតៈ, ឃានៈ, ជិវ្ហា, កាយ, មនោ នុ៎ះ, កាលដែលរលត់ទៅក៏រលត់ទៅក្នុងចក្ខុ, សោតៈ, ឃានៈ, ជិវ្ហា, កាយនឹងមនោនុ៎ះ ។

រូបារម្មណ៍, សទ្ទារម្មណ៍, គន្ធារម្មណ៍, រសារម្មណ៍, ផោដ្ឋព្វារម្មណ៍, ធម្មារម្មណ៍ទាំង៦យ៉ាង ដែលជាទីស្រឡាញ់, ជាទីត្រេកអរ; តណ្ហានោះ កាលដែលបុគ្គលលះបង់ក្តី, កាលរលត់ទៅក្តី ក៏តែក្នុងរូបារម្មណ៍ជាដើមនុ៎ះឯង ។

ចក្ខុវិញ្ញាណ, សោតវិញ្ញាណ, ឃានវិញ្ញាណ, ជិវ្ហាវិញ្ញាណ, កាយវិញ្ញាណ, មនោវិញ្ញាណ ដែលជាទីស្រឡាញ់, ជាទីត្រេកអរ; តណ្ហានោះ កាលដែលបុគ្គលលះបង់ក្តី, កាលរលត់ទៅក្តី ក៏តែក្នុងចក្ខុវិញ្ញាណជាដើមនុ៎ះឯង ។

ចក្ខុសម្ផស្ស, សោតសម្ផស្ស, ឃានសម្ផស្ស:, ជិវ្ហាសម្ផស្ស, កាយសម្ផស្ស, មនោសម្ផស្ស ដែលជាទីស្រឡាញ់, ជាទីត្រេកអរ; តណ្ហានោះ កាលដែលបុគ្គលលះបង់ក្តី, កាលរលត់ទៅក្តី ក៏តែក្នុងចក្ខុសម្ផស្សជាដើមនុ៎ះឯង ។

វេទនាដែលកើតអំពីចក្ខុសម្ផស្ស, អំពីសោតសម្ផស្ស, អំពីឃានសម្ផស្ស, អំពីជិវ្ហាសម្ផស្ស, អំពីកាយសម្ផស្ស, អំពីមនោសម្ផស្សដែលជាទីស្រឡាញ់, ជាទីត្រេកអរ; តណ្ហានោះ កាលដែលបុគ្គលលះបង់ក្តី, កាលរលត់ទៅក្តី ក៏តែក្នុងវេទនាដែលកើតអំពីចក្ខុសម្ផស្សជាដើមនុ៎ះឯង ។

សេចក្តីសំគាល់នូវរូបារម្មណ៍, នូវសទ្ទារម្មណ៍, នូវគន្ធារម្មណ៍, នូវរសារម្មណ៍, នូវផោដ្ឋព្វារម្មណ៍, នូវធម្មារម្មណ៍ ដែលជាទីស្រឡាញ់, ជាទី

ត្រេកអរ; តណ្ហានោះ កាលបុគ្គលលះបង់ក្តី កាលរលត់ទៅក្តី ក៏តែក្នុងសេចក្តីសំគាល់នូវរូបារម្មណ៍ ជាដើមនុ៎ះឯង ។

ការសន្សំនូវរូបារម្មណ៍, នូវសទ្ទារម្មណ៍, នូវគន្ធារម្មណ៍, នូវរសា-រម្មណ៍, នូវផោដ្ឋព្វារម្មណ៍, នូវធម្មារម្មណ៍ ដែលជាទីស្រឡាញ់, ជាទីត្រេកអរ; តណ្ហានោះ កាលបុគ្គលលះបង់ក្តី, កាលរលត់ទៅក្តី ក៏តែក្នុងការសន្សំនូវរូបារម្មណ៍ ជាដើមនុ៎ះឯង ។

សេចក្តីចំណង់ក្នុងរូបារម្ម, ក្នុងសទ្ទារម្មណ៍, ក្នុងគន្ធារម្មណ៍, ក្នុងរសារម្មណ៍, ក្នុងផោដ្ឋព្វារម្មណ៍, ក្នុងធម្មារម្មណ៍ ដែលជាទីស្រឡាញ់, ជាទីត្រេកអរ; តណ្ហានោះ កាលដែលបុគ្គលលះបង់ក្តី, កាលរលត់ទៅក្តី ក៏តែក្នុងសេចក្តីចំណង់ក្នុងរូបារម្មណ៍ ជាដើមនុ៎ះឯង ។

សេចក្តីត្រិះរិះនូវរូបារម្មណ៍, នូវសទ្ទារម្មណ៍, នូវគន្ធារម្មណ៍, នូវរសារម្មណ៍, នូវផោដ្ឋព្វារម្មណ៍, នូវធម្មារម្មណ៍ ដែលជាទីស្រឡាញ់, ជាទីត្រេកអរ; តណ្ហានោះ កាលដែលបុគ្គលលះបង់ក្តី, កាលរលត់ទៅក្តី ក៏តែក្នុងសេចក្តីត្រិះរិះនូវរូបារម្មណ៍ ជាដើមនុ៎ះឯង ។

ការពិចារណានូវរូបារម្មណ៍, នូវសទ្ទារម្មណ៍, នូវគន្ធារម្មណ៍, នូវរសារម្មណ៍, នូវផោដ្ឋព្វារម្មណ៍, នូវធម្មារម្មណ៍ ដែលជាទីស្រឡាញ់, ជាទីត្រេកអរ; តណ្ហានោះឯង កាលដែលបុគ្គលលះបង់ក្តី, កាលរលត់ទៅក្តី ក៏តែក្នុងការពិចារណានូវរូបារម្មណ៍ ជាដើមនុ៎ះឯង ។

ឯបុគ្គលដែលលះបង់នូវតណ្ហានោះ ហើយធ្វើនូវតណ្ហានោះឲ្យរលត់ទៅក្នុងទីនោះ ៗ បាន ដោយអំណាចនៃមគ្គញ្ញាណ គឺបញ្ញាដែលត្រាស់ដឹងនូវមគ្គទាំង ៤ មានសោតាបត្តិមគ្គជាដើម ។

បុគ្គលដែលមានបញ្ញា អាចត្រាស់ដឹងនូវមគ្គទាំង ៤ នោះបាន ហៅថា អរិយបុគ្គល គឺបុគ្គលដ៏ប្រសើរ, បុគ្គលត្រឹមត្រូវ, បុគ្គលមានសភាពកបសារ, បុគ្គលរៀបរយល្អ និងជាបុគ្គលតាំងនៅក្នុងអរិយធម៌ជានិច្ច ។ បុគ្គលទាំង ៤ ពួកនោះ គឺសោតាបន្នបុគ្គល ១, សកទាគាមីបុគ្គល ១, អនាគាមីបុគ្គល ១, អរហាបុគ្គល ១ ។

សោតាបន្នបុគ្គល បានដល់បុគ្គលដែលលះបង់បាននូវសំយោជនៈធម៌ ៣ គឺ:

១)- សក្កាយទិដ្ឋិ សេចក្តីប្រកាន់តាមគំនិតយល់ឃើញថារូបកាយជារបស់ខ្លួន ;

២)- វិចិកិច្ឆា សេចក្តីសង្ស័យមិនដាច់ស្រេច ;

៣)- សីលព្វតបរាមាសៈ ការបោះបោសអង្អែលប្រកាន់សីលវត្តរបស់ខ្លួនថាប្រសើរវិសេស ។

សោតាបន្នបុគ្គលនោះ ចែកចេញជា ៣ ពួកគឺ :

១). ឯកពីជី លោកដែលមានពូជគឺភពតែមួយគឺនៅកើតក្នុងភពមនុស្សលោកតែមួយជាតិទៀត ;

២). កោលំកោលៈ លោកដែលចេញពីត្រកូលមួយទៅកាន់ត្រកូលមួយទៀត គឺនៅកើត ២ ជាតិ ឬ ៣ ជាតិទៀត ទើបធ្វើឲ្យជាក់ច្បាស់នូវអរហត្តផលបាន ;

៣). សត្តក្ខត្តុបរមៈ លោកដែលត្រាច់រង្គាត់ទៅកើតក្នុងមនុស្សលោកនឹងទេវលោក យ៉ាងច្រើនបំផុតត្រឹម ៧ ជាតិទៀត ទើបបានធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល ។

សោតាបន្នបុគ្គលទាំងនេះតែងពិចារណានូវបច្ចវេក្ខណកិច្ច ៥ យ៉ាងគឺ:

១). មគ្គំ បច្ចវេក្ខតិ ពិចារណានូវមគ្គ ;

២). ផលំ បច្ចវេក្ខតិ ពិចារណានូវផល ;

៣). បហីនកិលេសេ បច្ចវេក្ខតិ ពិចារណានូវកិលេសដែលខ្លួនលះបានហើយ ;

៤). អវសិដ្ឋកិលេសេ បច្ចវេក្ខតិ ពិចារណានូវកិលេសដែលសល់នៅឡើយ ;

៥). និព្វានំ បច្ចវេក្ខតិ ពិចារណានូវព្រះនិព្វាន ។

សកទាគាមី[១] បុគ្គល លោកលះបង់បាននូវសំយោជនធម៌ ជាចំណែកនៃកាមធាតុទាំង ៥ គឺ: សក្កាយទិដ្ឋិ ១, វិចិកិច្ឆា ១, សីលព្វតបរាមាសៈ ១ ទាំង ៣ នេះលះបានជ្រះស្រឡះ, កាមរាគៈ សេចក្ដីត្រេក

១ សកិទាគាមី ក៏ហៅបាន ។

ក្រោលក្ខណ៍តាមគណ្ហា ១, បដិឃៈ សេចក្តីចង់ចាក់ក្តៅក្រហាយចិត្តប្រកប
ដោយទោមនស្ស ១ តាំងពីនេះគ្រាន់តែបានស្រាលស្តើង ៗ

សកទាគាមីបុគ្គលនេះ មាន ៥ ពួកគឺ:

១). ឥធ បត្តា ឥធ បរិនិព្វាយី លោកដែលបានសម្រេចសកទាគាមិផលក្នុងមនុស្សលោកនេះ ហើយចំរើនវិបស្សនាបានសម្រេចអរហត្តផល បរិនិព្វានក្នុងមនុស្សលោកនេះ ;

២). តត្ថ បត្តា តត្ថ បរិនិព្វាយី លោកដែលបានសម្រេចសកទាគាមិផលក្នុងស្ថានទេវលោក ហើយចំរើនវិបស្សនាបានសម្រេចអរហត្តផល បរិនិព្វានក្នុងទេវលោកនោះ ;

៣). ឥធ បត្តា តត្ថ បរិនិព្វាយី លោកដែលបានសម្រេចសកទាគាមិផលក្នុងមនុស្សលោកនេះ ហើយច្យុតទៅកើតក្នុងឋានៈទេវលោក ចំរើនវិបស្សនាបានសម្រេចអរហត្តផល បរិនិព្វានក្នុងស្ថានទេវលោកនោះតែម្តង ;

៤). តត្ថ បត្តា ឥធ បរិនិព្វាយី លោកដែលបានសម្រេចសកទាគាមិផលក្នុងឋានទេវលោក ហើយច្យុតចុះមកកើតក្នុងស្ថានមនុស្សលោក ចំរើនវិបស្សនាបានសម្រេចអរហត្តផល បរិនិព្វានក្នុងស្ថានមនុស្សលោកនេះ ;

៥). ឥធ បត្តា តត្ថ គន្ត្វា ឥធ បរិនិព្វាយី លោកដែលបាន

សម្រេចសកទាគាមិផល ក្នុងឋានមនុស្សលោកនេះ ហើយច្យុតទៅកើតឯឋានទេវលោក លុះអស់អាយុក៏ច្យុតចុះមកកើតក្នុងឋានមនុស្សលោកវិញ ចំរើនវិបស្សនាបានសម្រេចអរហត្តផល បរិនិព្វានក្នុងមនុស្សលោកនេះ ។

សកទាគាមិបុគ្គលនេះលោកតែងពិចារណានូវបច្ចវេក្ខណកិច្ច៥យ៉ាង ដូចជាសោតាបន្នបុគ្គលដែរ ។

អនាគាមិបុគ្គល លោកលះបង់នូវសំយោជនៈដាច់ចំណែកនៃកាមគុណទាំង៥ដាច់ស្រឡះ គឺសក្កាយទិដ្ឋិ១, វិចិកិច្ឆា១, សីលព្វតបរា-មាសៈ១, កាមរាគៈ១, បដិឃៈ១ ។

អនាគាមិបុគ្គលនេះចែកជា ៥ ពួកគឺ:

១)- អន្តរាបរិនិព្វាយី លោកលះកិលេសក្នុងចន្លោះ គឺលោកដែលកើតក្នុងសុទ្ធាវាសព្រហ្មហើយ នៅមិនទាន់ដល់ពាក់កណ្ដាលអាយុក៏ញុំាងអរហត្តមគ្គឲ្យកើតឡើង លះសំយោជនៈខាងលើបាន ;

២)- ឧបហច្ចបរិនិព្វាយី លោកដែលកន្លងពីចន្លោះនោះបន្តិចទៅទៀត គឺលោកដែលមានអាយុជាងពាក់កណ្ដាលឡើងទៅ ដល់ពេលជិតអស់អាយុ ទើបញុំាងអរហត្តមគ្គឲ្យកើតឡើងបាន ;

៣)- អសង្ខារបរិនិព្វាយី លោកដែលបរិនិព្វានដោយមិនមានសង្ខារគឺញុំាងអរហត្តមគ្គឲ្យកើតឡើង លះសំយោជនៈ ៥ ខាងលើបានដោយងាយមិនបាច់ព្យាយាមតឹងតែងពេក ;

៤)- សសង្ខារបរិនិព្វាយី លោកដែលរំលត់កិលេសដោយសសង្ខារ គឺញុំាងអរហត្តមគ្គឲ្យកើតឡើងដោយលំបាក លុះតែប្រកបដោយព្យា-យាមតឹងតែង ទើបញុំាងអរហត្តមគ្គឲ្យកើតឡើងបាន ;

៥)- ឧទ្ធំសោតអកនិដ្ឋគាមី លោកដែលមានខ្សែខាងលើទៅកាន់ភពអកនិដ្ឋ គឺច្យុតចាកព្រហ្មលោកឈ្មោះអវិហា ទៅកាន់ព្រហ្មលោកឈ្មោះអតប្បា, ច្យុតចាកព្រហ្មលោកឈ្មោះអតប្បា ទៅកាន់ព្រហ្មលោកឈ្មោះសុទស្សា, ច្យុតចាកព្រហ្មលោកឈ្មោះសុទស្សា ទៅកាន់ព្រហ្ម-លោកឈ្មោះសុទស្សី, ច្យុតចាកព្រហ្មលោកឈ្មោះសុទស្សី ទៅកាន់ព្រហ្មលោកឈ្មោះអកនិដ្ឋ ទើបញុំាងអរហត្តមគ្គឲ្យកើតឡើងបាន ។

អនាគាមិបុគ្គលនេះ លោកតែងពិចារណានូវបច្ចវេក្ខណកិច្ច ៥ យ៉ាង ដូចជាសោតាបន្នបុគ្គលដែរ ។

អរហន្តបុគ្គល លោកលះបង់បាននូវសំយោជនៈទាំង ១០ ទាំងជាប៉ែកនៃកាមធាតុ ៥ និងជារូបារូបធាតុ ៥ គឺរូបរាគៈ សេចក្តីត្រេកត្រអាលក្នុងរូបឈាន ១, អរូបរាគៈ សេចក្តីត្រេកត្រអាលក្នុងអរូបឈាន ១, មានៈ សេចក្តីប្រកាន់ខ្លួន ១, ឧទ្ធច្ចៈ សេចក្តីរាយមាយរវើរវាយចិត្ត ១, អវិជ្ជា សេចក្តីល្ងង់ខ្លៅ ១ ។

អរហន្តបុគ្គលចែកចេញជា ៤ ពួកគឺ៖

(១)- សុក្ខវិបស្សកោ លោកអ្នកមានវិបស្សនាដ៏រីងស្ងួត ព្រោះមិនមានឈាន គឺសមថភាវនា បានចំរើនវិបស្សនាលុះដល់អរហត្ត មិនប្រកបដោយបុទ្ធិវិសេសណាមួយឡើយ ;

(២)- តេវិជ្ជោ លោកដែលបានសម្រេចវិជ្ជា ៣ ;

(៣)- ឆឡភិញ្ញោ លោកដែលបានសម្រេចអភិញ្ញា ៦ ;

(៤)- បដិសម្ភិទប្បត្តោ លោកដែលបានសម្រេចនូវបដិសម្ភិទា ៤ ។

អរហាបុគ្គលនេះ លោកតែងពិចារណានូវបច្ចវេក្ខណកិច្ច ៤ យ៉ាងគឺ៖

(១)- មគ្គ បច្ចវេក្ខណ ពិចារណានូវមគ្គដោយន័យថា អាត្មាអញមកតាមផ្លូវណា ;

(២)- ផល បច្ចវេក្ខណ ពិចារណានូវផលថាជាអានិសង្សដែលអាត្មាអញត្រូវបាន ។

(៣)- បហីនកិលេស បច្ចវេក្ខណ ពិចារណានូវកិលេសដែលខ្លួនបានលះបង់ហើយថា កិលេសទាំងឡាយនេះអាត្មាអញលះបង់បានហើយ ;

(៤)- និព្វាន បច្ចវេក្ខណ ពិចារណានូវព្រះនិព្វានថា ធម៌នេះហើយដែលជាអារម្មណ៍គួរត្រាស់ដឹង ។

ព្រះអរិយបុគ្គលទាំងនេះ លោកកំចាត់បង់នូវតណ្ហាមិនឲ្យមានសេស

សល់ដោយអរហត្តមគ្គញាណ គឺដោយបញ្ញាដែលត្រាស់ដឹងនូវអរហត្ត-មគ្គរបស់លោក ។ ក៏យានចុះស៊ប់ទៅក្នុងព្រះនិព្វាន សោយនូវសេចក្តីសុខដ៏ក្រៃលែងជាងសុខទាំងពួងដែលហៅថា ឯកន្តបរមសុខ ព្រោះព្រះនិព្វានជាស្ថានសម្រាប់រលត់បង់នូវកងទុក្ខទាំងពួង ។

ព្រះនិព្វាននោះមានគុណច្រើនយ៉ាងគឺ វិរាគោ សភាវៈប្រាសចាកតម្រេកក្នុងកាមទាំងពួង, និរោធោ សភាវៈរលត់បង់នូវកងទុក្ខ, ចាគោ សភាវៈលះបង់នូវតណ្ហា, បដិនិស្សគ្គោ សភាវៈត្រូវតែបោលនូវតណ្ហា, មុត្តិ ផុតស្រឡះចាកអាល័យ, អនាលយោ មិនមានអាល័យក្នុងកាមគុណ៥, រាគក្ខយោ ជាទីអស់ទៅនៃរាគៈ, ទោសក្ខ-យោ ជាទីអស់ទៅនៃទោសៈ, មោហក្ខយោ ជាទីអស់ទៅនៃមោហៈ, តណ្ហក្ខយោ ជាទីអស់ទៅនៃតណ្ហា, អនុប្បាទោ មិនកើតទៀត, អប្បវត្តំ មិនប្រព្រឹត្តទៅ, អនិមិត្តំ មិនមាននិមិត្ត, អប្បណិហិតំ មិនមានទីដំកល់នូវបណិធិ, អប្បដិសន្ធិ មិនមានបដិសន្ធិ, អប្បវ-វត្តំ មិនត្រឡប់មកវិញ. អគតិ មិនមានដំណើរពីភព១ ទៅ ១, អជាតំ មិនមានជាតិ, អជរំ មិនមានជរា, អព្យាធិ មិនមានជម្ងឺគាត់, អមតំ មិនចេះស្លាប់, អសោកំ មិនមានសេចក្តីសោក, អបរិទេវំ មិនមានសេចក្តីខ្សឹកខ្សួល, អនុបាយាសំ មិនមានការស្អួលអាក់ក្នុងចិត្ត, អសំកិលិដ្ឋំ មិនមានសេចក្តីសៅហ្មង ព្រោះជាដើមចាត់ជាគុណរបស់

ព្រះនិព្វានទាំងអស់ ។

និរោធអរិយសច្ចនេះ មានអត្ថ ៤ យ៉ាងគឺ៖

(១)- និស្សរណដ្ឋោ មានអត្ថថារលាស់ចោលនូវបណ្ដាធម៌ដែល សម្រាប់ឲ្យសេចក្ដីទុក្ខចូលទៅអែបនៃបានទៅ ;

(២)- វិវេកដ្ឋោ មានអត្ថថាស្ងប់ស្ងាត់ចាកសង្ខារទាំងពួង ;

(៣)- អសង្ខតដ្ឋោ មានអត្ថថាមិនមានធម៌ជាបច្ច័យប្រជុំតាក់តែង ឲ្យកើតទៀត ;

(៤)- អមតដ្ឋោ មានអត្ថថាមិនចេះស្លាប់ ព្រោះជាធម៌ទៀង ។

ក្នុងគម្ពីរបដិសម្ភិទាមគ្គប្រាប់ថា និរោធសច្ចនេះ តាក់ជាអសង្ខតលក្ខណៈ គឺសច្ចធម៌មិនមានបច្ច័យប្រជុំតាក់តែងជាលក្ខណៈ ។

អសង្ខតលក្ខណៈនេះចែកចេញជា ៣ យ៉ាងគឺ៖

(១)- អនុប្បាទោ មិនមានកិរិយាកើតឡើង ហៅថា អនុប្បាទលក្ខណៈ ;

(២)- អនវយោ មិនមានកិរិយាសាបសូន្យទៅ ហៅថា អនវយលក្ខណៈ ;

(៣)- អនដ្ឋិតិ មិនមានកិរិយាតាំងនៅ ហៅថា អនដ្ឋិតិលក្ខណៈ ។

ម្យ៉ាងទៀត និរោធសច្ចនេះ តាក់ជាអព្យាកតធម៌ ព្រោះមិនមាន បច្ច័យតាក់តែងនូវកុសលនិងអកុសលទាំងពួង ។

### លក្ខណៈ កិច្ចនិងផលរបស់និរោធសច្ច

លក្ខណៈ=សន្តិលក្ខណំ និរោធសច្ចមានកិរិយាស្ងប់រម្ងាប់ជាលក្ខណៈ ។

កិច្ច– អច្ចុតរសំ និរោធសច្ចមានកិរិយាមិនច្យុតជាកិច្ច ។

ផល– អនិមិត្តប្បច្ចុប្បដ្ឋានំ និរោធសច្ចមានកិរិយាមិនមាននិមិត្តជាផល ។

សេចក្ដីឧបមារបស់និរោធសច្ចមាន ៣ យ៉ាងគឺ ៖

(១)– ភារនិក្ខេបនមិវ និរោធសច្ចំ និរោធសច្ចឧបមាដូចជាកិរិយាដាក់ចុះនូវភារៈធ្ងន់ចេញអំពីស្មា ;

(២)– រោគវូបសមោ វិយ និរោធសច្ចំ និរោធសច្ចដូចជាកិរិយាសះស្បើយទៅនៃរោគ ;

(៣)– សុភិក្ខមិវ និរោធសច្ចំ និរោធសច្ចដូចជាស្រុកដែលសម្បូរទៅដោយអាហារ ។

### ប្រភេទរបស់និរោធសច្ច

និរោធសច្ច បើសំដែងដោយប្រភេទមួយ បានដល់អសង្ខតធាតុ ។ សំដែងដោយប្រភេទពីរ បានដល់សឧបាទិសេសនិព្វាន១, អនុបាទិសេសនិព្វាន១ ។ សំដែងដោយប្រភេទបី បានដល់ការរំលត់នូវភព ៣ មានកាមភពជាដើម ។ សំដែងដោយប្រភេទបួន បានដល់ការព្រាស់ដ៏នូវមគ្គ ៤ មានសោតាបត្តិមគ្គជាដើម ។ សំដែងដោយប្រភេទប្រាំ បានដល់ការរំលត់នូវសេចក្ដីត្រេកអរក្នុងខន្ធ ៥ ។ សំដែងដោយប្រភេទ ៦ បានដល់កា

រំលត់ខ្សែតណ្ហាដែលប្រព្រឹត្តទៅក្នុងទ្វារទាំង ៦ ។ បើចាត់ជាសោឡសកិច្ច វិញ និរោធសច្ចនេះ ជាសច្ឆិកាតព្វកិច្ច គឺកិច្ចដែលព្រះយោគាវចរគប្បីធ្វើឲ្យជាក់ច្បាស់ ។

៤)– មគ្គសច្ចៈ ផ្លូវឬឧបាយនៃសេចក្ដីរលត់ទុក្ខ បានដល់មគ្គដែលប្រកបដោយអង្គទាំង ៨ ប្រការមានសម្មាទិដ្ឋិជាដើម ។

ក្នុងមគ្គសច្ចទី ៤ នេះ ពុំបានអធិប្បាយក្នុងទីនេះទេ ព្រោះក្នុងផ្នែកសៀវភៅនេះមានការអធិប្បាយនៃអំពីអង្គមគ្គទាំង ៨ ប្រការនោះប៉ុណ្ណោះ, សូមជ្រាបតាមអង្គមគ្គនោះ ១ ចុះ ។

ការយល់ត្រូវក្នុងរបស់ពិត គឺអរិយសច្ចទាំង ៤ យ៉ាង ដូចបានអធិប្បាយមកប៉ុណ្ណោះជាដើមហៅថា "សម្មាទិដ្ឋិ" ចាត់ជាអង្គមគ្គទី ១ ។

លក្ខណៈ កិច្ចនិងផលរបស់សម្មាទិដ្ឋិ

លក្ខណៈ– សម្មាទស្សនលក្ខណា សម្មាទិដ្ឋិមានកិរិយាឃើញនូវអរិយសច្ច ៤ ជាលក្ខណៈ ។

កិច្ច– បប្បកាសនរសា សម្មាទិដ្ឋិមានកិរិយាប្រកាសនូវសេចក្ដីពិតជាកិច្ច ។

ផល– អវិជ្ជន្ធការវិទ្ធំសនបច្ចុបដ្ឋានា សម្មាទិដ្ឋិមានកិរិយាកំចាត់បង់នូវងងឹត គឺអវិជ្ជាជាផល ។

សម្មាទិដ្ឋិនេះ បើចាត់ជាកម្មហៅថា មនោកម្ម ព្រោះជាអំពើត្រូវធ្វើ

ដោយផ្លូវចិត្ត ។ បើតាំងជាឋាន ហៅថាបញ្ញាឋាន ។ បើតាំងជាខន្ធ ហៅថាបញ្ញាខន្ធ ។ សង្គ្រោះចូលក្នុងអភិធម្មបិដក ។

## អធិប្បាយអង្គមគ្គទី ២

សម្មាសង្កប្ប ការត្រិះរិះត្រូវមាន ៣ យ៉ាងគឺ:

១– នេក្ខម្មសង្កប្ប ត្រិះរិះដើម្បីចេញចាកកាម;

២– អព្យាបាទសង្កប្ប ត្រិះរិះដើម្បីមិនព្យាបាទ;

៣– អវិហឹសាសង្កប្ប ត្រិះរិះដើម្បីមិនបៀតបៀនសត្វដទៃ ។ ការត្រិះរិះត្រូវតាំង ៣ យ៉ាងនេះ ហៅថា “សម្មាសង្កប្ប” ។

### សេចក្តីអធិប្បាយ

នេក្ខម្មសង្កប្ប ការត្រិះរិះដើម្បីចេញចាកកាមគឺត្រូវត្រិះរិះពិចារណា ឲ្យឃើញច្បាស់ ថា រូប, សំឡេង, ក្លិន, រស, សម្ផស្ស នេះជារបស់ តែងវិនាស, ជារបស់សោះសូន្យ, ជារបស់មិនស្អាត, ជារបស់បដិកូល គួរខ្ពើមរអើមក្រៃពេក ៖ សក់, រោម, ក្រចក, ធ្មេញ, ស្បែក ក៏សុទ្ធតែ ជាគ្រឿងបដិកូល គួរខ្ពើមរអើម, ត្រិះរិះពិចារណាឲ្យឃើញច្បាស់ថាជា របស់បដិកូលពិត, កាលបើឃើញច្បាស់ថាជាបដិកូលពិតហើយគួរចំរើន នូវបដិកូលសញ្ញានោះ កំណត់ទុកក្នុងចិត្តឲ្យរឿយ ៗ ហើយកាន់យកនូវ សញ្ញាដែលសំគាល់ថាបដិកូល ១ នោះមកជាអារម្មណ៍ លុះសញ្ញាជាប់

នៅក្នុងអារម្មណ៍ជាបដិកូលនោះហើយ ចិត្តក៏ប្រាសចាកតម្រេក មិនត្រេកអរនឹងរូប, មិនត្រេកអរនឹងសំឡេង, មិនត្រេកអរនឹងក្លិន, មិនត្រេកអរនឹងរស, មិនត្រេកអរនឹងផ្សព្វផ្សាយ, មិនត្រេកអរនឹងធម្មារម្មណ៍ដែលកើតក្នុងចិត្ត, ព្រោះពិចារណាឃើញទោសក្នុងកាមគុណទាំង ៥ ថាជារបស់វិនាស, ជារបស់សោះសូន្យ, ជារបស់ពុកផុយ, ជារបស់ក្តៅ, ជារបស់ឥតប្រយោជន៍, ជារបស់មិនទៀង, ជារបស់ទុក្ខ, ជារបស់មិនមែនជារបស់ខ្លួន; លុះត្រារិះពិចារណាឃើញទុក្ខទោសរបស់កាមគុណទាំង ៥ យ៉ាងនេះហើយ ចិត្តក៏មិនត្រេកអរពេញយកក្នុងកាមទាំងឡាយមានរូបជាដើម ត្រឡប់ជានឿយណាយខ្ពើមរអើម ដូច្នេះឈ្មោះថាចិត្តចេញចាកកាម ។

អព្យាបាទសង្កប្បៈ គឺការរិះរកដើម្បីមិនព្យាបាទនោះ គឺពិចារណាឲ្យឃើញទោសក្នុងការព្យាបាទ ថាព្យាបាទនេះ មានទុក្ខទោសច្រើនយ៉ាងជាអនេកតេកណាស់ គឺជាហេតុនាំឲ្យវិនាសខ្លួនក្នុងបច្ចុប្បន្ននេះក៏មាន, នាំឲ្យវិនាសខ្លួននៅក្នុងលោកខាងមុខក៏មាន; សេចក្តីវិនាសក្នុងបច្ចុប្បន្ននេះ គឺធ្វើចិត្តឲ្យក្តៅក្រហាយដូចជាភ្លើងឆេះគល់ជានិច្ចកាល ហើយរកឧបាយកលនឹងធ្វើគេឲ្យវិនាសជីវិតក៏មាន, ធ្វើគេឲ្យវិនាសទ្រព្យសម្បត្តិក៏មាន, កាលបើព្យាបាទគេឲ្យវិនាសយ៉ាងនេះហើយ សេចក្តីវិនាសនោះមុខជានឹងត្រឡប់ស្រោចមកលើខ្លួនវិញជាពុំខានឡើយ ។ ព្រោះអំពើដែលធ្វើ

អាក្រក់ក្រៅបានផលអាក្រក់, អំពើដែលធ្វើល្អក្រៅបានផលល្អ, កាលបើក្រិះរិះឃើញទោសរបស់ព្យាបាទដូច្នេះហើយ ក៏ចំរើនធម៌មេត្តាចំពោះចិត្តព្យាបាទថា ចិត្តព្យាបាទនេះ ជាចិត្តល្ងង់ខ្លៅ, ជាចិត្តក្តៅក្រពេកណាស់ ធ្វើខ្លួនឯងឲ្យលន់លិចទៅនៅក្នុងគ្រោះជ្រៅគឺ នរក, តិរច្ឆាន, ប្រេត, អសុរកាយ ។ ចំរើនធម៌មេត្តាគឺចិត្តត្រជាក់ដូចជាទឹក សំរាប់លត់នូវចិត្តក្តៅ គឺចិត្តព្យាបាទ, មេត្តាចិត្តកើតឡើងមាននូវសេចក្តីករុណា ការសួរដល់ចិត្តព្យាបាទថា ចិត្តព្យាបាទនេះ ជាចិត្តល្ងង់ខ្លៅក្តៅនាំក្រពេក ព្រោះតែបន្តបានឲ្យដូចចិត្តរបស់ខ្លួន បើមិនបានដូចចិត្តទេ ឬមិនត្រូវចិត្តទេ ចិត្តនោះក៏កើតទំនងចង់ព្យាបាទធ្វើឲ្យគេវិនាសបាត់ជីវិត, បាត់ទ្រព្យសម្បត្តិ ព្រោះតែគេមិនធ្វើឲ្យដូចចិត្តខ្លួន, ឲ្យត្រូវនឹងចិត្តរបស់ខ្លួន ; ក្រិះរិះពិចារណាឲ្យឃើញច្បាស់ថារបស់ទាំងអស់ក្នុងលោកនេះតាំងអំពីរូប, សំឡេង, ក្លិន, រស, ផ្សព្វផ្សាយទាំងអស់ ធ្វើឲ្យដូចចិត្តរបស់ខ្លួនមិនបានទេ , សូម្បីតែចិត្តរបស់ខ្លួនឯងក៏ធ្វើឲ្យដូចចិត្តរបស់ខ្លួន មិនបានផង ។ ក្រិះរិះឲ្យឃើញច្បាស់ក្នុងទោសរបស់ព្យាបាទដូច្នេះហើយ ចិត្តក៏ព្រាងើយការក្តីយកក្នុងសត្វនិងសង្ខារ ប្រកបដោយធម៌មេត្តា ដូច្នេះឈ្មោះថា ក្រិះរិះដើម្បីមិនព្យាបាទ ។

អវិហឹសាសង្កប្បោ ក្រិះរិះដើម្បីមិនបៀតបៀន គឺក្រិះរិះដើម្បីមិនបៀតបៀនប្រទូសរ៉ាយដល់សត្វនិងសង្ខារ មានវាយដំកាប់ចាក់សម្លាប់សត្វ

គួបរំ:ជាដើម ដោយឥតមានមេត្តាត្រាប្រណីអាណិតអាសូរដល់សត្វសត្វ ទៀត ។ ត្រិះរិះពិចារណាឲ្យឃើញច្បាស់ថា ចិត្តដែលបៀតបៀនប្រទូស ត៍យដល់សត្វនិងសង្ខារនេះ ជាចិត្តអកុសលសុទ្ធ, ជាចិត្តនាំខ្លួនឲ្យវិនាស ទៅនៅក្នុងអបាយភូមិទាំង ៤, កាលបើពិចារណាឃើញទោសក្នុងការបៀត បៀនគេដូច្នេះហើយ ចិត្តក៏លែងត្រិះរិះគេការបៀតបៀនសត្វនិងសង្ខារ ត្រឡប់ជាមានចិត្តករុណាអាណិតអាសូរដល់សត្វនិងសង្ខារវិញ ។ ដូច្នេះ ឈ្មោះថាចិត្តត្រិះរិះគេចចេញចាកការបៀតបៀន ។

សម្មាសង្កប្បនេះ មិនមែនគ្រាន់តែត្រិះរិះចេញចាកអកុសលវិតក្កៈ ៣ យ៉ាង មានកាមវិតក្កៈជាដើមប៉ុណ្ណោះទេ គឺត្រិះរិះចេញចាកខន្ធ ៥ មាន រូបក្ខន្ធជាដើមផង, ត្រិះរិះចេញចាកភព ៣ មានកាមភពជាដើមផង ។

អធិប្បាយថា : ត្រិះរិះចេញចាកខន្ធ ៥ នោះគឺ ត្រិះរិះពិចារណា ឃើញទោសទុក្ខរបស់ខន្ធទាំង ៥ គឺ រូប, វេទនា, សញ្ញា, សង្ខារ, វិញ្ញា-ណ ទាំង ៥ នេះ ជាជាតិនាំកើតទុក្ខ, កើតកិលេស ដុតឲ្យក្ដៅក្រហល់ក្រហាយ ដោយសេចក្ដីចាស់គ្រាំគ្រា, ដោយសេចក្ដីឈឺចុកចាប់អាពាធ កើតជាទិច្ចកាល, ដោយសេចក្ដីស្លាប់, ដោយសេចក្ដីសោកខ្សឹកខ្សួល; ត្រិះរិះពិចារណាឲ្យឃើញច្បាស់ថា : រូបក្ខន្ធនេះ ជាដី, ទឹក, ភ្លើង, ខ្យល់; កាលដែលកើតឡើងនោះក៏មិនដឹងដល់គ្នានឹងគ្នា, ដល់ចាស់ក៏មិនដឹងដល់គ្នានឹងគ្នា, ដល់ឈឺ-ស្លាប់ទៀតក៏មិនដឹងដល់គ្នានឹងគ្នាដែរ ។ ដូចយ៉ាង

សក់, រោម, ក្រចក, ធ្មេញ, ស្បែក ទាំងអស់នេះកើតនៅជាមួយគ្នាក៏ពិតមែន ប៉ុន្តែមិនអាចដឹងដល់គ្នាទៅវិញទៅមកទេ ដូចយ៉ាងពួករូប ២៨ នេះសុទ្ធតែមិនដឹងដល់គ្នានឹងគ្នាទាំងអស់ ។ បានជាឈ្មោះថាភ្លើងទុក្ខ ព្រោះជាខន្ធទាំង ៥ នេះលុះនៅក្នុងអំណាចជាតិ, ជរា, ព្យាធិ និងមរណៈ តែងដុតបំពាក់សត្វក្នុងត្រៃភពឲ្យក្តៅក្រហាយដូចជាភ្លើងឆេះគល់, សត្វទាំងឡាយអត់ទ្រាំបានដោយលំបាកក្រៃពេក ។ ភ្លើងកិលេសនោះបានដល់រាគៈ, ទោសៈ, មោហៈ អកុសលធម៌ទាំងអស់នេះ បានជាលោកហៅថា ភ្លើងកិលេស ព្រោះតែធ្វើចិត្តរបស់សត្វឲ្យក្តៅក្រហល់ក្រហាយ ដូចជាភ្លើងឆេះព្រៃចំសន្ធោសន្ធៅឆាបព្រាលឡើង ក្តៅឥតឧបមានឹងប្រៀបបាន ។ សត្វទាំងឡាយ កាលបើត្រូវភ្លើងគឺកិលេសទាំង ៣ យ៉ាងនេះឆេះនៅក្នុងសន្តានចិត្តហើយ ក៏ហ៊ានប្រព្រឹត្តធ្វើអំពើទុច្ចរិតទាំង ១០ យ៉ាង គឺៈកាយ-ទុច្ចរិត ៣, វចីទុច្ចរិត ៤, មនោទុច្ចរិត ៣ លុះប្រព្រឹត្តធ្វើទុច្ចរិតទាំង ៣ ឥតកោតញញើតយ៉ាងនេះហើយ លុះបែកធ្លាយពីកាយស្លាប់ទៅ ក៏រមែងធ្លាក់ទៅកាន់ទុគ្គតិ, វិនិបាត, នរក អស់កាលជាយូរអង្វែង ព្រោះតែភ្លើងទាំង ៣ នេះកើតឡើងក្នុងសន្តានចិត្តរបស់បុគ្គលនោះឯង ។

ចំណែកខាងអរូបក្ខន្ធទាំង ៤ គឺ វេទនា ធម្មជាតិជាគ្រឿងសោយនូវអារម្មណ៍, សញ្ញា ធម្មជាតិជាគ្រឿងចំណាំឬសំគាល់នូវអារម្មណ៍, សង្ខារ សភាវៈតាក់តែងនូវរូបកាយរបស់សត្វ, វិញ្ញាណ ធម្មជាតដឹងផ្សេង ៗ ។

បណ្ដា អុបក្ខន្ធទាំង ៥ សញ្ញានិងវិញ្ញាណទាំង ២ នេះដឹងដែរ, ស្គាល់ដែរ, តែដឹងស្គាល់នៅក្នុងអំណាចអវិជ្ជា- តណ្ហា- ឧបាទាន, ដឹងមិនពិត, ដឹងមិនប្រាកដទេ. ដូចដឹងថានេះរូបអញ. នេះសក់អញ, រោមអញ, ក្រចកអញ, ធ្មេញអញ, ស្បែកអញ ជាដើម នេះឈ្មោះថា ដឹងរបស់ពួកសញ្ញា- វិញ្ញាណ គឺដឹងនៅក្នុងអំណាចអវិជ្ជា- តណ្ហា- ឧបាទាន, ដឹងខុស.ប្រកាន់ខុស, មិនពិតថាពិត, មិនប្រាកដថាប្រាកដ, ខុសតាមផ្លូវមគ្គផលស្រឡះ ។

បញ្ញាពិចារណាឃើញច្បាស់ថា រូបនេះគ្មានអញ គ្មានឯងទេ, មិនមែនជាស្រីជាប្រុសទេ គឺគ្រាន់តែជាធាតុ ដី, ទឹក, ភ្លើង, ខ្យល់ប៉ុណ្ណោះ ។ រូបនេះគ្មានល្អ មានតែអសុភជាគ្រឿងមិនស្អាត, មិនផូរផង់ គួរតែខ្ពើមហើយ គួរតែលះបង់ចោល មិនគួរប្រកៀកប្រកាន់ឡើយ ។ ពួកសត្វដែលវង្វេងកាន់ប្រឡំ សំគាល់នូវអារម្មណ៍ខុស, ដឹងខុស ហើយប្រកាន់ទៅតាមអំណាចសញ្ញា និងវិញ្ញាណ ដែលសំគាល់ខុស ដឹងខុសនោះ ម៉្លោះហើយក៏បានជួបប្រទះតែនឹងសេចក្ដីទុក្ខលំបាកដោយការកើត, ចាស់, ឈឺ, ស្លាប់, ព្រាត់ប្រាស, សោក, ខ្សឹកខ្សួល, ទុក្ខ, ទោមនស្ស, ចង្អៀតចង្អល់តានតឹងក្នុងចិត្ត, មិនចេះចប់កប់កប្បជាអនេកមិនអស់ឡើយ ។

ការត្រិះរិះពិចារណាឲ្យឃើញច្បាស់ថា : រូបមិនទៀង, រូបជាទុក្ខ, រូបមិនមែនជារបស់ខ្លួនទេ ។ វេទនាមិនទៀង, វេទនាជាទុក្ខ, វេទនាមិនមែន

ជារបស់ខ្លួនទេ ។ សញ្ញាមិនទៀង, សញ្ញាជាទុក្ខ, សញ្ញាមិនមែនជារបស់ខ្លួនទេ ។ សង្ខារមិនទៀង, សង្ខារជាទុក្ខ, សង្ខារមិនមែនជារបស់ខ្លួនទេ ។ វិញ្ញាណមិនទៀង, វិញ្ញាណជាទុក្ខ, វិញ្ញាណមិនមែនជារបស់ខ្លួនទេ ។ កាលបើបានពិចារណាឃើញច្បាស់ថា : រូបមិនទៀង, វេទនាមិនទៀង, សញ្ញាមិនទៀង, សង្ខារមិនទៀង, វិញ្ញាណមិនទៀង ហើយក៏រមែងលះបង់នូវសញ្ញាដែលសំគាល់ថាទៀងៗ, សំគាល់ថាល្អៗ, ថាសុខៗ, ថាខ្លួនៗ, ថាអញៗ ក្នុងខន្ធទាំង ៥ នោះចេញ ។ កាលបើបុគ្គលណាមួយលះនូវសញ្ញាដែលសំគាល់ខុសនោះអស់ហើយ វិញ្ញាណដែលដឹងខុសនោះក៏លះដែរ, កាលបើវិញ្ញាណលះហើយ សង្ខារៈក៏លះដែរ, កាលបើសង្ខារលះហើយ វេទនាដែលទទួលសោយនូវអារម្មណ៍នោះក៏លះដែរ, បើវេទនាលះហើយ រូបក៏លះដែរ ។ បើលះនូវខន្ធទាំង ៥ នេះបានពេលណាហើយទើបរួចផុតស្រឡះចាកកងទុក្ខទាំងពួងមិនមានសេសសល់ឡើយ ។

ការត្រិះរិះត្រូវ យល់ត្រូវដូចបានពោលមកនេះ ទើបឈ្មោះថាលុះនូវខន្ធទាំង ៥ នេះបាន ។ ព្រោះថាការត្រិះរិះពិចារណាឃើញច្បាស់នូវរូបជាមិនទៀង រមែងអស់នូវនិមិត្តដែលឃើញថាទៀងៗ, ឃើញថាល្អៗ នោះ, បើអស់និមិត្តដែលឃើញថា ទៀង, ថាល្អ នេះហើយ ទើបហៅថា អនិមិត្តវិមោក្ខ គឺរួចផុតពីនិមិត្តនោះឯង ។

ពិចារណាឃើញច្បាស់ថា : រូបនេះពិតជាទុក្ខមែន រមែងរូបតាកនិមិត្តដែលឃើញជាសុខ ៗ នោះ ទើបហៅថា អប្បណិហិតវិមោក្ខ គឺរូបផុតនិមិត្តដែលឃើញថា នេះរបស់អញ, នេះសុខ ក្នុងសន្តានតាំងឡាយនោះៗ

បើពិចារណាឃើញច្បាស់ថា : រូបនេះមិនមែនជារបស់ខ្លួន,មិនមែនជារបស់អញផ្ទុះ រមែងរូបតាកនិមិត្ត ដែលឃើញជាខ្លួន-ជាអញនោះ ទើបហៅថា សុញ្ញតវិមោក្ខ គឺរូបតាកនិមិត្តដែលឃើញជាខ្លួន ៗ "ជាអញ ៗ នោះឯង ។ វិមោក្ខទាំង ៣ យ៉ាងនេះឯង ជាធម៌ផុតតាកនិមិត្តដែលធ្លាប់ឃើញជាល្អ ៗ, ជាទៀង ៗ, ជាសុខ ៗ ក្នុងខន្ធទាំងនេះ, ធ្លាប់ឃើញជាខ្លួន ៗ, អញ ៗ, របស់យើង, របស់គេ ក្នុងខន្ធទាំង ៥ នេះឯង ។

កាលបើនិមិត្តនេះរលត់ហើយ សញ្ញាដែលកាន់យកនូវនិមិត្តនោះក៏រលត់ដែរ, បើសញ្ញារលត់ហើយ វិញ្ញាណដែលធ្លាប់ដឹងតាមសញ្ញានោះក៏រលត់ដែរ, បើវិញ្ញាណរលត់ហើយ សង្ខារដែលជាអ្នកតាក់តែងនោះក៏រលត់ដែរ, បើសង្ខាររលត់ហើយ វេទនាដែលធ្លាប់សោយនូវអារម្មណ៍នោះ ក៏រលត់ដែរ, បើវេទនារលត់ហើយ ផស្សៈក៏រលត់ដែរ, បើផស្សៈរលត់ហើយ អវិជ្ជា, តណ្ហា, ឧបាទាន ក៏រលត់ដែរ ; បើអវិជ្ជា, តណ្ហា, ឧបាទាន រលត់ហើយ ញាណដែលជាគ្រឿងត្រាស់ដឹងនូវអរិយសច្ច ៤ ប្រការ និងមគ្គផល ព្រះនិព្វាននោះ ក៏រមែងកើតឡើងប្រាកដដល់អរិយ-សាវ័កក្នុងសាសនានេះ ។ ញាណរបស់អរិយសាវ័កនោះក៏ដឹងច្បាស់ថា

អាសវៈរបស់អញអស់ហើយ, ញាណរបស់អរិយសាវកនោះក៏ដឹងច្បាស់ថា ជាតិកំណើតរបស់អញអស់ហើយ, ញាណដឹងច្បាស់ថា : មគ្គព្រហ្ម-ចរិយធម៌អាត្មាអញក៏បានប្រព្រឹត្តគ្រប់គ្រាន់ហើយ, សោឡសកិច្ចអាត្មាអញក៏បានធ្វើរួចហើយ; ញាណដឹងច្បាស់ថា: មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនោះទៀតមិនមានឡើយ ។

ញាណដឹងច្បាស់នូវធម៌ដែលស្ងប់ម្ងាប់, ធម៌មិនកំរើកនេះហើយដែលឈ្មោះថាជាធម៌សុខពិត, សុខមែន, ជាធម៌ដ៏ឧត្តម នេះហៅថាក្រិះរិះចេញចាកខន្ធ ៥ ។ ឯក្រិះរិះចេញចាកភពនោះ គឺក្រិះរិះពិចារណាឃើញទោសក្នុងភព ៣ គឺ កាមភព ១, រូបភព ១, អរូបភព ១ ។ ឃើញទោសក្នុងកាមភពនោះ គឺឃើញទោសក្នុងកាមាវចរកុសលសង្ខារ ដែលតាក់តែងជាតិ-ភព-សម្បត្តិក្នុងកាមភពនោះ ឲ្យប្រព្រឹត្តទៅដើម្បីចាស់, ឈឺ, ស្លាប់, ព្រាត់ប្រាស់ជាធម្មតា ។ ឃើញទោសក្នុងរូបភពនោះ គឺឃើញទោសក្នុងរូបាវចរកុសលសង្ខារដែលតាក់តែងជាតិ-ភព- សម្បត្តិក្នុងរូបភពនោះ ក៏ប្រព្រឹត្តទៅដើម្បីចាស់, ឈឺ, ស្លាប់, វិនាសព្រាត់ប្រាស ជាធម្មតា ។ ឃើញទោសក្នុងអរូបភពនោះគឺឃើញទោសក្នុងអរូបាវចរ-កុសលសង្ខារ ដែលតាក់តែងជាតិ-ភព-សម្បត្តិក្នុងអរូបភពនោះ ក៏ប្រព្រឹត្តទៅដើម្បីចាស់, ឈឺ, ស្លាប់ វិនាសព្រាត់ប្រាសជាធម្មតា ។ ក្រិះរិះ

ឃើញទោសក្នុងភពទាំង ៣ ដូចជាភ្លើងឆេះសន្ធោសន្ធៅកាលដាលមកលើពពួកសត្វដែលកំពុងដេកលក់ក្នុងផ្ទះ គឺវដ្តសង្សារ, ដេកលក់នៅក្នុងគន្លង់ឱឃៈទាំង ៤ គឺៈ កាមោឃៈ, ភវោឃៈ, ទិដ្ឋោឃៈ និងអវិជ្ជោឃៈ ។ ត្រិះរិះពិចារណាឃើញទោសរបស់សង្សារ ដែលតាក់តែងជាភព-គតិ-សម្បត្តិ ក្នុងកាមភពក្តី, ក្នុងរូបភពក្តី, ក្នុងអរូបភពក្តី ដូចជាភ្លើងឆេះកាលដាលមកលើពពួកសត្វដែលកំពុងដេកលក់ ក្នុងភពទាំង ៣ ដូច្នេះហើយ ចិត្តក៏នឿយណាយ មិនជាប់ចិត្ត, មិនត្រេកអរនឹងភព ហៅថា ចិត្តចេញចាក ឬថា នូវចាកភពទាំង ៣ ។ ការត្រិះរិះត្រូវ ឬយល់ត្រូវដូចបានអធិប្បាយរៀបរាប់មកប៉ុណ្ណោះជាដើម ហៅថា សម្មាសង្កប្បៈ ចាត់ជាអង្គមគ្គ ទី ២ ។

លក្ខណៈ-កិច្ចនិងផលរបស់សម្មាសង្កប្បៈ

លក្ខណៈ – សមាចិត្តាភិនិរោបនលក្ខណោ សម្មាសង្កប្បៈ មានកិរិយាដាក់នូវចិត្តដោយប្រពៃជាលក្ខណៈ ។

កិច្ច – អប្បនារសោ សម្មាសង្កប្បៈ មានអប្បនាជាកិច្ច ។

ផ.ប – មិច្ឆាសង្កប្បប្បហានបច្ចុប្បដ្ឋានោ សម្មាសង្កប្បៈ មានកិរិយាលះបង់នូវតម្រិះខុសជាផល ។

សម្មាសង្កប្បៈនេះជាមនោកម្ម ព្រោះជាអំពើត្រូវធ្វើដោយផ្លូវចិត្ត ចាត់ជាបញ្ញាខន្ធ ។

# អធិប្បាយអង្គមគ្គទី ៣

សម្មាវាចា ការនិយាយត្រូវខាង ៤ យ៉ាងគឺ មិននិយាយកុហកបញ្ឆោតឲ្យខូចប្រយោជន៍អ្នកដទៃ ១, មិននិយាយញុះញង់បង្កបង្កើនឲ្យខូចប្រយោជន៍និងកេរ្តិ៍ឈ្មោះរបស់អ្នកដទៃ ១, មិននិយាយគ្រោះគោះបោះបោកម៉ានដេរប្រទេចក់ហែងគម្រាមអ្នកដទៃជាដើម ១, មិននិយាយពាក្យរោយរាយសាត់អណ្ដែតឥតហេតុផល ១, ការត្រូវទាំង ៤ យ៉ាងនេះ ហៅថា សម្មាវាចា ។

សម្មាវាចានេះព្រះមានព្រះភាគទ្រង់សំដែងទៅក្នុងគម្ពីរមជ្ឈិមនិកាយ ត្រង់មហាចត្តារីសកសូត្រថា :

សម្មាវាចំ បហំ ភិក្ខវេ ទ្វយំ វទាមិ អត្ថិ ភិក្ខវេ សម្មាវាចា សាសវា បុញ្ញភាគិយា ឧបធិវេបក្កា អត្ថិ ភិក្ខវេ សម្មាវាចា អរិយា អនាសវា លោកុត្តរា មគ្គង្គា = ម្នាលភិក្ខុទាំងឡាយ តថាគតសំដែងនូវសម្មាវាចាជាចំណែកពីរ, ម្នាលភិក្ខុទាំងឡាយ សម្មាវាចាប្រកបដោយអាសវៈ ជាចំណែកនៃបុណ្យ ឲ្យផលជាឧបធិកិលេស (ជាលោកិយ) ក៏មាន, ម្នាលភិក្ខុទាំងឡាយ សម្មាវាចាដ៏ប្រសើរមិនមានអាសវៈ ជាលោកុត្តរៈ ជាអង្គនៃមគ្គក៏មាន ។

សម្មាវាចា ជាលោកិយនោះ បានដល់សំដីល្អត្រឹមត្រូវរបស់បុថុជ្ជន.

បុគ្គលដែលនៅជាប់ជំពាក់ដោយទុច្ចរិតលេសទៀយ ។ និងសម្មាវាចាជាលោកុត្តរៈ បានដល់ពាក្យសំដីរបស់ព្រះអរិយបុគ្គលទាំងឡាយ ដែលមានចិត្តប្រាសចាកអាសវៈ ប្រកបដោយអរិយមគ្គ ។

ម្យ៉ាងទៀត សម្មាវាចាទាំងពីរនេះ ព្រះមានព្រះភាគទ្រង់សំដែងក្នុងសច្ចបដ្ឋានសូត្រថា :

មុសាវាចា វេរមណី បិសុណាយ វាចាយ វេរមណី ផរុសាយ វាចាយ វេរមណី សម្ផប្បលាបា វេរមណី អយំ វុច្ចតិ ភិក្ខវេ សម្មាវាចា = ចេតនាវៀរចាកការពោលពាក្យមិនពិត ១, ចេតនាវៀរចាកសំដីញុះញង់ ១, ចេតនាវៀរចាកសំដីគ្រោតគ្រាតព្រោះពោក ១, ចេតនាវៀរចាកសំដីរោយរាយឥតហេតុផល ១ ម្នាលភិក្ខុទាំងឡាយ នេះតថាគតឲ្យឈ្មោះថា សម្មាវាចា ។

## អធិប្បាយ

ចេតនាវៀរចាកការពោលនូវពាក្យមិនពិត បានដល់ចេតនារបស់បុគ្គលអ្នកមានសច្ចៈ មានពាក្យសំដីមិនបំផ្លើស គឺមិននិយាយឲ្យលើសពីសភាវធម៌ដែលពិតមែន, ដែលបានឃើញ, បានឮ, បានដឹង, បើបានឃើញយ៉ាងណា, ឮយ៉ាងណា, ដឹងយ៉ាងណា ក៏និយាយយ៉ាងនោះ ។

បុគ្គលអ្នកមានសច្ចៈ គឺអ្នកនិយាយពិតអះអាង ដែលចេញជាប្រក្រតី :

១). អត្តនា ច មុសាវាទា បដិវិរតោ ហោតិ អ្នកវៀរចាកកិរិយាពោលនូវពាក្យមិនពិតដោយខ្លួនឯង ;

២) បរញ្ច មុសាវាទា វេរមណិយា សមាទបេតិ - អ្នកបបួលអ្នកដទៃឲ្យវៀរចាកកិរិយាពោលនូវពាក្យមិនពិត ;

៣). មុសាវាទា វេរមណិយា ច សមនុញ្ញោ ហោតិ អ្នកត្រេកអរក្នុងកិរិយាវៀរចាកការពោលនូវពាក្យមិនពិត ;

៤). មុសាវាទា វេរមណិយា ច វណ្ណំ ភាសតិ អ្នកពោលសរសើរនូវការវៀរចាកកិរិយាពោលនូវពាក្យមិនពិត ។

ចេតនាវៀរចាកសំដីញុះញង់ បានដល់ចេតនារបស់បុគ្គលអ្នកឃើញច្បាស់នូវទោសរបស់បិសុណាវាចា នឹងឃើញច្បាស់នូវអានិសង្សរបស់សាមគ្គីធម៌ ។

បុគ្គលអ្នកវៀរចាកសំដីញុះញង់នោះ ចែកចេញជា ៤ ពួកគឺ :

១). អត្តនា ច បិសុណាវាចាយ បដិវិរតោ ហោតិ អ្នកវៀរចាកសំដីញុះញង់ដោយខ្លួនឯង ;

២). បរញ្ច បិសុណាវាចាយ វេរមណិយា សមាទបេតិ ជាអ្នកបបួលអ្នកដទៃឲ្យវៀរចាកសំដីញុះញង់ ;

៣). បិសុណាវាចាយ វេរមណិយា ច សមនុញ្ញោ ហោតិ អ្នកត្រេកអរក្នុងកិរិយាវៀរចាកសំដីញុះញង់ ;

៤). បិសុណាវាចាយ វេរមណិយា ច វណ្ណំ ភាសតិ អ្នកពោលសរសើរនូវកិរិយាវៀរចាកសំដីញុះញង់ ។

ចេតនាវៀរចាកសំដីគ្រគោះគ្រោះគ្រោក បានផលដល់ចេតនារបស់បុគ្គលអ្នកឃើញនូវទោសរបស់ផរុសវាចា ហើយឃើញនូវអានិសង្សរបស់ករុណាធម៌ ។

បុគ្គលអ្នកវៀរចាកសំដីគ្រគោះគ្រោះគ្រោកនោះចែកចេញជា ៤ ពួកគឺ ៖

១). អត្តនា ច ផរុសវាចាយ បដិវិរតោ ហោតិ អ្នកវៀរចាកសំដីគ្រគោះគ្រោះគ្រោកដោយខ្លួនឯង ;

២). បរញ្ច ផរុសវាចាយ វេរមណិយា សមាទបេតិ អ្នកបបួលអ្នកដទៃឲ្យវៀរចាកសំដីគ្រគោះគ្រោះគ្រោក ;

៣). ផរុសវាចាយ វេរមណិយា ច សមនុញ្ញោ ហោតិ អ្នកត្រេកអរក្នុងកិរិយាវៀរចាកសំដីគ្រគោះគ្រោះគ្រោក ;

៤). ផរុសវាចាយ វេរមណិយា ច វណ្ណំ ភាសតិ អ្នកពោលសរសើរនូវការវៀរចាកសំដីគ្រគោះគ្រោះគ្រោក ។

ចេតនាវៀរចាកសំដីរោយរាយឥតហេតុផល បានផលដល់ចេតនារបស់បុគ្គលអ្នកឃើញទោសរបស់ពាក្យរោយរាយ ហើយឃើញអានិសង្សរបស់កថាវត្ថុ ។

បុគ្គលអ្នកវៀរចាកសំដីរោយរាយឥតហេតុផលនោះ ចែកចេញជា ៤ ពួកគឺ ៖

១). អត្តនា ច សម្ផប្បលាបា បដិវិរតោ ហោតិ អ្នកវៀរចាកកិរិយាពោលនូវពាក្យរោយរាយឥតហេតុផលដោយខ្លួនឯង ;

២). បរញ្ច សម្ផប្បលាបា វេរមណិយា សមាទបេតិ អ្នកបបួលអ្នកដទៃឲ្យវៀរចាកកិរិយាពោលនូវពាក្យរោយរាយឥតហេតុផល;

៣). សម្ផប្បលាបា វេរមណិយា ច សមនុញ្ញោ ហោតិ អ្នកត្រេកអរក្នុងកិរិយាវៀរចាកការពោលនូវពាក្យរោយរាយឥតហេតុផល ;

៤). សម្ផប្បលាបា វេរមណិយា ច វណ្ណំ ភាសតិ អ្នកពោលសរសើរនូវកិរិយាវៀរចាកការពោលនូវពាក្យរោយរាយឥតហេតុផល ។

ឯតិរច្ឆានកថានោះ: ព្រះអរហន្តសម្មាសម្ពុទ្ធទ្រង់សំដែងក្នុងគម្ពីរមជ្ឈិមនិកាយ ឧបរិបណ្ណាសក: និងគម្ពីរទីឃនិកាយ សីលក្ខន្ធ ថាជាពាក្យជាកងាយ, ពាក្យឥតប្រយោជន៍, ពាក្យទទឹងផ្លូវសួគ៌និងព្រះនិព្វាន បើប្រព្រឹត្តទៅដើម្បីលេងកំប្លុក មាន ២៧ យ៉ាងគឺ:

១). រាជកថា និយាយពីស្តេច ;

២). ចោរកថា និយាយពីចោរ ;

៣). មហាមត្តកថា និយាយពីមហាមាត្យ ;

៤). សេនាកថា និយាយពីសេនា ;

៥). ភយកថា និយាយពីភ័យ ;

៦)- យុទ្ធកថា និយាយពីចម្បាំង ;

៧)- អន្នកថា និយាយពីបាយ ;

៨)- បានកថា និយាយពីទឹក ;

៩)- វត្ថកថា និយាយពីសំពត់ ;

១០)- សយនកថា និយាយពីដំណេក ;

១១)- មាលាកថា និយាយពីកម្រងផ្កា ;

១២)- គន្ធកថា និយាយពីគ្រឿងក្រអូប ;

១៣)- ញាតិកថា និយាយពីញាតិ ;

១៤)- យានកថា និយាយពីយានជំនិះ ;

១៥)- គាមកថា និយាយពីស្រុក ;

១៦)- និគមកថា និយាយពីនិគម ;

១៧)- នគរកថា និយាយពីក្រុង ;

១៨)- ជនបទកថា និយាយពីជនបទ ;

១៩)- ឥត្ថីកថា : និយាយពីស្រ្តី ;

២០)- សូរកថា និយាយពីមនុស្សក្លៀវក្លា ;

២១)- វិសិខាកថា និយាយពីច្រកផ្លូវ ;

២២)- កុម្ភដ្ឋានកថា និយាយពីកំពង់ទឹក ;

២៣)- បុព្វបេតកថា និយាយពីមនុស្សដែលស្លាប់ទៅ ;

២៤). នានត្តកថា និយាយពីពាក្យដែលឥតប្រយោជន៍ មានសភាពផ្សេង ៗ គ្នា ;

២៥). លោកក្ខាយិកា និយាយពីលោក (លោកនេះ អ្នកណាកសាង, អ្នកនោះកសាង, ក្អែកស ព្រោះឆ្អឹងវាសជាដើម) ;

២៦). សមុទ្ទក្ខាយិកា និយាយពីរឿងជីកសមុទ្រ (សមុទ្រ ហៅថាសាគរ ព្រោះទេវតាជីកជាដើម) ;

២៧). ភវាភវកថា និយាយពីសេចក្តីចំរើននិងមិនចំរើន ដែលជាការឥតប្រយោជន៍ ;

គាថាទាំង២៧នេះ បព្វជិតទាំងឡាយតែងវៀរពាក្យកុំនិយាយឡើយ គឺលោកនិយាយតែអំពីកថាវត្ថុទាំង ១០ យ៉ាងគឺ ៖

១). អប្បិច្ឆកថា និយាយពីសេចក្តីប្រាថ្នាតិច ;

២). សន្តុដ្ឋិកថា និយាយពីសេចក្តីសន្តោស ;

៣). បវិវេកកថា និយាយពីសេចក្តីស្ងប់ស្ងាត់ ;

៤). អសំសគ្គកថា និយាយពីសេចក្តីមិនជាប់ជំពាក់ ;

៥). វិរិយារម្ភកថា និយាយពីការប្រារព្ធព្យាយាម ;

៦). សីលកថា និយាយពីសីល ;

៧). សមាធិកថា និយាយពីសមាធិ ;

៨). បញ្ញាកថា និយាយពីប្រាជ្ញា ;

៩). វិមុត្តិគាថា និយាយពីការរួចចាកកិលេស ;

១០). វិមុត្តិញាណទស្សនគាថា និយាយពីការឃើញដោយបញ្ញា ចំពោះកិរិយារួចចាកកិលេស ។

គាថាទាំង១០នេះជាគាថាថ្លៃថ្នូរ ជាគាថានាំមកនូវប្រយោជន៍និងសេចក្តីសុខចំរើនដ៏ធំទូលាយចំពោះខ្លួននិងបុគ្គលដទៃ ប្រព្រឹត្តទៅដើម្បីរលត់ទុក្ខគ្រប់ប្រការ ។

ការនិយាយត្រូវតាំង ៤ យ៉ាង ដូចបានរៀបរាប់មកប៉ុណ្ណេះជាដើម ហៅថា "សម្មាវាចា" ចាត់ជាអង្គមគ្គទី ៣ ។

លក្ខណៈកិច្ចនិងផលរបស់សម្មាវាចា

លក្ខណៈ= បរិគ្គហលក្ខណា សម្មាវាចាមានកិរិយាដឹងនូវពាក្យពិតជាលក្ខណៈ ។

កិច្ច= វិរមណរសា សម្មាវាចាមានការវៀរចាកវចីទុច្ចរិតជាកិច្ច ។

ផល= មិច្ឆាវាចប្បហានបច្ចុបដ្ឋានា សម្មាវាចាមានកិរិយាលះបង់នូវវាចាខុសជាផល ។

សម្មាវាចានេះចាត់ជាវចីកម្ម ព្រោះជាអំពើត្រូវធ្វើដោយវាចា ចាត់ជាសីលក្ខន្ធ ។

## អធិប្បាយអង្គមគ្គទី ៤

សម្មាកម្មន្តោ ការងារត្រូវមាន ៣ យ៉ាងគឺៈ មិនសម្លាប់សត្វ ១,

មិនល្មួចទ្រព្យគេ១, មិនប្រព្រឹត្តខុសក្នុងកាម១, ទាំង៣យ៉ាងនេះ ហៅថា សម្មាកម្មន្ត: ។

សម្មាកម្មន្តនេះ ព្រះមានព្រះភាគទ្រង់សំដែងក្នុងគម្ពីរមជ្ឈិមនិកាយ មហាចត្តារីសកសូត្រថា :

សម្មាកម្មន្តំ បហំ ភិក្ខវេ ទ្វយំ វទាមិ អត្ថិ ភិក្ខវេ សម្មាកម្មន្តោ សាសវោ បុញ្ញភាគិយោ ឧបធិវេបក្កោ អត្ថិ ភិក្ខវេ សម្មាកម្មន្តោ អរិយោ អនាសវោ លោកុត្តរោ មគ្គង្គោ = ម្នាលភិក្ខុទាំងឡាយ តថាគតសំដែងនូវសម្មាកម្មន្ត:ជាពីរចំណែក, ម្នាលភិក្ខុទាំងឡាយ សម្មាកម្មន្ត:ប្រកបដោយអាសវ:ជាចំណែកនៃបុណ្យឲ្យផលជាឧបធិកិលេស (ជាលោកិយ) ក៏មាន, ម្នាលភិក្ខុទាំងឡាយ សម្មាកម្មន្ត:ដ៏ប្រសើរមិនមានអាសវ:, ជាលោកុត្តរ:, ជាអង្គនៃមគ្គក៏មាន ។

សម្មាកម្មន្ត:ជាលោកិយនោះ បានដល់ការវៀរល្អបរិសុទ្ធរបស់បុថុជ្ជនបុគ្គលដែលមានចិត្តពុំទាន់ប្រស្រឡះចាកអាសវធម៌ នៅជាប់ជំពាក់ដោយឧបធិកិលេសនៅឡើយ ។

ឯសម្មាកម្មន្ត:ជាលោកុត្តរ:នោះ បានដល់ការវៀររបស់ព្រះអរិយបុគ្គលដែលប្រាសចាកអាសវ: មានចិត្តបរិបូណ៌ដោយអរិយមគ្គ ។

សម្មាកម្មន្តៈ ទាំង ២ នេះ ព្រះអរហន្តសម្មាសម្ពុទ្ធ ទ្រង់សំដែងនៅក្នុងសតិបដ្ឋានសូត្រថា :

បាណាតិបាតា វេរមណី អទិន្នាទានា វេរមណី កាមេសុ មិច្ឆាចារា វេរមណី អយំ វុច្ចតិ ភិក្ខវេ សម្មាកម្មន្តោ = ចេតនាវៀរចាកកិរិយាញុំាងសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង ១, ចេតនាវៀរចាកកិរិយាកាន់យកនូវទ្រព្យដែលគេមិនបានឲ្យ ១, ចេតនាវៀរចាកកិរិយាប្រព្រឹត្តខុសក្នុងកាម(១)ទាំងឡាយ ១, ម្នាលភិក្ខុទាំងឡាយ នេះហៅថា "សម្មាកម្មន្តៈ" ។

អធិប្បាយ

ចេតនាវៀរចាកកិរិយាញុំាងសត្វមានជីវិតឲ្យធ្លាក់ចុះកន្លងនោះបាន ដល់ចេតនារបស់បុគ្គលអ្នកមានមេត្តានិងករុណា, ព្រោះមេត្តាជាធម្មជាតិប្ដូចសាលស្នេហាប្រាថ្នាពប់គេសង្គ្រោះចង់ជួយការពារជីវិតបុគ្គលដទៃ ឲ្យបានសេចក្តីសុខចំរើន ។ ករុណាជាធម្មជាតិបង្អោនចិត្តអាណិតអាសូរចំពោះបុគ្គលអ្នកមានសេចក្តីលំបាកវេទនាយ៉ាក ធ្វើចិត្តឲ្យមានអាការហាក់ដូចជានឹងលោះទិញរំលែកយកសេចក្តីទុក្ខរបស់បុគ្គលដទៃនោះចេញ ។ មេត្តានិងករុណានេះ ជាគ្រឿងគាំទ្រចេតនារបស់បុគ្គលអ្នកវៀរចាកការសម្លាប់សត្វ ។ ធម៌ ២ នេះលោកចាត់ជាកល្យាណធម៌ គឺជាគ្រឿងលំអ

---

១ ក្នុងអភិធម្មត្ថវិភាវិនីយៈ នឹកនូវស្មុកក៏ឈ្មោះថាកាមដែរ ហៅថា វត្ថុកាម ។

របស់បុគ្គលអ្នកមិនសម្លាប់សត្វ ។

បុគ្គលអ្នកវៀរចាកការសម្លាប់សត្វនោះ ចែកចេញជា ៤ ពួកគឺ ៖

១). អត្តនា ច ការណាតិកាតា បដិវិរតោ ហោតិ ជាអ្នកវៀរចាកការសម្លាប់សត្វដោយខ្លួនឯង ;

២). បរញ្ច ចាណាតិចាតា វេរមណិយា សមាទបេតិ ជាអ្នកបបួលអ្នកដទៃឲ្យវៀរចាកការសម្លាប់សត្វ ;

៣). ចាណាតិចាតា វេរមណិយា ច សមនុញ្ញោ ហោតិ ជាអ្នកត្រេកអរនឹងកិរិយាវៀរចាកការសម្លាប់សត្វ ;

៤). ចាណាតិចាតា វេរមណិយា ច វណ្ណំ ភាសតិ ជាអ្នកពោលសរសើរនូវកិរិយាវៀរចាកការសម្លាប់សត្វ ។

ចេតនាវៀរចាកកិរិយាកាន់យកនូវទ្រព្យដែលគេមិនបានឲ្យ បាន ដល់ចេតនារបស់បុគ្គលអ្នកមានសម្មាអាជីវៈ ការចិញ្ចឹមជីវិតដោយប្រពៃ ព្រោះចាកមិច្ឆាជីវៈ ការចិញ្ចឹមជីវិតខុស គឺវៀរចាកជំនួញមិនប្រសើរ ៥ប្រការ ហើយមានការចិញ្ចឹមជីវិតតាមគន្លងធម៌, អនុវត្តន៍តាមសណ្តាប់ធ្នាប់ របស់សង្គម មិនរលះរលាំនស្រេកស្រេខញឆក់ដណ្តើមទ្រព្យសម្បត្តិ របស់បុគ្គលដទៃ ចាំងមិនបៀតបៀនអាយុសង្ខាររបស់សត្វ ព្រោះតែ ចំណង់ក្នុងទ្រព្យសម្បត្តិ ។

សម្មាអាជីវៈ ការចិញ្ចឹមជីវិតដោយប្រពៃនេះជាគ្រឿងគាំទ្រនូវចេតនា

របស់បុគ្គលអ្នកវៀរចាកការលួចនូវទ្រព្យរបស់បុគ្គលដទៃ ៗ ន័យខ្លះលោក ចាត់ជាកល្យាណធម៌ គឺធម៌ជាគ្រឿងលំអរបស់បុគ្គលអ្នកមិនកាន់យកនូវទ្រព្យរបស់បុគ្គលដទៃ ៗ ។

បុគ្គលអ្នកវៀរចាកការកាន់យកនូវទ្រព្យរបស់បុគ្គលដទៃនោះចែកចេញជា ៤ពួកគឺ៖

១). អត្តា ច អទិន្នាទានា បដិវិរតោ ហោតិ ជាអ្នកវៀរចាកការកាន់យកនូវទ្រព្យនៃបុគ្គលដទៃដោយខ្លួនឯង ;

២). បរញ្ច អទិន្នាទានា វេរមណិយា សមាទបេតិ ជាអ្នកបបួលអ្នកដទៃឲ្យវៀរចាកការកាន់យកនូវទ្រព្យដែលគេមិនបានឲ្យ;

៣). អទិន្នាទានា វេរមណិយា ច សមនុញ្ញោ ហោតិ ជាអ្នកត្រេកអរគុណកិរិយាវៀរចាកការកាន់យកនូវទ្រព្យដែលគេមិនបានឲ្យ;

៤). អទិន្នាទានា វេរមណិយា ច វណ្ណំ ភាសតិ ជាអ្នកពោលសរសើរនូវកិរិយាវៀរចាកការកាន់យកនូវទ្រព្យដែលគេមិនបានឲ្យ ។

ចេតនាវៀរចាកកិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ បានដល់ចេតនារបស់បុគ្គលអ្នកមានសតិសំវរៈ និងសទារសន្តោសៈ ព្រោះសតិសំវរៈមានឥទ្ធិពលនាំការសង្រួមប្រយ័ត្នរក្សាចិត្ត មិនឲ្យលិចលង់ជ្រួលទៅក្នុងកាម ប្រព្រឹត្តខុសចាកប្រវេណីរបស់ត្រកូល, សទារសន្តោសៈ មានឥទ្ធិពលនាំការធ្វើចិត្តឲ្យត្រេកអរល្មម ស្កប់ស្កល់ចំពោះតែភរិយានិងស្វាមី

របស់ខ្លួន មិនឲ្យរះរើមប្រព្រឹត្តហួសហេតុ ។ សតិសំវរៈ និង សទារ-សន្តោសៈនេះ ជាគ្រឿងគាំទ្រចេតនារបស់បុគ្គលអ្នកវៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។ ព្រោះ: លោកចាត់ជាគុណធម៌របស់បុគ្គលអ្នកវៀរចាកកាមេសុមិច្ឆាចារ ។

បុគ្គលអ្នកវៀរចាកកាមេសុមិច្ឆាចារនោះចែកចេញជា ៤ ពួក:

១)- អត្តនា ច កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ ជាអ្នកវៀរចាកកាមេសុមិច្ឆាចារដោយខ្លួនឯង;

២)- បរញ្ច កាមេសុ មិច្ឆាចារា វេរមណិយា សមា-ទបេតិ ជាអ្នកបបួលអ្នកដទៃឲ្យវៀរចាកកាមេសុមិច្ឆាចារ;

៣)- កាមេសុមិច្ឆាចារា វេរមណិយា ច សមនុញ្ញោ ហោតិ ជាអ្នកត្រេកអរក្នុងកិរិយាវៀរចាកកាមេសុមិច្ឆាចារ;

៤)- កាមេសុ មិច្ឆាចារា វេរមណិយា ច វណ្ណំ ភាសតិ ជាអ្នកពោលសរសើរនូវកិរិយាវៀរចាកកាមេសុមិច្ឆាចារ ។

ការវៀរគ្រប់ទាំង ៣ យ៉ាងដូចបានអធិប្បាយរៀបរាប់មកពុំណោះជាដើម ហៅថា សម្មាកម្មន្ត: ចាត់ជាអដ្ឋមគ្គ ទី ៤ ។

លក្ខណ: កិច្ចនិងផលរបស់សម្មាកម្មន្ត:

លក្ខណ: — សមុដ្ឋាបនលក្ខណោ សម្មាកម្មន្តោ: មានកិរិយាលើកស្ទួយនូវខ្លួនជាលក្ខណ: ។

កិច្ច – វិរមណរសោ សម្មាកម្មន្តៈ មានកិរិយាវៀរចាកកាយទុច្ចរិតជាកិច្ច ។

ផល – អកិច្ចកម្មបរិច្ចជនបច្ចុប្បដ្ឋានោ សម្មាកម្មន្តៈ មានកិរិយាលះបង់នូវការធ្វើខុសជាផល ។

សម្មាកម្មន្តៈនេះចាត់ជាកាយកម្ម ព្រោះជាអំពើប្រព្រឹត្តដោយកាយ ចាត់ជាសីលក្ខន្ធ ។

## អធិប្បាយអង្គមគ្គទី៥

សម្មាអាជីវោ ការចិញ្ចឹមជីវិតត្រូវ គឺលះបង់នូវមិច្ឆាជីវៈ គឺការចិញ្ចឹមជីវិតខុសតាមសាសនារបស់បណ្ឌិតទាំងឡាយ ដែលធ្លាប់ថែរក្សាទប់ទល់ជីវិតតាមគន្លងបុរាណសម័យមក ។ ការដែលលះបង់នូវមិច្ឆាជីវៈចេញ ហើយអនុវត្តតាមសាសនាការថែរក្សាទប់ទល់ជីវិតរបស់បុរាណបណ្ឌិតទាំងឡាយហៅថា “សម្មាអាជីវៈ” ។

សម្មាអាជីវៈនេះ ព្រះមានព្រះភាគទ្រង់សំដែងក្នុងគម្ពីរមជ្ឈិមនិកាយ ត្រង់មហាចត្តារីសកសូត្រថា :

សម្មាអាជីវំ បេហំ ភិក្ខវេ ទ្វយំ វទាមិ អត្ថិ ភិក្ខវេ សម្មាអាជីវោ សាសវោ បុញ្ញភាគិយោ ឧបធិវេបក្កោ អត្ថិ ភិក្ខវេ សម្មាអាជីវោ អរិយោ អនាសវោ លោកុត្តរោ មគ្គង្គោ= ម្នាលភិក្ខុទាំងឡាយ តថាគតសំដែងនូវសម្មាអាជីវៈ

ជាចំណែកគតិ, ម្នាលភិក្ខុទាំងឡាយ សម្មាអាជីវៈប្រកបដោយអាសវៈជាចំណែកនៃបុណ្យឲ្យផលជាឧបធិកិលេស (ជាលោកិយ) ក៏មាន, ម្នាលភិក្ខុទាំងឡាយ សម្មាអាជីវៈដ៏ប្រសើរ, មិនមានអាសវៈ, ជាលោកុត្តរៈ, ជាអង្គនៃមគ្គក៏មាន ។

សម្មាអាជីវៈជាលោកិយនោះ បានដល់ការចិញ្ចឹមជីវិតដ៏ប្រសើររបស់បុថុជ្ជនបុគ្គលដែលនៅពុំទាន់រួចចាកអាសវធម៌ នៅជាប់ជំពាក់ដោយឧបធិកិលេសនៅឡើយ, ឯសម្មាអាជីវៈជាលោកុត្តរៈនោះ បានដល់ការចិញ្ចឹមជីវិតរបស់អរិយបុគ្គលដែលប្រាសចាកអាសវៈ មានចិត្តបរិបូណ៌ដោយអរិយមគ្គ ។

សម្មាអាជីវៈទាំងពីរនេះ ព្រះអរហន្តសម្មាសម្ពុទ្ធទ្រង់សំដែងនៅក្នុងសតិប្បដ្ឋានសូត្រថា :

ឥធ ភិក្ខវេ អរិយសាវកោ មិច្ឆាអាជីវំ បហាយ សម្មាអាជីវេន ជីវិតំ កប្បេតិ ភិក្ខវេ សម្មាអាជីវោ = ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ លះបង់នូវព្យាយាមជាគ្រឿងចិញ្ចឹមជីវិតខុស ហើយរស់នៅដោយព្យាយាមជាគ្រឿងចិញ្ចឹមជីវិតដ៏ប្រសើរ ម្នាលភិក្ខុទាំងឡាយ នេះតថាគតឲ្យឈ្មោះថា "សម្មាអាជីវៈ" ។

## អធិប្បាយ

ពាក្យថា លះបង់នូវមិច្ឆាជីវៈ ការព្យាយាមជាគ្រឿងចិញ្ចឹមជីវិតខុស នោះ បែកជាពីរផ្នែកគឺ ខាងគ្រហស្ថមួយផ្នែក, ខាងបព្វជិតមួយផ្នែក ។ ខាងគ្រហស្ថត្រូវលះបង់នូវជំនួញខុសតាំង ៥ យ៉ាងគឺ :

១)- សត្ថវណិជ្ជា ជួញគ្រឿងសាស្ត្រាវុធ;

២)- សត្តវណិជ្ជា ជួញសត្វ;

៣)- មំសវណិជ្ជា ជួញសាច់;

៤)- មជ្ជវណិជ្ជា ជួញទឹកស្រវឹង;

៥)- វិសវណិជ្ជា ជួញថ្នាំពិស ។

ជំនួញតាំង ៥ យ៉ាងនេះ ជាជំនួញមិនបរិសុទ្ធ, ជាជំនួញទាក់ទាប, ជាជំនួញមានទោស ពួកគ្រហស្ថអ្នកគប់គ្រងផ្ទះទាំងឡាយ គប្បីវៀរនូវការចិញ្ចឹមជីវិតដែលជាប់ទាក់ទងដោយជំនួញខុសតាំង ៥ ប្រការនេះ ហៅថា "សម្មាអាជីវៈ" ។

ផ្នែកខាងបព្វជិតត្រូវលះបង់នូវបាបធម៌ ៥ យ៉ាង មិនអនេសនៈ ២១ យ៉ាង ព្រមទាំងតិរច្ឆានវិជ្ជាទាំងឡាយ ។

បាបធម៌ ៥ និងអនេសនៈ ២១ មុខ ២៦ នោះពុំបានយកមកពិព្ណនាក្នុងទីនេះទេ ព្រោះមានគន្ថបព្វជិតសំលានិទ្ទេសទី៥ បញ្ចប់អោយបព្វជិតច្បាស់ នោះ ដោយសព្វគ្រប់ហើយ បើលោក-អ្នកត្រូវការចង់ដឹងចង់ជ្រាប

រឿងបាបធម៌ ៨ និងអនេសនៈ ២១ នោះ ប្អូនមើលក្នុងច្បាប់ទាំងពីរដែលលើកមកជាគ្រឿងអាងនោះចុះ នឹងបានឃើញសេចក្ដីដោយសព្វគ្រប់ក្នុងច្បាប់នោះឯង ។ ឯក្នុងទីនេះ សូមអធិប្បាយតែអំពីតិរច្ឆានវិជ្ជា ដោយសេចក្ដីសង្ខេបដូចតទៅ ។

ពាក្យថា ឲ្យលះមិច្ឆាជីវៈ ការចិញ្ចឹមជីវិតខុសចាកគន្លងធម៌នោះ មិនមែនឲ្យលះត្រឹមតែបាបធម៌ ៨ និងអនេសនៈ ២១ ប៉ុណ្ណោះទេ នៅមានធម៌ដែលត្រូវលះនោះច្រើនតទៅទៀត ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់សំដែងនៅក្នុងគម្ពីរទីឃនិកាយ ទ្រង់សីលក្ខន្ធវគ្គមានច្រើនជាអនេក ពុំអាចនឹងដកស្រង់យកមកអធិប្បាយឲ្យសព្វគ្រប់ក្នុងសៀវភៅនេះបានទេ នឹងដកស្រង់យកតែត្រង់ព្រះពុទ្ធដីកាបន្តិចក្នុងសាមញ្ញផលសូត្រថា:

យថា វា បនេកេ ភោន្តោ សមណព្រាហ្មណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបាយ តិរច្ឆានវិជ្ជាយ មិច្ឆាជីវេន ជីវិតំ កប្បេន្តិ = ម្នាលអ្នកដ៏ចំរើនទាំងឡាយ ម្យ៉ាងទៀត ដូចជាសមណៈព្រាហ្មណ៍ទាំងឡាយពួកខ្លះ បរិភោគភោជនទាំងឡាយដែលទាយកឲ្យដោយសទ្ធាហើយ សមណៈព្រាហ្មណ៍ទាំងនោះ នៅចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជាបែបនោះ ។

សេយ្យថីទំ តិរច្ឆានវិជ្ជានោះ តើដូចម្ដេចខ្លះ ?

(តិរច្ឆានវិជ្ជាទាំងនោះ) គឺ :

សុវុដ្ឋិកា កវិស្សតិ ទាយថាឆ្នាំនេះនឹងមានភ្លៀងធ្លាក់ស្រួល ;

ទុព្វុដ្ឋិកា កវិស្សតិ ទាយថាឆ្នាំនេះនឹងមានភ្លៀងធ្លាក់មិនស្រួល ;

សុភិក្ខំ កវិស្សតិ ទាយថាឆ្នាំនេះនឹងមានបាយសម្បូណ៌ ;

ទុព្ភិក្ខំ កវិស្សតិ ទាយថាឆ្នាំនេះនឹងមានបាយក្រ ;

ខេមំ កវិស្សតិ ទាយថាឆ្នាំនេះនឹងមានសេចក្តីក្សេម ;

ភយំ កវិស្សតិ ទាយថាឆ្នាំនេះនឹងមានភ័យ ;

រោគោ កវិស្សតិ ទាយថាឆ្នាំនេះនឹងមានរោគ ;

អារោគ្យំ កវិស្សតិ ទាយថាឆ្នាំនេះនឹងមិនមានរោគ ;

បព្វជិតចិញ្ចឹមជីវិតដោយការទាយដូច្នេះជាដើមហៅថា ចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ព្រោះការចិញ្ចឹមជីវិត ដែលអាស្រ័យទាក់ទងដោយបាបធម៌នឹងអនេសនៈ ឬ ក៏តិរច្ឆានវិជ្ជាណាមួយ ដូចបានរៀបរាប់មកនេះ ហៅថា មិច្ឆាជីវៈ មិនមែនជាគន្លងមគ្គទេឡើយ, បើបព្វជិតណាមួយរស់នៅដោយការចិញ្ចឹមជីវិតខុសនោះ បព្វជិតនោះឈ្មោះថា រស់នៅឥតកើត បើរស់នៅយូរទៅ: ទោសនោះរឹងរឹតតែច្រើនឡើង ៗ

ហេតុនេះ ឧបាសកក្តី, ឧបាសិកាក្តី, បព្វជិតក្តី កុំគប្បីចិញ្ចឹមជីវិតដោយជំនួញខុស ៥ យ៉ាងនឹងបាបធម៌, អនេសនៈ ២១ ប្រការនិង:តិរច្ឆានវិជ្ជានោះឡើយ, ត្រូវស្វែងរកការចិញ្ចឹមជីវិតដែលបរិសុទ្ធប្រាសចាកទោសគឺជំនួញ

ខុស ៥ យ៉ាងនេះ បាបធម៌ ៥ យ៉ាងនោះ ហើយហៅថា "សម្មាអាជីវៈ" ។ យ៉ាងនេះចាត់ជាអង្គមគ្គទី ៥ ។

លក្ខណៈ-កិច្ចនិងផលរបស់សម្មាអាជីវៈ :

លក្ខណៈ= វោទានលក្ខណោ សម្មាអាជីវៈមានការផូរផង់ជាលក្ខណៈ ។

កិច្ច= ញាយាជីវប្បវត្តិរសោ សម្មាអាជីវៈមានកិរិយាប្រព្រឹត្តទៅដោយការចិញ្ចឹមជីវិតដ៏សមគួរជាកិច្ច ។

ផល= មិច្ឆាជីវប្បហានបច្ចុប្បដ្ឋានោ សម្មាអាជីវៈមានកិរិយាលះបង់នូវការចិញ្ចឹមជីវិតខុសជាផល ។

សម្មាអាជីវៈនេះ ចាត់ជាកាយកម្មផង, ជាវចីកម្មផង ព្រោះជាអំពើត្រូវធ្វើដោយកាយនិងវាចា, ចាត់ចូលក្នុងសីលក្ខន្ធ ។

## អធិប្បាយអង្គមគ្គទី ៦

សម្មាវាយាមោ សេចក្ដីព្យាយាមត្រូវ បានដល់សេចក្ដីព្យាយាមដែលប្រព្រឹត្តទៅក្នុងចំណែកនៃកុសលធម៌ទាំងពួង ។ ព្រះសម្មាសម្ពុទ្ធបរមគ្រូទ្រង់សំដៅយកសេចក្ដីព្យាយាមល្អ ៤ យ៉ាង ដោយព្រះពុទ្ធដីកាដែលព្រះអង្គទ្រង់សំដែងក្នុងគម្ពីរទីឃនិកាយមហាវគ្គ និងគម្ពីរមជ្ឈិមនិកាយមូលបណ្ណាសកៈត្រង់សតិប្បដ្ឋានសូត្រថា :

កតមោ ច ភិក្ខវេ សម្មាវាយាមោ ម្នាលភិក្ខុទាំងឡាយ

ដូចម្ដេចហៅថា សេចក្ដីព្យាយាមដោយប្រពៃ ?

ឥធ ភិក្ខវេ ភិក្ខុ អនុប្បន្នានំ ចាបកានំ អកុស-លានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ បេ ។ ឧប្បន្នានំ កុសលានំ ធម្មានំ ភិយ្យោ ភាវាយ ឆន្ទំ ជនេតិ វាយ-មតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ = ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែងប្រារព្ធនូវព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីញុំាងធម៌ទាំងឡាយ ជាអកុសលដ៏លាមក ដែលមិនទាន់កើតឡើង កុំឲ្យកើតឡើងបាន ។ បេ ។ ញុំាងឆន្ទៈឲ្យកើតប្រឹងប្រែងប្រារព្ធនូវព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីបំពូននូវកុសលធម៌ដែលកើតមានឡើងហើយ ឲ្យស្ថិតនៅ មិនឲ្យវិនាស ឲ្យរឹតតែចំរើន ធំទូលាយពោរពេញឡើង ។

អយំ វុច្ចតិ ភិក្ខវេ សម្មាវាយាមោ = ម្នាលភិក្ខុទាំងឡាយ ព្យាយាម ៤ យ៉ាងនេះ តថាគតឲ្យឈ្មោះថា សម្មាវាយាមៈ ។

សេចក្ដីព្យាយាមទាំង ៤ យ៉ាងដូចបានរៀបរាប់មកនេះ ហៅថា សម្មប្បធាន ជាធម៌ថ្នាក់ទី ២ ក្នុងពួកពោធិបក្ខិយធម៌ ។ សម្មប្បធាន នេះ ន័យខ្លះកប់ផ្ដួចចុះគឺ:

១). សំវរប្បធាន ព្យាយាមក្នុងការប្រយ័ត្នមិនឲ្យបាបកើតឡើង;

២)- បហានប្បធាន ព្យាយាមក្នុងការលះបង់បាបដែលកើតឡើងហើយ ;

៣)- ភាវនាប្បធាន ព្យាយាមក្នុងការធ្វើកុសលឲ្យកើតឡើង ;

៤)- អនុរក្ខនាប្បធាន ព្យាយាមក្នុងការរក្សាទុកនូវកុសលធម៌ដែលកើតឡើងហើយ មិនឲ្យវិនាសសាបសូន្យទៅវិញ ។

សម្មប្បធានទាំង ៤ យ៉ាងនេះ បើនិយាយបំប្រួញឲ្យខ្លីចុះមក ដើម្បីឲ្យងាយស្តាប់ថា: ព្យាយាមបង្អាំងបាបថ្មី, កំចាត់បង់បាបចាស់, បណ្តុះបុណ្យថ្មី, បន្ថែមបុណ្យចាស់ ។

សូមបញ្ជាក់អំពីពាក្យថាបាបថ្មី, បាបចាស់, បុណ្យថ្មី, បុណ្យចាស់ជាមុន ។ ពាក្យថាបាបថ្មី, បុណ្យថ្មីនោះ បានដល់អំពើដែលកើតចេញឡើងតាមរយៈកាលកំណត់ពីត្រឹមបច្ចុប្បន្ននេះទៅអនាគត ។ ពាក្យថាបាបចាស់, បុណ្យចាស់នោះ បានដល់អំពើដែលជាប់នាំយកមកជាមួយនឹងជាតិ ឬអំពើដែលធ្វើរួចហើយ កំណត់ពីត្រឹមខាងក្រោយបច្ចុប្បន្ននេះ សាទៅខាងអតីត ។

អធិប្បាយ

សំវរប្បធាន ការព្យាយាមបង្អាំងបាបមិនឲ្យកើតឡើង ។ ពាក្យថា "បាប" ប្រែថា អំពើលាមក, អាក្រក់, ពុំប្រសើរ មានលំនាំកំណើតកើតមកពីរបស់: ការធ្វេសប្រហែស, ព្រោះនោះមានឈ្មោះ

ហៅបានច្រើនយ៉ាង ហៅថា កិលេស, ឧបកិលេស, ឧបធិកិលេស, សំយោជនៈ, មិច្ឆត្តៈ, មច្ឆរិយៈ, វិបល្លាសៈ, គន្ថៈ, អគតិ, អាសវៈ, ឱឃៈ, យោគៈ, នីវរណៈ, អនុសយៈ, មលៈ, អកុសល, ទុច្ចរិត ; ដែលមានឈ្មោះផ្សេងគ្នាយ៉ាងនេះ គឺនិយាយទៅតាមប្រភេទធម៌ ដែលព្រះសម្ពុទ្ធ- ជាធម្មសាមី ទ្រង់សំដែងញែកចែកដើម្បីចងក្រងឲ្យមានបន្ទាមគ្គស៊ើរស្រាប់ល្អប៉ុណ្ណោះ បើសំដៅត្រង់សម្បយុត្តធម៌ទាំងនេះវិញ ក៏សុទ្ធតែមានសម្ពសញ្ញាមកអាក្រក់ពុំប្រសើរ ដែលហៅថាបាបនោះឯង ។

បាបនោះបើកប់តែមេដែលធំ ៗ មាន ៣ យ៉ាង គឺ :

១)- លោភៈ ការជាប់ជំពាក់ក្នុងកាមារម្មណ៍ ;

២)- ទោសៈ សេចក្តីក្រោធខឹងប្រទូស្តរ៉ាយចំពោះសត្វនិងសង្ខារ;

៣)- មោហៈ សេចក្តីវង្វេងភាន់ច្រឡំមិនដឹងតាមសេចក្តីពិត ។

បើកប់ឲ្យពិស្តារបន្តិចទៅទៀតមាន ១០ យ៉ាង គឺ : ;

១)- លោភៈ ការជាប់ជំពាក់ក្នុងកាម ;

២)- ទោសៈ សេចក្តីក្រោធខឹងប្រទូស្ត ;

៣)- មោហៈ សេចក្តីវង្វេងភាន់ច្រឡំ ;

៤)- មានៈ សេចក្តីប្រកាន់ ;

៥)- ទិដ្ឋិ សេចក្តីយល់ខុស ;

៦)- វិចិកិច្ឆា សេចក្តីសង្ស័យ ;

៧)- ជីណំ ការស៊ុយស្រោក;

៨)- ឧក្កុំ សេចក្តីយយាយ;

៩)- អហិរិកំ សេចក្តីមិនខ្មាសអំពើអាក្រក់;

១០)- អនោត្តប្បំ សេចក្តីមិនខ្លាចក្រែងបាបទីធំអំពើអាក្រក់ ៗ

បើគប់ឲ្យល្អិតពិស្តារទៅទៀតមានមួយពាន់ប្រាំរយ (១.៥០០) គឺ យកចិត្ត ៨៩ គប់ជា ១, ចេតសិក ៥២, និប្ផន្នរូប ១៨, លក្ខណរូប ៤ រួមបញ្ចូលគ្នា (១+៥២+១៨+៤) ត្រូវជា ៧៥, ពាក់ជាធម្មរូបធម៌ខាងក្នុង ៧៥, ធម្មរូបធម៌ខាងក្រៅ ៧៥ រួមគ្នាជា ១៥០, យកកិលេស ១០ ជួបបានគប់មាតិកាខាងលើនុះមកគុណ (១៥០.×១០=១.៥០០) ត្រូវជា ១៥០០ ; នេះគប់តាមបែបអភិធម្មត្ថសង្គហៈ ៗ

ន័យមួយទៀតដែលមានក្នុងអដ្ឋកថាមហាពុទ្ធគុណ លោកឲ្យគប់ដូច្នេះ គឺយកលោកិយចិត្ត ៨១ គប់ជា ១, ចេតសិក ៥២, និប្ផន្នរូប ១៨, អកាសធាតុ ១, ជាតិ ១, ជរ ១, ភង្គ ១ រួមបញ្ចូលគ្នា (១+៥២+១៨+១+១+១+១=៧៥) ត្រូវជា ៧៥ ពាក់ជាកិលេសខាងក្នុង ៧៥ ខាងក្រៅ ៧៥ ត្រូវជា ១៥០ យកកិលេស ១០ មកគុណ (១៥០×១០=១៥០០) ត្រូវជា ១.៥០០; កិលេសទាំងនេះហើយដែលហៅថា "បាប" ៗ

បាបជាគូប្រឆាំងនឹងបុណ្យ គឺជាគូបដិបក្ខដល់គ្នានឹងគ្នា កុំដែលកើតទៀនព្រមគ្នានៅពេលជាមួយគ្នាឡើយ, បើបាបកើតហើយ បុណ្យក៏ក

ឱកាសកើតឡើងពុំបាន បើបុណ្យកើតឡើងហើយ បាបក៏គេឱកាសកើតឡើងពុំបាន ។ បាបនឹងបុណ្យទាំងពីរនេះ តែងនៅប្រចាំវេនទ្វារទាំងបី គឺកាយទ្វារ, វចីទ្វារ, មនោទ្វារ ជានិច្ចកាល ឃ្លាំចាំមើលតែឱកាស, បើបុណ្យឃ្លាតចេញ បាបក៏កើតឡើង, បាបឃ្លាតចេញបុណ្យក៏កើតឡើងឥតបន្ទន់ឲ្យមានវិស្សមោកាសឡើយ ។

ដូចនេះសមនឹងព្រះពុទ្ធដីកា ដែលព្រះមានព្រះភាគសំដែងថា :

អញ្ញំ ឧប្បជ្ជតេ ចិត្តំ អញ្ញំ ចិត្តំ និរុជ្ឈតិ
អវីចិមនុសម្ពន្ធោ នទីសោតោវ វត្តតិ ។

សេចក្តីថា ចិត្តដទៃកើតឡើង ចិត្តដទៃរលត់ទៅ ប្រហែលគ្នានឹងខ្សែទឹកនទីដែលប្រព្រឹត្តជាប់ទៅតាមខ្សែទឹកដែលឥតមានរលក ព្រោះហេតុនោះ ពាក្យថា បន្ទាំងបាបមិនឲ្យកើត ត្រូវយកសុចរិតទាំងបីដែលជាគូបុណ្យទៅបន្ទាំងកាំងទ្វារទាំងបីគឺ យកកាយសុចរិតទៅកាំងកាយទ្វារ, វចីសុចរិតទៅកាំងវចីទ្វារ, មនោសុចរិតទៅកាំងមនោទ្វារ ហើយត្រូវព្យាយាមរក្សាសុចរិតទាំងបីនោះឲ្យខ្ជាប់ខ្ជួនកុំឲ្យធ្លុះធ្លាយទ្វារណាមួយ; បើបានព្យាយាមរក្សាសុចរិតទាំងបីឲ្យខ្ជាប់ខ្ជួនដរាបណា ឈ្មោះថា បានបន្ទាំងបាបមិនឲ្យកើតឡើងដរាបនោះ ។

ពាក្យថា "ព្យាយាមបន្ទាំងបាបមិនឲ្យកើតឡើង" នេះ មានន័យខ្លះលោកអធិប្បាយច្រើនជាអនេកពេកណាស់ សូមបណ្ឌិតអ្នកបរិបូណ៌ ដោយ

យោបល់ពិចារណាតទៅទៀតចុះ ។

បហានប្បធាន ការព្យាយាមកំចាត់បង់នូវបាបចាស់ដែលកើតឡើងហើយឲ្យជ្រះស្រឡះពីខន្ធសន្តាន បានដល់សេចក្តីព្យាយាមក្នុងការលះ ៣ យ៉ាងដែលហៅថា បហានៈគឺ:

១)- តទង្គប្បហានៈ ការលះកិលេស, លះបាបដោយអង្គនោះ ៗ គឺសំដៅយកការលះកិលេសដោយអំណាចសីល ។

ពាក្យថា "លះកិលេសដោយអង្គនោះៗ" គឺបើបុគ្គលណាបានសង្រួមរក្សានូវក្រុមសីលណា ៗ, នូវសិក្ខាបទណា ៗ ឲ្យបរិសុទ្ធហ្មត់ចត់ហើយ កិលេសគឺសេចក្តីសៅហ្មងដក់ខន្ធសន្តានដែលហៅថាបាប ក៏វិនាសសាបសូន្យទៅដោយអំណាចសីលនោះ ៗ, សិក្ខាបទនោះ ៗ ក្លាយជាបុគ្គលដែលរក្សាសីលទាំង៥ មានវៀរចាកបាណាតិបាតជាដើម ជាអ្នកយកចិត្តទុកដាក់មិនប្រហែសធ្វេស ប្រយ័ត្នមិនឲ្យធ្លុះធ្លាយក្នុងគ្រណាមណាមួយ ទោសពៀរគឺសេចក្តីសៅហ្មងទាំង៥ ក៏សាបសូន្យឃ្លាតចាកខន្ធសន្តានរបស់បុគ្គលនោះដោយអំណាចសីលទាំង៥នោះឯង ។ នេះឈ្មោះថាការកំចាត់បង់នូវកិលេសអកើនកក់ៗស្រាលស្តើង, បើសំដែងឲ្យជ្រៅដល់កំរិតធម៌ពេញលក្ខណៈ ពាក្យថាលះដោយអង្គនោះ ៗ ដែលហៅថាតទង្គប្បហានៈនោះ ក្នុងគម្ពីរសុមង្គលវិលាសិនីបហារត្តណា ដែលសំដែងអំពីវិមុត្តិ៥នោះថា: តទង្គប្បហានៈ សំដៅយកអនុបស្សនាទាំង៧ ដែលអ្នកមានសីលដ៏បរិសុទ្ធ

យកមកពិចារណា ដើម្បីកំចាត់បង់នូវកិលេសគឺបាបធម៌ទាំងនោះឯង ។

អនុបស្សនា ៧ នោះ គឺ:

(១)- អនិច្ចតោ អនុបស្សន្តោ និច្ចសញ្ញំ បជហាតិ ព្រះយោគាវចរអ្នកមានសីលបរិសុទ្ធ ពិចារណាឃើញច្បាស់នូវបញ្ចក្ខន្ធ ដោយអនិច្ចលក្ខណៈ រមែងលះបង់នូវនិច្ចសញ្ញា (សេចក្ដីសំគាល់ថាទៀង);

(២)- ទុក្ខតោ អនុបស្សន្តោ សុខសញ្ញំ បជហាតិ ព្រះយោគាវចរអ្នកមានសីលបរិសុទ្ធ ពិចារណាឃើញច្បាស់នូវខន្ធទាំង ៥ ដោយទុក្ខលក្ខណៈ រមែងលះបង់នូវសុខសញ្ញា (សេចក្ដីសំគាល់ថាសុខ);

(៣)- អនត្តតោ អនុបស្សន្តោ អត្តសញ្ញំ បជហាតិ ព្រះយោគាវចរពិចារណាឃើញច្បាស់នូវខន្ធ ៥ ដោយអនត្តលក្ខណៈ រមែងលះបង់នូវអត្តសញ្ញា (សេចក្ដីសំគាល់ថាខ្លួន, ថារបស់ខ្លួន);

(៤)- និព្វិទតោ អនុបស្សន្តោ នន្ទឹ បជហាតិ ព្រះយោគាវចរកាលនឿយណាយបណ្ដើរ ពិចារណាបណ្ដើរនូវខន្ធ ៥ រមែងលះបង់នូវតណ្ហាប្រកបដោយសេចក្ដីត្រេកអរ ប្រព្រឹត្តទៅដោយបីតិ;

(៥)- វិរាគតោ អនុបស្សន្តោ រាគំ បជហាតិ ព្រះយោគាវចរកាលប្រាសចាកតម្រេកបណ្ដើរ ពិចារណាឃើញបណ្ដើរនូវខន្ធ ៥ រមែងលះបង់នូវរាគៈ;

(៦)- និរោធតោ អនុបស្សន្តោ សមុទយំ បជហាតិ

ព្រះយោគាវចរកាលរំលត់បណ្ដើរពិចារណាបណ្ដើរនូវខន្ធ ៥ រមែងលះបង់នូវសមុទយៈ ;

(៧)–បដិនិស្សគ្គា អនុបស្សនា អាទានំ បជហតិ ព្រះគាវចរកាលរលាស់ចោលបណ្ដើរពិចារណាបណ្ដើរនូវខន្ធ ៥ រមែងលះបង់នូវសេចក្ដីប្រកាន់ ប្រមូលប្រកៀកនូវខន្ធ ៥ ។

ការផលលះកិលេសតាមជាក់តាមអង្គដូចបានរៀបរាប់មកនេះ ហៅជា តទង្គប្បហានៈ ប្រែថា ការលះកិលេស, លះបាបដោយអង្គនោះ ៗ គឺ បើនិយាយពីវិមុត្តិវិញ ហៅថា តទង្គវិមុត្តិ ការរួចស្រឡះចាកកិលេសដោយអង្គនៃធម៌នោះ ៗ ។ អនុបស្សនាទាំង ៧ នេះ ក្នុងគម្ពីរវិសុទ្ធិមគ្គគ្រន់ ដែលសំដែងអំពីលោកិយបរិញ្ញា ៣ គឺញាតបរិញ្ញា ១, តីរណបរិញ្ញា ១, បហានបរិញ្ញា ១ នោះលោកចាត់ជាអង្គរបស់បហានបរិញ្ញា ។

លោកិយបរិញ្ញា ការកំណត់ដឹងនូវធម៌ជាលោកិយ គឺ: ញាតបរិញ្ញា ការកំណត់ដឹងនូវធម៌ដែលខ្លួនធ្លាប់ដឹងហើយ, តីរណបរិញ្ញា ការកំណត់ដឹងនូវធម៌ដោយការពិចារណា, បហានបរិញ្ញា ការកំណត់ដឹងនូវធម៌ដោយកិរិយាលះបង់នូវធម៌ដែលខ្លួនគួរលះបង់ ។

ពាក្យថា “លះកិលេសដោយអំណាចសីល” នោះ សីលនេះមានច្រើនក្រុមច្រើនជាន់ ពុំបាននាំមកអធិប្បាយក្នុងទីនេះទេ សូមបណ្ឌិតជ្រាបតាមបែបក្នុងគម្ពីរវិសុទ្ធិមគ្គគ្រន់សីលនិទ្ទេស ឬសៀវភៅសីលនិទ្ទេស

សង្ខេបឯណោះផងចុះ ។

សីលនេះបើបុគ្គលណាបានញុំាងផ្នួះឲ្យកើត ប្រឹងប្រែងព្រមពេញ ព្យាយាម ផ្ចិតទុក តាំងព្យាយាមមាំ ថែរក្សាមិនឲ្យធ្លុះធ្លាយ ទំផុតផ្តួនឲ្យបានបរិសុទ្ធហ្មត់ចត់ល្អហើយ តែបើកាត់បង់នូវកិលេស គឺបាបតាស់របស់បុគ្គលនោះបានច្រើនយ៉ាង មានកំចាត់បង់នូវបាបធម៌ ១៦ ជាដើមគឺ :

(១)- កោធោ សេចក្ដីក្រោធ មានការខឹងជាលក្ខណៈ ;

(២)- ឧបនាហោ ការចងពៀរមានកិរិយាគុំទុកជាលក្ខណៈ ;

(៣) មក្ខោ ការមើលគុណ មានការលុបគុណរបស់បុគ្គលដទៃជាលក្ខណៈ ;

(៤)- បលាសោ ការប្រណាំងប្រជែង មានការកាន់យកនូវគូ (គឺផ្ទឹមគូ) ជាលក្ខណៈ ;

(៥)- ឥស្សា សេចក្ដីឫស្សា មានការច្រណែននូវសម្បត្តិរបស់បុគ្គលដទៃជាលក្ខណៈ ;

(៦)- មច្ឆរិយំ សេចក្ដីកំណាញ់ មានការលាក់លៀមនូវសម្បត្តិរបស់ខ្លួនជាលក្ខណៈ ;

(៧)- មាយា ការលាក់លៀមនូវអំពើទុច្ចរិត មានការបិទបាំងនូវទោសជាលក្ខណៈ ;

(៨)- សាឋេយ្យំ សេចក្ដីអួតអាង មានការសរសើរគុណរបស់

ខ្លួនតាំងមិនមានជាលក្ខណៈ ;

(...)- ប្រាជ្ញា ការរឹងប្អូន មានការតាំងចិត្តរឹងប៉ឹងជាលក្ខណៈ ;

(...)- ... ឱ្យហ៊ុំព័ទ្ធប្រព្រឹត្តទៅព្រមគ្នាបាន. មានចិត្តរើក

មានការមិនខ្វល់ខ្វាយ ... ជាលក្ខណៈ ;

(៦៦)- មានៃជា សំគាល់ សំគាល់ខ្លួន មានការយកចិត្តទុក

ដាក់ខ្លួនជាលក្ខណៈ ;

(៦៧)- អតិមានៈ សំគាល់ សំគាល់ខ្លួនដាក់ក្រោមគេ មានការ

កើតមិនមានខ្លួនដាក់ក្រោមគេជាលក្ខណៈ ; មិនសប្បាយ ;

(១៨)- មេត្តា សេចក្ដីស្រឡាញ់ មានហេតុជាគ្រឿងស្រឡាញ់ជា

លក្ខណៈ ;

(១៩)- ករុណា សេចក្ដីប្រណី មានការចង់ជួយឱ្យផុតទុក្ខជា

លក្ខណៈ ;

សីលដែលបុគ្គលគប្បីរក្សាប្រតិបត្តិហើយ មិនត្រឹមតែកំចាត់បង់

នូវអំពើអាក្រក់ប៉ុណ្ណោះទៀយ តែមិនត្រឹមតែប៉ុណ្ណោះ ថែមទាំងដុះដាលសេចក្ដី

ល្អផ្សេងៗ ទៅទៀត ដូចព្រះពុទ្ធដីកាដែលព្រះសម្មាសម្ពុទ្ធទ្រង់ដឹកនាំ

តម្រង់អ្នកទាំងឡាយ ឱ្យសីលជាធំ ដើម្បីកំចាត់បង់នូវវិប្បដិសារៈ គឺ

សេចក្ដីក្ដៅក្រហាយក្នុងពេលក្រោយ ហើយឱ្យកើតអវិប្បដិសារៈ គឺសេចក្ដីមិន

ក្ដៅក្រហាយ ដែលនាំឱ្យកើតបាមោជ្ជៈ ជាដើមតរៀងៗដែល

នៅក្នុងបីភពដ៏មានកម្លាំងខ្លាំង, នាំឲ្យកើតបីតិ បានដល់បីតិដ៏មានកម្លាំង បាន សេចក្តីត្រេកអរខ្លាំងជាការនាំឲ្យកើតបដិប្បស្សទ្ធិ សេចក្តីស្ងប់កាយស្ងប់ចិត្ត, នាំឲ្យកើតសុខ សេចក្តីស្រួលកាយសប្បាយចិត្ត, នាំឲ្យកើតសមាធិ ការដំកល់ចិត្តមាំក្នុងកុសលធម៌, នាំឲ្យកើតយថាភូតញាណទស្សនៈ ការឃើញនូវសភាវធម៌ដោយប្រាជ្ញាដែលនៅក្នុងខ្លួនរាងកាយ, នាំឲ្យកើតនិព្វិទា វិបស្សនាដ៏មានកម្លាំង, នាំឲ្យកើតវិរាគៈ គឺមគ្គ, នាំឲ្យកើតវិមុត្តិញាណទស្សនៈ គឺការរួចស្រឡះចាកកិលេសដោយអរហត្តមគ្គ និងការពិចារណាឲ្យជាក់ច្បាស់ ៗ ដែលបានឡើងដល់ថ្នាក់ជាលំដាប់យ៉ាងនេះ គឺបានដោយអំណាចរបស់សីល ៗ ន័យមួយទៀតថា សីលអាចនាំបុគ្គលដែលបានរក្សាដោយប្រពៃឲ្យសម្រេចដល់ថ្នាក់ជាសោតាបន្នបុគ្គល និងសកទាគាមីបុគ្គល ៗ បើបានឡើងដល់ថ្នាក់ជាអរិយបុគ្គលទាំងពីរពួកនេះហើយ កិលេស គឺបាបចាស់ ក៏ឈ្មោះថាបានកំចាត់បង់ហើយដោយស្រេច ៗ

២)– វិក្ខម្ភនប្បហានៈ ការលះអកុសលធម៌ទាំងឡាយមានកាមច្ឆន្ទៈជាដើម ដែលស្ថិតនៅប្រចាំក្នុងចិត្ត ដោយសង្កត់សង្កិន ៗ ការកំចាត់បង់នូវបរិយុដ្ឋានកិលេស គឺកិរិយាសង្កត់សង្កិននូវបរិយុដ្ឋានកិលេសឲ្យកុំផុសឡើងក្នុងសន្តាន ឈ្មោះថា វិក្ខម្ភៈ ៗ

ពាក្យថា "វិក្ខម្ភនប្បហានៈ" នេះ ក្នុងមហាវគ្គ សំដៅយកសមាបត្តិទាំង ៨ គឺរូបជ្ឈាន ៤, អរូបជ្ឈាន ៤ ។ សមាបត្តិទាំង ៨ នេះកើតឡើងដោយ

អំណាចសមាធិ បើគ្មានសមាធិ សមាបត្តិក៏មិនមាន ព្រោះហេតុនោះក្នុងឋានៈនេះ ទើបលោកប្រាប់ថា លះកិលេសដោយអំណាចនៃសមាធិ ។

ឯពាក្យថា សមាធិនេះ ពុំបានអធិប្បាយក្នុងទីនេះទេ សូមបណ្ឌិតជ្រាបតាមបែបក្នុងគម្ពីរវិសុទ្ធិមគ្គត្រង់សមាធិនិទ្ទេស ឬក្នុងសៀវភៅសមាធិនិទ្ទេសសង្ខេបឯណោះចុះ ។

ក្នុងទីនេះ នឹងសំដែងឲ្យឃើញតែអំពីពួកកិលេសខ្លះ ដែលសមាធិអាចកំចាត់បង់បានប៉ុណ្ណោះ ។ សមាធិនេះអាចកំចាត់បង់នូវកិលេសបានច្រើនយ៉ាង តែក្នុងទីនេះនឹងទាញយកកិលេសដែលសមាធិកំចាត់បង់បានដោយសមាបត្តិទាំង ៨ មកសំដែងឲ្យឃើញជាគូយ៉ាង ។

សមាបត្តិ ៨ នោះគឺ :

(១)- បឋមជ្ឈានសមាបត្តិ ការបានសម្រេចនូវរូបជ្ឈានទី ១ ;

(២)- ទុតិយជ្ឈានសមាបត្តិ ការបានសម្រេចនូវរូបជ្ឈានទី២;

(៣)- តតិយជ្ឈានសមាបត្តិ ការបានសម្រេចនូវរូបជ្ឈានទី៣;

(៤)- ចតុត្ថជ្ឈានសមាបត្តិ ការបានសម្រេចនូវរូបជ្ឈានទី៤;

(៥)- អាកាសានញ្ចាយតនជ្ឈានសមាបត្តិ ការបានសម្រេចនូវអាកាសានញ្ចាយតនជ្ឈាន ;

(៦)- វិញ្ញាណញ្ចាយតនជ្ឈានសមាបត្តិ ការបានសម្រេចនូវវិញ្ញាណញ្ចាយតនជ្ឈាន ;

(៧)- អាកិញ្ចញ្ញាយតនជ្ឈានសមាបត្តិ ការបានសម្រេចនូវអាកិញ្ចញ្ញាយតនជ្ឈាន ;

(៨)- នេវសញ្ញានាសញ្ញាយតនជ្ឈានសមាបត្តិ ការបានសម្រេចនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ។

សមាបត្តិទាំង ៨ នេះកំចាត់បង់នូវកិលេសបានដូច្នេះ គឺ:

បឋមជ្ឈានសមាបត្តិ កំចាត់បង់នូវនីវរណបក្កិលេសទាំង ៥ គឺ:

(១)- កាមច្ឆន្ទៈ: សេចក្ដីពេញចិត្តត្រេកត្រអាលក្នុងកាមគុណ ៥ គឺ រូប, សម្លេង, ក្លិន, រស, សម្ផស្ស ;

(២)- ព្យាបាទ: សេចក្ដីគុំគួនដល់ជនដទៃប្រាថ្នាឲ្យគេវិនាស ;

(៣)- ថីនមិទ្ធៈ: (១)សេចក្ដីធុញទ្រាន់នឹងសេចក្ដីងុយងោក ;

(៤)- ឧទ្ធច្ចកុក្កុច្ចៈ: សេចក្ដីរាយមាយចិត្តនឹងសេចក្ដីក្ដៅក្រហាយចិត្ត ;

(៥) វិចិកិច្ឆា សេចក្ដីសង្ស័យ គឺការស្ទាក់ស្ទើរមិនប្រះស្រាយ ចំស-

---

១ សេចក្ដីលក់ប្រកបដោយថីនមិទ្ធៈ ភាពនៃកិរិយាប្រជុំប្រមូលឈ្មោះថា ថីនៈ ព្រោះភាពនៃកិរិយាប្រជុំប្រមូលនូវសេចក្ដីមិនឧស្សាហ៍ និងសេចក្ដីខ្ជិលច្រអូសបានដល់ចិត្ត ព្រោះចិត្តដែលប្រកបដោយថីនៈ មានសេចក្ដីមិនឧស្សាហ៍ជាដើម, ភាពនៃថីនចិត្តនេះឈ្មោះថាថីនៈ ។ សេចក្ដីលក់ប្រកបដោយមិទ្ធៈ ជាផលដល់ចិត្ត ព្រោះចិត្តនោះ ប្រកបហើយនឹង... ការប្រមូលបង្រួមអកុសលធម៌ ព្រោះភាពនៃការប្រមូលមកនូវសេចក្ដីមិនឧស្សាហ៍ និងសេចក្ដីខ្ជិលច្រអូសឈ្មោះថាមិទ្ធៈ ។ ការកំចាត់បង់នូវសេចក្ដីមិនរឹងប៉ឹងឈ្មោះថា មិទ្ធៈ ។

ពាសគំនិត ។

ទុតិយជ្ឈានសមាបត្តិ កំចាត់បង់នូវវិតក្កៈ នឹងវិចារៈ ។

តតិយជ្ឈានសមាបត្តិ កំចាត់បង់នូវបីតិ ។

ចតុត្ថជ្ឈានសមាបត្តិ កំចាត់បង់នូវសុខៈ ។

អាកាសានញ្ចាយតនជ្ឈានសមាបត្តិ កំចាត់បង់នូវអារម្មណ៍ក្នុងរូបជ្ឈានទី ៤ ។

វិញ្ញាណញ្ចាយតនសមាបត្តិ កំចាត់បង់នូវអាកាសានញ្ចាយតនសញ្ញា ។

អាកិញ្ចញ្ញាយតនសមាបត្តិ កំចាត់បង់នូវវិញ្ញាណញ្ចាយតនសញ្ញា ។

នេវសញ្ញានាសញ្ញាយតនសមាបត្តិ កំចាត់បង់នូវអាកិញ្ចញ្ញាយតនសញ្ញា ។

សមាបត្តិដែលបុគ្គលព្យាយាមចំរើនបានហើយដោយប្រពៃ មិនត្រឹមតែកំចាត់បង់នូវកិលេសដូចបានពោលមកប៉ុណ្ណោះឡើយ តែងបានសម្រេចនូវគុណវិសេសច្រើនជាអនេកតទៅទៀត ដូចយ៉ាងដែលមាននៅក្នុងវិសុទ្ធិមគ្គប្បករណៈថា សមាធិជាមូលនិស្ស័យឲ្យបាននូវអភិញ្ញា ៦ និងកន្ទ្រាបបង់នូវកាមធាតុខាងក្រោម ទាំងបាននូវភាពជាអរិយបុគ្គល, បើបានសម្រេចដល់ជាន់អនាគាមីបុគ្គលហើយ កិលេសគឺបាបធម៌ក៏ឈ្មោះថាបានកំចាត់ផ្ដាច់

ហើយដោយច្រើន ។

៣)- សមុច្ឆេទប្បហានៈ: ការលះកិលេសដោយអរិយមគ្គជាគ្រឿងគាស់រំលើង បានដល់ការលះកិលេសឲ្យអស់រលីងមិនឲ្យកើតទៀត ដោយអរិយមគ្គញាណគឺបញ្ញា ។

ពាក្យថា សមុច្ឆេទប្បហានៈនេះ គឺសម្ដែងបរិយាយនិងអដ្ឋកថា ទីឃនិកាយ សំដៅយកអរិយមគ្គទាំង ៤ គឺ សោតាបត្តិមគ្គ, សកទាគាមិមគ្គ, អនាគាមិមគ្គ, អរហត្តមគ្គ ព្រោះមគ្គទាំងបួននេះហើយដែលជាគុណជាតិវិសេសបំផុតក្នុងការគាស់រំលើងនូវកិលេស គឺផ្ដាច់ផ្ដិលដាច់ផេកព្រាំងនៅក្នុងខន្ធសន្តានរបស់បុថុជ្ជនបុគ្គលទាំងឡាយក្នុងត្រកូល ។ មគ្គទាំង ៤ នេះ បើនិយាយពីវិមុត្តិវិញ ហៅថា សមុច្ឆេទវិមុត្តិ ការប ស្រឡះចាកកិលេសដោយមគ្គ ជាគ្រឿងគាស់រំលើងពាលលែងឲ្យកើតតទៅទៀត ។

បុគ្គលដែលបានសម្រេចនូវមគ្គទាំង ៤ នេះ គេក៏បានស្រង់យកសេចក្ដីក្សេម មកពីការបំពេញបារមី ព្រោះហេតុតែការបានបហានៈនេះ លោកប្រាប់ថាលះកិលេស ដោយអរិយមគ្គញាណគឺបញ្ញា ។

ពាក្យថា បញ្ញានេះ មិនមែនគ្រាន់តែការរៀនព្យាយេក្ខង់ចេះ ២០ ស៊ុម បណ្ឌិតប្រាប់តាមវេបកក្នុងគម្ពីរសុត្តន្ត ក្រៃបញ្ញាដទៃ ឬ ក្នុងសៀវភៅ បញ្ញាដែលឆ្លៀតឆ្លាតគិតឯណានុះ ។

កិលេសគឺបាបធម៌ដែលមគ្គទាំង ៤ មានសោតាបត្តិមគ្គជាដើមត្រូវកំចាត់បង់ គឺមគ្គណាត្រូវកំចាត់បង់នូវកិលេសប្រភេទណា នោះមានអធិប្បាយក្នុងអង្គមគ្គទី ១ គឺសម្មាទិដ្ឋិនោះរួចហើយ សូមប្រាប់តាមន័យនោះចុះ ។

ពាក្យថា ព្យាយាមកំចាត់បាបធម៌ដែលកើតឡើងហើយឲ្យវិនាសទៅវិញនោះ មានសេចក្តីអធិប្បាយផ្សេងដោយឡែកពីន័យនេះដោយច្រើនទៀត សូមបញ្ជាក់អ្នកបរិបូណ៌ដោយយោបល់ពិចារណាតទៅទៀតចុះ ។

បហានៈ ៣ នេះ ន័យខ្លះលោកបកប្រែគឺ :

(១)- វីតិក្កមប្បហានៈ: ការលះបង់នូវវីតិក្កមកិលេសដែលជាសត្រូវដល់សីល ;

(២)- បរិយុដ្ឋានប្បហានៈ: ការលះបង់នូវបរិយុដ្ឋានកិលេសដែលជាសត្រូវដល់សមាធិ;

(៣)- អនុសយប្បហានៈ: ការលះបង់នូវអនុសយកិលេសដែលជាសត្រូវដល់បញ្ញា ។

វីតិក្កមប្បហានៈជាគូនឹងតទង្គប្បហានៈ ចាត់ជាវិនយបិដក ។ បរិយុដ្ឋានប្បហានៈជាគូនឹងវិក្ខម្ភនប្បហានៈ ចាត់ជាសុត្តន្តបិដក ។ អនុសយប្បហានៈជាគូនឹងសមុច្ឆេទប្បហានៈ ចាត់ជាអភិធម្មបិដក ។

៣) ភាវនាបធានៈ: ព្យាយាមបណ្ដុះបុណ្យថ្មី គឺព្យាយាមញ៉ាំងកុសលណាដែលមិនទាន់កើតឲ្យកើតឡើង ។

ពាក្យថាបុណ្យ ប្រែថា គុណជាតកើតក្នុងសន្តានឯណា ហើយ ជម្រះនូវសន្តាននោះ មានជាតិកំណើតកើតគត់ពិសេសៗ: ការមិនធ្វេស ប្រហែស ។ បុណ្យនោះ មានឈ្មោះហៅច្រើនយ៉ាង ហៅថា កុសល, សុចរិត, ទាន, សីល, ភាវនា, ឈាន, សមាបត្តិ, វិមុត្តិ, មគ្គ, ផល ។

ដែលមានឈ្មោះហៅផ្សេងគ្នាយ៉ាងនេះ គឺនិយមទៅតាមប្រភេទធម៌ ដែលព្រះសព្វញ្ញូជាម្ចាស់ទ្រង់សំដែងចែក ដើម្បីចងក្រងឲ្យមានចក្រោម ស្ទើស្រប់តាមល្អ កុំឲ្យច្របូកច្របល់គ្នាប៉ុណ្ណោះ បើសំដៅត្រង់សម្មស្សធម៌ តាំងនេះវិញ គឺសុទ្ធតែមានសម្មស្សណ្ណជាគ្រឿងជម្រះសន្តានចិត្ត អាច ញ៉ាំងសេចក្តីសុខ, សេចក្តីចំរើនរុងរឿងដែលហៅថា បុណ្យនោះឯងឲ្យកើតមានឡើង ។

២)- អនុរក្ខណបធាន ព្យាយាមបង្កើនបុណ្យចាស់ មុខផល ការថែរក្សាកុសលធម៌ទាំងឡាយមានទាន, សីល, ភាវនាជាដើម ដែល ធ្លាប់បានរក្សា, បានធ្វើ, បានចំរើនមកហើយ, ការថែរក្សានោះគឺត្រូវញ៉ាំង ឆន្ទៈឲ្យកើត, ប្រឹងប្រែង, ប្រារព្ធព្យាយាម, ចួនចិត្តមុត, តាំងព្យាយាមរក្សា ចំពោះកុសលកម្មដែលធ្លាប់បានធ្វើ, បានចំរើនមកហើយមិនឲ្យសាបសូន្យ កុំបណ្តោយឲ្យធម៌ដែលជាសត្រូវទាំងឡាយពាលមកកៀរគៀនបៀនចិត្តបាន ឡើយ កាលបើសត្រូវចូលមកបៀតបៀនចិត្តមិនបានហើយ កុសល-កម្មមានទាន, សីល, ភាវនាជាដើម កើនចំរើនល្អគ្រប់ស្រុះតាមឡើង

តាមលំដាប់កាល ៗ ឯការដែលរក្សានូវកុសលកម្មដែលបានធ្វើ, បានចំរើនហើយកុំឲ្យវិនាសទៅវិញ តាំងឲ្យបានចំរើនលូតលាស់ដុះដាលថែមឡើងទៀតនោះ កុំមានធម៌អ្វីវិសេសជាងសតិសម្បជញ្ញៈឡើយ ៗ ព្រោះធម៌ទាំងពីរនេះ ជាធម៌មានឧបការៈច្រើន ព្រះសម្មាសម្ពុទ្ធទ្រង់សំដែងក្នុងគម្ពីរសំយុត្តនិកាយ មហាវគ្គ នឹងគម្ពីរអង្គុត្តរនិកាយសត្តកនិបាត ថាសតិទុកដូចជានាយសារថី, ដូចជាឆ្មាំទ្វារ, ធម្មតានាយសារថីក្តី, អ្នកឆ្មាំ-ទ្វារក្តី សុទ្ធតែជាអ្នកប៉ិនប្រសប់ក្នុងការថែរក្សា ៗ នាយសារថី បើមិនធ្លាក់ក្នុងការបរ ក៏មិនអាចរក្សាសន្ទុះរបស់រថឲ្យលឿនទៅបានស្រួល ៗ អ្នកឆ្មាំទ្វារ បើមិនធ្លាក់ក្នុងការមើលលក្ខណៈមនុស្សអ្នកចេញចូលទេក៏មិនអាចរក្សានូវសេចក្តីសុខ នឹងទ្រព្យសម្បត្តិបានឡើយ យ៉ាងណាមិញ សតិ-សម្បជញ្ញៈនោះក៏ជាធម៌វិសេសបំផុតក្នុងការរក្សាកុសលធម៌ដូច្នោះដែរ ៗ

សតិ ប្រែថា សេចក្តីរលឹក, ធម្មជាតិជាគ្រឿងរលឹក, ចៀ ចៀននូវសេចក្តីប្រមាទ, ដំណើររបៀករបៀនគំនិតជាដើម ៗ

សម្បជញ្ញៈ ប្រែថា សេចក្តីដឹងខ្លួន (គឺការមិនភ្លេចខ្លួន) បញ្ញាដឹងជុំខ្លួន ៗ

រួមសេចក្តីទាំងពីរនេះចូលគ្នាជាសតិសម្បជញ្ញៈ ប្រែថា ការដឹងខ្លួនដោយការរលឹកឃើញ, ធម៌ទាំងពីរនេះប្រព្រឹត្តទៅក្នុងកិច្ចជាមួយគ្នា ផ្សេងតែអាការៈ គឺសតិ ជាភ្នាក់ងារខាងឯនឹកឃើញ ក្នុងវេលាដែលធ្វើហើយ,

និយាយហើយ, គិតហើយ, ពោះបើធ្វើ-និយាយ-គិត យូរៗហើយក៏នឹក ឃើញបាន; សម្បជញ្ញៈ ជាភ្នាក់ងារនាំឲ្យដឹងខ្លួនក្នុងវេលាដែលកំពុងធ្វើ, កំពុងនិយាយ, កំពុងគិត ។

សតិសម្បជញ្ញៈ នេះ បើបានកើតឡើងក្នុងសន្តានចិត្តរបស់បុគ្គល ណាហើយ បុគ្គលនោះរមែងស្គាល់នូវអំពើល្អ អាក្រក់ច្បាស់លាស់ ហើយ ជ្រើសរើសកាន់យកតែអំពើណាដែលល្អ ៗ ដែលជាហេតុនាំឲ្យកើតសេចក្តី ចំរើនដល់ខ្លួននិងបុគ្គលដទៃ, ឯអំពើអាក្រក់ដែលជាសត្រូវដល់កុសលធម៌ ទាំងប៉ុន្មាន មិនអាចចូលទៅលុកលុយញាំញីឲ្យខូចកុសលធម៌របស់អ្នក មានសតិសម្បជញ្ញៈនោះបានឡើយ; កាលបើអកុសលធម៌ទាំងឡាយចូល ទៅញាំញីមិនបានហើយ កុសលធម៌ដែលបានធ្វើហើយក្តី, កំពុងតែធ្វើ ក៏មានកម្លាំងល្អណាស់ដុះដាលចំរើនឡើងឥតគាក់ ៗ ប្រៀបដូចផល- ផ្កាដែលកើតក្នុងទឹក មានឈូកសនិងឈូកក្រហមជាដើម ដែលដុះក្នុង ត្រពាំង, បឹង, ស្រះ, បើត្រពាំង-បឹង-ស្រះនោះមានអ្នកគ្រប់គ្រងថែរក្សាល្អ មិនធ្វេសប្រហែសបណ្តោយឲ្យសត្វជាសត្រូវទៅជិះជាន់-ស៊ី-ពោះ-ដើម- ស្លឹកនិងត្រយបានហើយ ផលជាតិទាំងឡាយនោះក៏មានដើមទងផ្កាផ្លែ ល្អណាស់ដុះល្អចំរើនឡើងឥតគាក់ យ៉ាងណាមិញ ពាក្យថា បានក្តីបុណ្យ ក៏ដូច្នោះដែរ ។

សន្តោសេមៈ ពាក្យក្រោមត្រៃនេះ អធិប្បាយដោយសេចក្តី

បំប្រួញមក៏ទៀតថា សេចក្តីព្យាយាមលះបាប, អកុសល, ទុច្ចរិត, ដោយផ្លូវកាយ, វាចា, គឺបានដល់ការព្យាយាមថែរក្សាកាយវាចាមិនឲ្យប្រព្រឹត្តកន្លងធ្លុះធ្លាយនូវសិក្ខាបទ ៥ គឺ និច្ចសីល, សិក្ខាបទ ៨ គឺ ឧបោសថសីល, សិក្ខាបទ ១០ គឺអតិរេកសីល និងសិក្ខាបទ ២២៧ របស់បព្វជិត ដែលកើតឡើងចំពោះកាយនិងវាចានោះ ហៅថា ព្យាយាមលះបាប អកុសល ទុច្ចរិតដោយផ្លូវកាយវាចា ។ ព្យាយាមលះបាប, អកុសល, ទុច្ចរិត ដែលកើតឡើងដោយផ្លូវចិត្តនោះ បានដល់ការព្យាយាមចំរើនមេត្តាភាវនាឲ្យកើតមានឡើង លះបង់ ឬរំលត់នូវចិត្តព្យាបាទ, ចំរើនអសុភសញ្ញា លះបង់ ឬរំលត់នូវកាមច្ឆន្ទៈ, ចំរើនអានាបានស្សតិ លះបង់ ឬរំលត់នូវឧទ្ធច្ចកុក្កុច្ចៈ, ព្យាយាមចំរើនកាយគតាសតិកម្មដ្ឋាន ដំកល់ចិត្តឲ្យនឹងនៅស៊ប់ស្ងួនក្នុងអារម្មណ៍តែមួយ ហៅថា ដំកល់ចិត្តស៊ប់ក្នុងឈានមានបឋមជ្ឈានប្រកបដោយអង្គ ៥ គឺ វិតក្កៈ, វិចារៈ, បីតិ, សុខៈនិងឯកគ្គតាជាដើម ។ កាលបើបានសម្រេចដល់ថ្នាក់បឋមជ្ឈានហើយ នីវរណៈទាំង ៥ គឺ កាមច្ឆន្ទៈ, ព្យាបាទៈ, ថីនមិទ្ធៈ, ឧទ្ធច្ចកុក្កុច្ចៈ, វិចិកិច្ឆា ដែលជាសត្រូវនឹងអង្គឈាននោះក៏ត្រូវរម្ងាប់បាត់បង់អស់ទៅ, យ៉ាងនេះ ហៅថា ព្យាយាមលះបាប, អកុសល, ទុច្ចរិត ដែលកើតមាននៅក្នុងសន្តានចិត្ត ។

ពាក្យថា ព្យាយាម ធ្វើនូវកុសលធម៌, សុចរិតធម៌ឲ្យកើតមានឡើង, ឲ្យចំរើនឡើងនោះ កុសល ប្រែថា ប្រកាត់ ឬថាលះបង់នូវសេចក្តីអាក្រក់

ឬជាលះបង់នូវលាមកធម៌, កិលេសធម៌, ធម៌ជាគ្រឿងសៅហ្មងនៃចិត្ត, ដូចមានអធិប្បាយរៀបរាប់មកក្នុងសម្មប្បធានទាំង ៤ ខាងដើមរួចហើយ ។

ពាក្យថា ព្យាយាមចំរើនកុសល, លះអកុសលនោះ គួរយល់ដូចបុគ្គលព្យាយាមចំរើនសម្មាទិដ្ឋិ និងសម្មាសង្កប្បៈ គឺ ចំរើនគំនិតយល់ត្រូវ និងការត្រិះរិះត្រូវ ដែលជាកុសលនោះឲ្យកើតមានឡើង ដូចបានអធិប្បាយរួចមកហើយ ក្នុងអង្គមគ្គទី ១ និងទី ២ ខាងដើម ។

ការព្យាយាមចំរើននូវមគ្គប្រកបដោយអង្គ ៨ មានសម្មាទិដ្ឋិជាដើមឲ្យចំរើនឡើង ៗ ហើយចិត្តក៏សម្បយុត្តប្រកបព្រមដោយមគ្គទាំង ៨, កាលបើចិត្តប្រកបដោយមគ្គទាំង ៨ នេះហើយ កិលេស គឺមិច្ឆាមគ្គ ប្រកបដោយអង្គទាំង ៨ មានមិច្ឆាទិដ្ឋិជាដើម មានមិច្ឆាសមាធិជាខាងចុង ដែលជាគ្រឿងសៅហ្មងតែងដេកត្រាំក្នុងការយល់ខុសនិងត្រិះរិះខុសនោះ ក៏វិនាសសាបសូន្យអស់ទៅ ដោយអំណាចព្យាយាមចំរើននូវមគ្គប្រកបព្រមដោយអង្គទាំង ៨ ឲ្យកើតមានឡើង, បើព្យាយាមរក្សាទុកនូវការយល់ត្រូវនិងត្រិះរិះត្រូវឲ្យខ្ជាប់ខ្ជួនមិនឲ្យដាច់ហើយ ការយល់ខុសនិងត្រិះរិះខុសនោះក៏សាបសូន្យអស់ទៅ បើគ្មានខុសហើយកសាវៈដែលធ្លាប់ដេកត្រាំក្នុងការយល់ខុសនិងត្រិះរិះខុសនោះក៏អស់ដែរ ។

សេចក្តីព្យាយាមចំរើននូវមគ្គប្រកបដោយអង្គទាំង ៨ នេះ ឈ្មោះថាជាធម៌ធ្វើឲ្យផុតចាកគន្លងទុក្ខទាំងអស់បាន, ដូចមានពុទ្ធភាសិតពោលថា:

វីរិយេន ឧក្កមន្តេតិ គេធ្វើនូវសេចក្តីខំគ្រប់យ៉ាងបានដោយសារសេចក្តីព្យាយាម, បើមានសេចក្តីព្យាយាមជានិច្ចមិនដាច់ហើយ ហៅថាមិនប្រមាទ គឺមិនធ្វេសប្រហែស, បើគ្មានព្យាយាមហៅជាប្រមាទគឺសេចក្តីធ្វេសប្រហែស, សេចក្តីធ្វេសប្រហែសនេះហើយដែលបើកផ្លូវឲ្យកិលេសឬអកុសលដ៏លាមកចូលមកលុកលុយបាន ។

សេចក្តីព្យាយាមក៏ប្រភេទទាំង ៤ យ៉ាង ដូចបានរៀបរាប់មកនេះ ហៅថា "សម្មាវាយាមៈ" ចាត់ជាមគ្គទី ៦ ។

អដ្ឋមគ្គនេះចាត់ជា ២ យ៉ាង គឺ ជាលោកិយ ១, ជាលោកុត្តរៈ ១ ។ សេចក្តីព្យាយាមក្រៅរបស់បុថុជ្ជនបុគ្គលចាត់ជាលោកិយ, សេចក្តីព្យាយាមក្រៅរបស់ព្រះអរិយបុគ្គលចាត់ជាលោកុត្តរៈ ។

លក្ខណៈ-កិច្ចនិងផលរបស់សម្មាវាយាមៈ

លក្ខណៈ= បគ្គហលក្ខណោ សម្មាវាយាមៈមានកិរិយាផ្គងឡើងនូវចិត្តជាលក្ខណៈ ។

កិច្ច= អនុប្បន្នអកុសលានុប្បាទនរសោ សម្មាវាយាមៈមានកិរិយាញ៉ាំងអកុសលដែលមិនទាន់កើត មិនឲ្យកើតឡើងបានជាកិច្ច ។

ផល= មិច្ឆាវាយាមប្បហានបច្ចុបដ្ឋានោ សម្មាវាយាមៈមានកិរិយាលះបង់នូវសេចក្តីព្យាយាមខុសជាផល ។

សម្មាវាយាមៈ នេះ ចាត់ជាមនោកម្ម ព្រោះជាអំពើក្នុងចិត្ត

ដោយផ្លូវចិត្ត ចាត់ជាសមាធិក្ខន្ធ ។

## អធិប្បាយអង្គមគ្គទី ៧

សម្មាសតិ សេចក្តីរលឹកត្រូវមាន ៤ យ៉ាងគឺរលឹកក្នុងកាយ ១, ក្នុងវេទនា ១, ក្នុងចិត្ត ១, ក្នុងធម្មារម្មណ៍ ១ ថាគ្រាន់តែជាកាយ, ជាវេទនា, ជាចិត្ត, ជាធម្មារម្មណ៍ប៉ុណ្ណោះ មិនរាប់ថាជាសត្វ, ជាបុគ្គល, ជាខ្លួនប្រាណ, ស្រីប្រុស, យើងគេឡើយ ។

សម្មាសតិនេះ ព្រះសម្មាសម្ពុទ្ធទ្រង់សំដែងក្នុងគម្ពីរទីឃនិកាយ-មហាវគ្គ និងគម្ពីរមជ្ឈិមនិកាយមូលបណ្ណាសកៈថា :

កតមា ច ភិក្ខវេ សម្មាសតិ ម្នាលភិក្ខុទាំងឡាយ ដូចម្តេចហៅថា សម្មាសតិ ?

ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញរឿយ ៗ នូវកាយក្នុងកាយប្រព្រឹត្តទៅ, មានព្យាយាមជាគ្រឿងដុតកំដៅកិលេស, ប្រកបដោយប្រាជ្ញាដឹងសព្វ, មានស្មារតីជាគ្រឿងកំណត់, បណ្តេញបង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។

វេទនាសុ វេទនានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ

ពិចារណាឃើញរឿយៗ នូវវេទនាក្នុងវេទនាទាំងឡាយប្រព្រឹត្តទៅ, មានព្យាយាមជាគ្រឿងដុតកំដៅនូវកិលេស, ប្រកបដោយប្រាជ្ញាដឹងសព្វ, មានស្មារតីជាគ្រឿងកំណត់, បណ្ដេញបង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។

ចិត្តេ ចិត្តានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ពិចារណាឃើញរឿយៗ នូវចិត្តក្នុងចិត្តប្រព្រឹត្តទៅ, មានព្យាយាមជាគ្រឿងដុតកំដៅនូវកិលេស, ប្រកបដោយប្រាជ្ញាដឹងសព្វ, មានស្មារតីជាគ្រឿងកំណត់, បណ្ដេញបង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។

ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្ប-ជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ= ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយប្រព្រឹត្តទៅ, មានព្យា-យាមជាគ្រឿងដុតកំដៅនូវកិលេស, ប្រកបដោយប្រាជ្ញាដឹងសព្វ, មានស្មារតីជាគ្រឿងកំណត់, បណ្ដេញបង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកៗ

អយំ វុច្ចតិ ភិក្ខវេ សម្មាសតិ ម្នាលភិក្ខុទាំងឡាយ នេះ តថាគតឲ្យឈ្មោះថាសម្មាសតិ ។

ក្នុងពុទ្ធភាសិតនេះ សំដៅយកសតិប្បដ្ឋានទាំង ៤ ។ សតិប្បដ្ឋាននោះ ព្រះសម្ពុទ្ធទ្រង់សំដែងយ៉ាងពិស្ដារ ពុំអាចនឹងនាំមកពណ៌នាឲ្យសព្វគ្រប់បានទេ ដកស្រង់យកតែគោលៗ មករៀបរៀងជូនតទៅនេះ ។

សតិប្បដ្ឋានមាន ៤ គឺ :

១)- កាយានុបស្សនាសតិប្បដ្ឋាន ការដំកល់ស្មារតីពិចារណានូវកាយឲ្យឃើញច្បាស់ថា កាយនេះគ្រាន់តែជាធាតុដី, ទឹក, ភ្លើង, ខ្យល់ ប៉ុណ្ណោះ មិនមែនជាសត្វ, មិនមែនជាបុគ្គល, មិនមែនជាអញ-ឯង, មិនមែនជាជីវិត, មិនមែនជាគេ-យើង, មិនមែនជាប្រុស-ស្រី ឡើយ; ការតាំងសតិគឺស្មារតីពិចារណាឲ្យឃើញច្បាស់នូវកាយដូច្នេះ ហៅថា កាយានុបស្សនាសតិប្បដ្ឋាន ។

២)- វេទនានុបស្សនាសតិប្បដ្ឋាន ការដំកល់ស្មារតីពិចារណានូវវេទនា ជាសុខ, ជាទុក្ខ, មិនសុខ មិនទុក្ខ ឲ្យឃើញច្បាស់ថា គ្រាន់តែជាវេទនាប៉ុណ្ណោះ មិនមែនជាសត្វ, មិនមែនជាបុគ្គល, មិនមែនជាអញ ឯង, មិនមែនជាជីវិត, មិនមែនជាគេ-យើង, មិនមែនជាប្រុស-ស្រីឡើយ; ការតាំងសតិ គឺស្មារតីពិចារណាឲ្យឃើញច្បាស់នូវវេទនាដូច្នេះ ហៅថា វេទនានុបស្សនាសតិប្បដ្ឋាន ។

៣)- ចិត្តានុបស្សនាសតិប្បដ្ឋាន ការដំកល់ស្មារតីពិចារណានូវចិត្ត ឲ្យឃើញច្បាស់ថា ចិត្តនេះក៏គ្រាន់តែជាធម្មជាត គិត, នឹក, សង្ស័យ, ស្រាវជ្រាវនូវអារម្មណ៍ល្អ, អាក្រក់, បុណ្យ. បាប ប៉ុណ្ណោះ មិនមែនជាសត្វ, មិនមែនជាបុគ្គល, មិនមែនជាអញ-ឯង, មិនមែនជាជីវិត, មិនមែនជាគេ-យើង, មិនមែនជាប្រុស-ស្រីឡើយ; ការតាំងសតិគឺស្មារតីពិចារណា

ឲ្យឃើញច្បាស់នូវចិត្តប៉ុណ្ណោះ ហៅថា ចិត្តានុបស្សនាសតិប្បដ្ឋាន ។

៤)- ធម្មានុបស្សនាសតិប្បដ្ឋាន ការដំកល់ស្មារតីពិចារណា (១) នូវធម៌ឲ្យឃើញច្បាស់ថា គ្រាន់តែជាធម៌សម្រាប់ប្រតិបត្តិ ដើម្បីដំណើរទៅកាន់ទីរលត់ទុក្ខ ពោលគឺព្រះនិព្វានតែប៉ុណ្ណោះ មិនមែនជាសត្វ, មិនមែនជាបុគ្គល, មិនមែនជាអញ-ឯង, មិនមែនជាគេ-យើង, មិនមែនជាជីវៈ, មិនមែនជាប្រុស-ស្រីឡើយ; ការតាំងសតិស្មារតីពិចារណាឲ្យឃើញច្បាស់ នូវធម៌តាមសភាពពិតប៉ុណ្ណោះ ហៅថា ធម្មានុបស្សនាសតិប្បដ្ឋាន ។

សតិប្បដ្ឋានទាំង ៤ នេះ បើពោលរួមឲ្យខ្លីមក បានដល់ការតាំងសតិស្មារតីពិចារណាឲ្យឃើញរឿយ ៗ នូវកាយផង, ឃើញរឿយ ៗ នូវវេទនាផង, ឃើញរឿយ ៗ នូវចិត្តផង, ឃើញរឿយ ៗ នូវធម៌ផង ថាគ្រាន់តែជាកាយៗ, វេទនាៗ, ចិត្តៗ, ធម៌ៗ ប៉ុណ្ណោះទេ ព្រោះហេតុអ្វី ព្រោះថា សភាវធម៌ទាំងអស់នេះ សុទ្ធតែទៅក្នុងអំណាចធម៌មិនទៀង, ជាទុក្ខ, ជាអនត្តា គឺមិនមែនជារបស់ខ្លួនប្រាណ, មិនមែនជាអញ-ឯង, មិនមែនជាប្រុស-ស្រី ឡើយ ។

កាលបើពិចារណាឃើញច្បាស់ថា: មិនទៀង, ជាទុក្ខ, មិនមែនជារបស់ខ្លួនហើយ កំណត់ដើម្បីទុកក្នុងចិត្តរឿយ ៗ ញ៉ាំងសទ្ធាឲ្យជឿជាក់ច្បាស់ រលត់ឬលះនូវនិមិត្តដែលធ្លាប់ឃើញថាអញៗ, ធ្លាប់ឃើញថាសុខៗ, ធ្លាប់

---

១ ធម៌ក្នុងទីនេះ សំដៅយកអដ្ឋង្គិកមគ្គ ប្រកបដោយអង្គ ៨ ប្រការ ។

ឃើញជាទៀង ៗ នោះទេ ។ បើលែងនិមិត្ត ដែលសំគាល់ថាទៀង, ជាសុខ, ជាខ្លួន, ជាអញអស់ហើយ ហៅថាអនិមិត្តវិមោក្ខ ឬបានកអនិមិត្ត ឬ ហៅថា ព្រះនិព្វានខ្ចូវចេះក៏បាន ។

ការផ្តល់ចំរើនសតិ គឺស្មារតីនេះឲ្យតាំងនៅរឿយ ៗ បានគ្រប់ឥរិយាបថទាំង ៤ នឹងយប់-ថ្ងៃ-ព្រឹក-ល្ងាចមិនដាច់នោះ ព្រោះការស្រ័យ នូវធម៌ប្រាសចាកគម្រោកផង, ការស្រ័យនូវធម៌ស្ងប់រម្ងាប់ផង, ការស្រ័យនូវធម៌ដែលរំលត់នូវទុក្ខនិងទោមនស្សផង, ចិត្តក៏បុះលិបស្ងប់ស្ងាត់ ចាកចេញពីអាសវៈ ឥតមានកំរើកញាប់ញ័រទៅដោយអារម្មណ៍ផ្សេង ៗ ផង ។ ម្យ៉ាងទៀត ធម៌មិនកម្រើកនេះ ដែលនឹងកើតនៅបាននោះ ត្រូវអាស្រ័យដោយធម៌ ៦ យ៉ាង គឺមិនត្រេកអរនឹងការងារ១, មិនត្រេកអរនឹងបក្សពួក១, មិនត្រេកអរនឹងស៊ីដេក១, មិនត្រេកអរនឹងនិយាយលេងលក់១, មិនត្រេកអរ មិនពាក្យពិរោះខ្ចានកថា១, មានការយាសម្រើមក្នុងសីល ១; មានធម៌ ៦ យ៉ាងនេះ ទើបកើតនូវធម៌មិនកម្រើក, ធម៌ស្ងប់រម្ងាប់បាន ។

សតិបដ្ឋាននេះ បែកចេញជាបទៈ មាន ៤ ។ ពាក្យថាបទៈ ប្រែថា ស្នាក់, តាំង, ថ្នាក់, សន្ទាក់ តាមគួរដល់លំនាំសេចក្តី ។ ក្នុងទីនេះ សំដៅយកពាក្យថា: "ថ្នាក់ ឬ សន្ទាក់" ។

បទៈ ៤ នោះគឺ:

១) អានាបានបទៈ: សន្ទាក់នៃការកំណត់នូវខ្យល់ដង្ហើម

ចេញចូល ;

២) ឥរិយាបថបព្វ : សង្កាត់នៃការពិចារណានូវឥរិយាបថ;

៣) សម្បជញ្ញបព្វ : សង្កាត់នៃការពិចារណានូវសម្បជញ្ញៈ;

៤) បដិក្កូលបព្វ : — " — នូវបដិក្កូល ;

៥) ធាតុបព្វ : — " — នូវធាតុ;

៦) នវសីវថិកាបព្វ : — " — នូវអសុភ ៩ យ៉ាង;

៧) នីវរណបព្វ : — " — នូវនីវរណៈ;

៨) ខន្ធបព្វ : — " — នូវខន្ធ :

៩) អាយតនបព្វ : — " — នូវអាយតនៈ;

១០) ពោជ្ឈង្គបព្វ : — " — នូវពោជ្ឈង្គៈ;

១១) សច្ចបព្វ : — " — នូវសច្ចៈ ។

គ្រប់បព្វៈមួយ ៗ ចែកចេញទៅទៀត មានច្រើនថ្នាក់, ច្រើនជាងគេ គឺ ចែកជា ៤ ខ្ទះ, ៥ ខ្ទះ, ៦ ខ្ទះ, ៧ ខ្ទះ, ៩ ខ្ទះ. នឹងមានអធិប្បាយចែកចេញទៅក្នុងខាងមុខ ។

បព្វៈ ១១ នេះ មានចែកក្នុងសតិប្បដ្ឋាន ៤ គឺ កាយានុបស្សនាសតិប្បដ្ឋានមានបព្វៈ ៦ រាប់ពីត្រឹមបព្វៈទី ១ ដល់ទី ៦ ។ វេទនានុបស្សនាសតិប្បដ្ឋាននិងចិត្តានុបស្សនាសតិប្បដ្ឋាន ទាំងពីរនេះមិនមានបព្វៈទេ ។ ធម្មានុបស្សនាសតិប្បដ្ឋានមានបព្វៈ ៥ រាប់ពីត្រឹមទី ៧ ដល់ទី ១១ ។

## សតិបដ្ឋានទី ១

កាយានុបស្សនាសតិបដ្ឋាន មានវិធីពិចារណា ៦ ។ គឺពិចារណាទៅតាមបព្វៈទាំង ៦ ។ បព្វៈទាំង ៦ នេះ មិនបានអធិប្បាយក្នុងសៀវភៅនេះឲ្យសព្វគ្រប់ទេ ។

ការពិចារណាយ៉ាងនេះ ជាហេតុឲ្យចម្រើនប្រាជ្ញាស្មារតី ដើម្បីបំបែរចិត្តគំនិតឲ្យឃ្លាតចាកតណ្ហា និងទិដ្ឋិ កុំឲ្យប្រកាន់អ្វីតិចតួចក្នុងលោក ។

## សតិបដ្ឋានទី ២

វេទនានុបស្សនាសតិបដ្ឋាន ការដំកល់ស្មារតីពិចារណានូវវេទនា ។ វេទនា ប្រែថា ការទទួលនូវអារម្មណ៍, ការសោយ ឬរងនូវអារម្មណ៍មាន ៣ យ៉ាងគឺ :

(១)- សុខវេទនា ការទទួលអារម្មណ៍ជាសុខ ;

(២)- ទុក្ខវេទនា ការទទួលអារម្មណ៍ជាទុក្ខ;

(៣)- អទុក្ខមសុខវេទនា ការទទួលអារម្មណ៍ឥតទុក្ខឥតសុខ ។

វេទនានុបស្សនាសតិបដ្ឋានទី ២ នេះ មិនបានអធិប្បាយទេ ។ ការពិចារណានូវសតិបដ្ឋាននេះ ត្រូវតាំងចិត្តថា គ្រាន់តែជាវេទនា មិនមែនសត្វ, មិនមែនខ្លួនប្រាណ, មិនមែនបុរសស្ត្រីឡើយ ។ កំណត់ពិចារណាយ៉ាងនេះក៏ជាហេតុឲ្យចម្រើនប្រាជ្ញាស្មារតី ដើម្បីទាញចិត្តឲ្យឃ្លាតចាកតណ្ហា និងទិដ្ឋិកុំឲ្យប្រកាន់អ្វីតិចតួចក្នុងលោកនេះឡើយ ។

សតិប្បដ្ឋានទី ៣

ចិត្តានុបស្សនាសតិប្បដ្ឋាន ការដំកល់ស្មារតីពិចារណានូវចិត្តដែលត្រូវលើកយកមកជាគោលពិចារណាក្នុងទីនេះ មាន ១៦ យ៉ាង, ចិត្តទាំង ១៦ យ៉ាងនេះ ក៏មិនបានអធិប្បាយរៀបរាប់ក្នុងទីនេះដែរ ។

ការដែលពិចារណានូវសតិប្បដ្ឋាននេះ ត្រូវសំគាល់ថាគ្រាន់តែជាចិត្តៗ ប៉ុណ្ណោះ មិនមែនសត្វ, មិនមែនខ្លួនប្រាណ, មិនមែនបុរសស្ត្រីឡើយ ។ ពិចារណាយ៉ាងនេះ ក៏គ្រាន់តែជាហេតុឲ្យចម្រើនប្រាជ្ញាស្មារតីប៉ុណ្ណោះ ដើម្បីបំបែរចិត្តឲ្យឃ្លាតចាកតណ្ហានិងទិដ្ឋិកុំឲ្យប្រកាន់អ្វីតិចតួចក្នុងលោក ។

សតិប្បដ្ឋានទី ៤

ធម្មានុបស្សនាសតិប្បដ្ឋាន គឺដែលពិចារណា ៥ គឺពិចារណាទៅកៈបបត្តៈទាំង ៥ ។ បត្តៈទាំង ៥ នេះ មិនបានអធិប្បាយក្នុងទីនេះទេ ។

សូមបញ្ជាក់-សម្រេច លោកអ្នកត្រូវការដោយសេចក្តីពិស្តារសូត្រ គ្រប់មើលក្នុងច្បាប់សតិប្បដ្ឋានសូត្រ ឬច្បាប់អរិយមគ្គាធិប្បាយរបស់លោកគ្រូបាឡាត់ឧត្តមលិខិត សុន-ស៊ីវ ធម៌ចុះ ។

ការពិចារណានូវបត្តៈទាំងអស់នេះ ត្រូវសំគាល់ថាគ្រាន់តែជាធម៌ៗ ប៉ុណ្ណោះ មិនមែនជាសត្វ, មិនមែនជាបុគ្គល, មិនមែនជាបុរសស្ត្រីឡើយ គ្រាន់តែជាហេតុឲ្យចម្រើនប្រាជ្ញាស្មារតីប៉ុណ្ណោះ ដើម្បីបំបែរចិត្តឲ្យឃ្លាតចាកតណ្ហានិងទិដ្ឋិ កុំឲ្យប្រកាន់របស់អ្វីតិចតួចក្នុងលោក ។

សតិប្បដ្ឋាន ទាំង ៤ នេះ បើព្រះយោគាវចរអ្នកចម្រើនបាននូវសតិប្បដ្ឋានណាមួយ ក៏គេចចូលទៅកាន់ព្រះនិព្វានបាន ។

សេចក្តីរលឹកត្រូវទាំង ៤ យ៉ាង ដូចបានរៀបរាប់មកដោយសង្ខេបនេះ ហៅថា "សម្មាសតិ" ចាត់ជាអង្គមគ្គទី ៧ ។

### លក្ខណៈ កិច្ចនិងផលរបស់សម្មាសតិ

លក្ខណៈ = ឧបដ្ឋានលក្ខណា សម្មាសតិមានកិរិយាចូលទៅដម្កល់ឬចប់នូវចិត្តជាលក្ខណៈ ។

កិច្ច = អសម្មោសរសា សម្មាសតិមានកិរិយាមិនវង្វេងជាកិច្ច ។

ផល = មិច្ឆាសតិប្បហានបច្ចុប្បដ្ឋានា សម្មាសតិមានការលះបង់នូវកិរិយារលឹកខុសជាផល ។

សម្មាសតិ នេះ ចាត់ជាមនោកម្ម ព្រោះជាអំពើត្រូវធ្វើដោយផ្លូវចិត្ត ចាត់ជាសមាធិក្ខន្ធ ។

## អធិប្បាយអង្គមគ្គទី ៨

សម្មាសមាធិ ការតម្កល់ចិត្ត ឬតាំងចិត្តត្រូវមាន ៤ យ៉ាង គឺ ដម្កល់ចិត្តស៊ប់ក្នុងបឋមជ្ឈាន ១, ក្នុងទុតិយជ្ឈាន ១, ក្នុងតតិយជ្ឈាន ១, ក្នុងចតុត្ថជ្ឈាន ១ ។

ម្យ៉ាងទៀត សមាធិនេះ ប្រែថា កិរិយាតម្កល់ចិត្តឲ្យមាំនៅក្នុង

អារម្មណ៍តែមួយ ឬថា ធ្វើចិត្តឲ្យផុតចាកនីវរណធម៌ទាំង ៥ មានកាមច្ឆន្ទៈ ជាដើម និងអកុសលធម៌ ៣ យ៉ាង គឺ លោភៈ ទោសៈ មោហៈ ដែលជាគ្រឿងសៅហ្មងដល់កុសលធម៌ទាំងពួង ។

សហជាតធម៌នេះ សំដៅយក សមាធិ៣យ៉ាង គឺ សុញ្ញតសមាធិ១, អនិមិត្តសមាធិ១, អប្បណិហិតសមាធិ១ ។ សមាធិទាំង៣នេះ កំណត់កាប់យកត្រៃលក្ខណៈ ៣ យ៉ាងគឺ អនិច្ចលក្ខណៈ១, ទុក្ខលក្ខណៈ១, អនត្តលក្ខណៈ១; បណ្ដាលក្ខណៈទាំង៣នេះ កំណត់កាប់យកត្រៃលក្ខណៈណាមួយមកជាអារម្មណ៍ក៏បាន ។

## អធិប្បាយ

ព្រះយោគាវចរកាប់យកអនិច្ចលក្ខណៈ កំណត់ធ្វើមុខក្នុងចិត្តជាអារម្មណ៍ ហើយចំរើនបញ្ញា ពិចារណាឲ្យឃើញច្បាស់ខ្ទង់ខន្ធទាំង៥ ថាមិនទៀងទាត់, មិនស្ថិតស្ថេរ, មិនខ្ជាប់ខ្ជួន, មិនគង់នៅព្រាកដ ។ ចំរើនបញ្ញាឲ្យច្រើនឡើង ៗ ហើយញុំាងសន្ដានឲ្យជឿជាក់ថាខន្ធទាំង៥នេះ គឺពិតជាមិនទៀង មិនស្ថិតស្ថេរមែន ចិត្តក៏ស្ងប់ស្ងៀម ជាប់មិនដាច់នៅក្នុងអារម្មណ៍ដែលឃើញថាមិនទៀង មិនស្ថិតស្ថេរនោះ មួយតែមួយគត់នៅស៊ប់ស្ងប់ស្ងៀមព្រងើយកន្តើយ, រំលត់បង់នូវសន្ទេហនិមិត្ត គឺនិមិត្តដែលឃើញថាទៀង, ល្អ ៗ ក្នុងខន្ធទាំង៥នោះឯង ។ បើនិមិត្តដែលឃើញថាទៀង ល្អ ៗ នោះ [illegible] សមាធិ ឬហៅថា

អនិមិត្តវិមោក្ខ ព្រោះអស់សេចក្ដីសំគាល់ថាទៀង, ថាល្អក៏ដូចខ្លួន ៥ ឬ ហៅថា អនិមិត្តនិព្វានវិញក៏បាន ព្រោះអស់សេចក្ដីប្រកាន់មាំថាទៀង, ថាល្អ ឬថាអស់សេចក្ដីយល់ឃើញខុសនោះឯង, ឬហៅថា សុញ្ញតវិសេសនិព្វានក៏បាន ព្រោះកិលេសអស់ទៅនៃគំលេស គឺ រាគៈ, ទោសៈ, មោហៈ, អវិជ្ជា, តណ្ហា, ឧបាទាន, ទិដ្ឋិ, មានៈ ដោយអំណាចបំភ្លេចនូវអនិមិត្តសមាធិ ឬ អនិមិត្តវិមោក្ខ ដែលកំណត់កាន់យកនូវអនិច្ចានុបស្សនាជាអារម្មណ៍ ជាបន្ទាប់ប្រព្រឹត្តទៅជាប្រក្រតីនោះឯង ។

ព្រះយោគាវចរកាន់យកនូវទុក្ខលក្ខណៈ គឺណាត់ធ្វើទុក្ខនិមិត្តជាអារម្មណ៍ ហើយចម្រើនបញ្ញា ពិចារណាឲ្យឃើញច្បាស់នូវគន្ធទុក្ខបំពោះខន្ធ៥នោះឲ្យច្រើនឡើងៗ ហើយញុំាងសត្វឲ្យជឿជាក់ថា ខន្ធ៥នេះ គឺជាជាទុក្ខមែន ចិត្តក៏សម្បយុត្តជាប់នៅក្នុងអារម្មណ៍ដែលឃើញថាទុក្ខនោះ មូលតែមួយ គាំងនៅសិប់ស្ងប់ស្ងៀម ព្រមដោយគន្ធើយ, រំលត់ដ៏ទុក្ខនិមិត្ត គឺនិមិត្តដែលឃើញថា ខន្ធ៥នេះសុខៗ, ខន្ធ៥នេះល្អៗ; បើនិមិត្តដែលឃើញថាសុខៗ, ល្អៗនោះរលត់ហើយ ហៅថា អប្បណិហិតសមាធិ, ឬហៅថា អប្បណិហិតវិមោក្ខ ព្រោះអស់សេចក្ដីសំគាល់ថាសុខក្នុងខន្ធ៥ ឬហៅថា និព្វានវិញក៏បាន ព្រោះអស់ទៅនៃតណ្ហាជាគ្រឿងដោតត្រង ។

សមាធិ និចិត្តដែលប្រព្រឹត្តទៅក្នុងទុក្ខលក្ខណៈ គឺកំណត់កាន់យកនូវទុក្ខទោស របស់នាមរូបដែលជាអារម្មណ៍ជាប់មិនដាច់ហើយ ឥតមិត្ត ដល់

សំគាល់ថាសុខ, ថាល្អ, ថាទៀងនោះក៏រលត់អស់ទៅ, បើនិមិត្តនោះរលត់ហើយ តណ្ហាក៏រលត់អស់ដែរ ព្រោះថា តណ្ហាដែលនឹងកើតឡើងនោះ អាស្រ័យនឹងនិមិត្តដែលឃើញថាសុខៗ, ល្អ ៗ នេះឯង ។

សមាធិ គឺចិត្តដែលកាន់យកនូវទុក្ខទោសរបស់ខន្ធ មកកំណត់ផ្ចុំទុកក្នុងចិត្តជាអារម្មណ៍រឿយ ៗ ហើយ តណ្ហាគឺសេចក្ដីពេញចិត្ត ត្រេកអរប្រាថ្នាចង់បាននូវវត្ថុកាមនោះ ក៏រលត់សាបសូន្យអស់ទៅមិនកើតទៀត ព្រោះសត្វាជឿជាក់ច្បាស់ថាខន្ធនេះ គឺពិតជាទុក្ខទោសមែន, ម្យ៉ាងហើយតណ្ហានោះ ក៏កេប្រាថ្នាថាសុខ, ថាល្អមិនកើត ត្រង់នេះហើយដែលហៅថារលត់តណ្ហា ។ បើតណ្ហារលត់ហើយ អវិជ្ជា គឺសេចក្ដីមិនដឹងច្បាស់នូវកងទុក្ខ ដែលជាបច្ច័យឲ្យកើតសង្ខារ ជាបច្ច័យឲ្យកើតវិញ្ញាណ, វិញ្ញាណគឺសេចក្ដីដឹងទៅតាមទ្វារទាំង ៦ មានចក្ខុទ្វារជាដើម, តែដឹងនេះមិនពិត មិនប្រាកដទេ គឺដឹងទៅប្រកបដោយតណ្ហានឹងទិដ្ឋិ ដូចយ៉ាងដឹងថា: នេះរូបអញ រូបនេះល្អ, រូបនេះជាសុខ, រូបនេះប្រសើរ, រូបនេះទៀងទាត់ស្ថិតស្ថេរពិតប្រាកដ ៗ វិញ្ញាណដែលដឹងរបស់មិនពិតប្រាកដថាជារបស់ពិតប្រាកដនេះ មកអំពីអវិជ្ជាសេចក្ដីមិនដឹងនេះឯងជាមូលហេតុ, ជាបច្ច័យនាំឲ្យកើត ។ សមាធិ គឺចិត្តដែលសម្បយុត្តទៅក្នុងអារម្មណ៍តែមួយកំណត់យកទុក្ខទោសរបស់ខន្ធ ៥ នោះមកជាអារម្មណ៍ ហើយញ៉ាំងសត្វាឲ្យជឿជាក់ច្បាស់ថា រូបនេះ គឺពិតជាមិនមែនខ្លួន, មិនមែនអញ,

រូបនេះមិនមានសុខ, មិនល្អ, សត្វាជៀញស់ជារូបនេះ ពិតជាមិនស្អាត, មិនល្អមែន, ប្រព្រឹត្តទៅដើម្បីចាស់, ឈឺ, ស្លាប់, ព្រាត់ប្រាស់ ពិតមែនៗ កាលបើ សត្វាជៀផាត់ មានគម្ពីរគ្រាទៅទីនេះហើយ សតិ គឺសេចក្តីរលឹកពិចារណាឃើញរឿយៗ នូវទុក្ខទោសរបស់ខន្ធនោះ ក៏មានកម្លាំង, វីរិយៈ សេចក្តីព្យាយាមក៏មានកម្លាំង, សមាធិដែលផ្គល់ចិត្តឲ្យនឹងនៅក៏មានកម្លាំង, បញ្ញាក៏មានកម្លាំងក្លៀវក្លាៗ កាលបើផលទាំង៤យ៉ាង គឺ សទ្ធា, វីរិយៈ, សតិ, សមាធិ និងបញ្ញានេះកើតក្លៀវក្លាព្រមគ្នាឡើងកាលណា ក៏អាចញុំាងបុគ្គលអ្នកប្រតិបត្តិនោះឲ្យត្រាស់ដឹងនូវសភាវធម៌ ដែលពិតមែន គឺត្រាស់ដឹងនូវអរិយសច្ចធម៌ ៤ យ៉ាង គឺត្រាស់ដឹងនូវទុក្ខសច្ច គឺកងទុក្ខទាំង ១៤ កងមានជាតិទុក្ខជាដើម, ត្រាស់ដឹងនូវសមុទយសច្ច គឺតណ្ហាទាំង៣ ប្រការមានកាមតណ្ហាជាដើម ដែលជាហេតុនាំបណ្តាលឲ្យកើតនូវកងទុក្ខ ១៤កងមានជាតិទុក្ខជាដើម, ត្រាស់ដឹងនូវនិរោធសច្ច គឺព្រះនិព្វានដែលជាធម៌រលត់បង់នូវសេចក្តីទុក្ខព្រួយ ១, ត្រាស់ដឹងនូវមគ្គសច្ច គឺអដ្ឋង្គិកមគ្គ ប្រកបដោយអង្គ ៨ ដែលជាផ្លូវប្រតិបត្តិសម្រាប់ធ្វើដំណើរទៅកាន់ទីរលត់ទុក្ខ១; រួមត្រូវជាអរិយសច្ច ៤ ។

កិច្ចដែលព្រះអរិយបុគ្គលគប្បីប្រតិបត្តិក្នុងអរិយសច្ចនោះមាន៤យ៉ាង គឺ បរិញ្ញាកិច្ច ជាកិច្ចដែលព្រះយោគីត្រូវកំណត់ដឹងនូវទុក្ខសច្ច គឺកំណត់យកកងទុក្ខមកជាអារម្មណ៍, កំណត់យកធម៌មិនទៀងមកជាអារម្មណ៍, កំណត់

យកធម៌មិនមែនខ្លួនមកជាអារម្មណ៍, ធ្វើទុកក្នុងចិត្តឲ្យរឿយៗហើយប្រព្រឹត្តទៅ ១, បហាតព្វកិច្ច ជាកិច្ចដែលព្រះយោគីគប្បីលះបង់នូវតណ្ហា, ឧបា-ទាន នឹងអវិជ្ជា ១, សច្ឆិកាតព្វកិច្ច ជាកិច្ចដែលព្រះយោគីគប្បីធ្វើឲ្យជាក់ច្បាស់នូវនិរោធសច្ច បានដល់ព្រះនិព្វានដែលជាគុណជាតិចេញចាកតណ្ហា, ឧបាទាន នឹងសង្ខារធម៌ទាំងពួង ១, ភាវេតព្វកិច្ច ជាកិច្ចដែលព្រះយោគីគប្បីប្រតិបត្តិ គឺត្រូវចំរើនធម៌ អនិច្ចំ, ទុក្ខំ, អនត្តា ឲ្យច្រើនឡើងៗ ១ ។ កាលបើព្រះយោគីបានប្រតិបត្តិក្នុងអរិយសច្ចទាំង ៤ នឹងកិច្ច ៤ យ៉ាង ដែលព្រះយោគីគប្បីប្រតិបត្តិក្នុងអរិយសច្ចនោះៗ ហើយ គប្បីប្រតិបត្តិក្នុងធម៌ដែលជាកម្លាំង ៥ យ៉ាង តទៅទៀត ។ បើធម៌ជាកម្លាំងទាំង ៥ កើតឡើងមានកម្លាំងស្មើគ្នាហើយ កិលេសដែលជាគ្រឿងសៅហ្មងនោះ ក៏ស្រាប់តែវិនាសសាបសូន្យអស់ទៅ ដោយអំណាចនៃអរិយមគ្គញាណ គឺបញ្ញាដែលត្រាស់ដឹងនូវធម៌ពិតធម៌មែន ដូចបានពោលមកដោយសង្ខេបខាងលើនេះឯង ។

ព្រះយោគាវចរកាន់យកនូវអនត្តលក្ខណៈ កំណត់ធ្វើទុកក្នុងចិត្តជាអារម្មណ៍ ហើយចំរើនបញ្ញាពិចារណាឲ្យឃើញច្បាស់នូវខន្ធទាំង ៥ នោះ ថាមិនមែនជាសត្វ, មិនមែនជាបុគ្គល, មិនមែនជាខ្លួន, មិនមែនជាអញ, មិនមែនជាឯង, មិនមែនជាគេ, មិនមែនជាយើង, មិនមែនជាស្រី, មិនមែនជាប្រុស, មិនមែនជាជីវិតឡើយ ។

ខន្ធ៥ គឺ រូបក្ខន្ធ១, វេទនាខន្ធ១, សញ្ញាខន្ធ១, សង្ខារក្ខន្ធ១, វិញ្ញាណក្ខន្ធ១ ។ រូបក្ខន្ធ ជាកំណាត់រូបធម៌ ។ វេទនាខន្ធ-សញ្ញាខន្ធ-សង្ខារក្ខន្ធ-វិញ្ញាណក្ខន្ធ ជាកំណាត់នាមធម៌ (មិនបានអធិប្បាយក្នុងទីនេះទេ ព្រោះបានអធិប្បាយក្នុងអដ្ឋមគ្គខាងដើមហើយ) ។

អាយតនៈ១២ គឺ ភ្នែក១, ត្រចៀក១, ច្រមុះ១, អណ្ដាត១, កាយ១, ចិត្ត១, រូប១, សំឡេង១, ក្លិន១, រស១, ផស្សផ្សាយ១, ធម្មារម្មណ៍១, ជា១២ ។ ខន្ធក្ដី, អាយតនៈក្ដី ដែលបានរៀបរាប់ជាបទមាតិកាមកខាងលើនេះ ព្រះយោគាវចរគប្បីពិចារណាឲ្យឃើញច្បាស់ចំពោះខន្ធមួយ ៗ និងអាយតនៈមួយ ៗនោះ ហើយកំណត់ធ្វើទុកក្នុងចិត្តជាអារម្មណ៍ថាខន្ធ-អាយតនៈទាំងអស់នេះ កាលដែលកើតឡើងនោះ ក៏កើតឡើងឯង, ដល់ចាស់ ក៏ចាស់ឯង, ដល់ឈឺ ក៏ឈឺឯង, ដល់ស្លាប់ ក៏ស្លាប់ឯង គឺគ្មានអ្នកណាជាម្ចាស់ជានាយទៅហាមឃាត់ អាចនឹងបង្គាប់បញ្ជាត្រួតត្រាលើខន្ធ-អាយតនៈទាំងអស់នេះបានទេ គឺពិតជាមិនចុះក្នុងអំណាចរបស់អាត្មាអញឡើយ ។ កាលបើពិចារណាឃើញច្បាស់យ៉ាងនេះហើយ គប្បីញាំងសទ្ធាឲ្យជឿជាក់ថា ខន្ធ-អាយតនៈទាំងអស់នេះ គឺពិតជាមិនមែនខ្លួន, មិនមែនអញ, មិនមែនសត្វ, មិនមែនបុគ្គល, មិនមែនស្រី, មិនមែនប្រុស, មិនមែនជាជីវិតឡើយ ។ កាលបើសទ្ធាជឿជាក់ថា ខន្ធ-អាយតនៈទាំងអស់នេះ គឺពិតជាមិនមែនអញ, មិនមែនខ្លួនហើយ និមិត្តដែលធ្លាប់សំគាល់

ឃើញជាទុក្ខៗ, ជាអញៗ, ជាស្រីៗ, ប្រុសៗនោះ ក៏លែងសាបសូន្យអស់ទៅដែរ, ទើបនិមិត្តនោះលែងសាបសូន្យអស់ហើយ ហៅថាសុញ្ញត-សមាធិ ឬហៅថា សុញ្ញតវិមោក្ខ ព្រោះតែអស់ទៅ, សូន្យទៅនៃនិមិត្តដែលសំគាល់ជាទុក្ខ, ជាអញ, ជាស្រី, ជាប្រុស, ជាល្អ, ជាស្អាត, ជាសុខ, ជាចំរើននោះឯង ឬហៅថា សុញ្ញតនិព្វានជួបប្រទះវិញក៏បាន ព្រោះអស់ទៅសូន្យទៅនៃអវិជ្ជា, តណ្ហា, ឧបាទាន, ទិដ្ឋិ, មានះ ពុំមានសេសសល់ឡើយ ។

សមាធិ គឺការតម្កល់ចិត្តឲ្យនឹងនៅក្នុងអារម្មណ៍តែមួយ, សម្បយុត្តជាប់មិនដាច់ ដោយអនត្តានុបស្សនា ហៅថា សុញ្ញតសមាធិ ។

សមាធិនេះ ជាប្រធាន ខាងឯតម្កល់ចិត្តឲ្យនឹងនៅក្នុងអារម្មណ៍ ។ សម្មាសតិ ជាអធិបតី ខាងការពិនិត្យត្រួតត្រាមើលគ្រប់អង្គមគ្គទាំង៨, សម្មា-ទិដ្ឋិ នឹងសម្មាសង្កប្បៈ ដែលជាគូបញ្ញា ជាវិសេសខាងឆ្លុះបំភ្លឺមើលសច្ច-ធម៌ទាំងឡាយដែលនៅក្នុងវង្គិត គឺអវិជ្ជា, ឆ្លុះបំភ្លឺមើលផ្លូវសម្រាប់ដើរទៅកាន់ទីរលត់ទុក្ខ គឺព្រះនិព្វាន បានដល់អរិយមគ្គ ប្រកបដោយអង្គ ៨ ជាធម៌សម្រាប់ប្រតិបត្តិដើម្បីរលត់បង់នូវក្ដីទុក្ខ, ក្ដីកិលេសឲ្យរសាត់ពីខ្លួន ឬឲ្យផុតចាកពីភព ៣ ។

សមាធិ ការដែលតម្កល់ចិត្តឲ្យនឹងនៅក្នុងអារម្មណ៍តែមួយនោះមានអំណាចនឹងកំចាត់បង់នូវកិលេសបាន ៣ ថ្នាក់ គឺ:

១)- តទង្គវិមុត្តិ រំងាប់កិលេសដោយអំណាចការពិចារណាឃើញ

នូវការចាស់, ឈឺ, ស្លាប់ មួយប្រព្រិចភ្នែក មួយគ្រា ហើយកើតសេចក្ដីសង្វេគឡើង យ៉ាងនេះ ហៅថាតទង្គវិមុត្តិ ;

២)- វិក្ខម្ភនវិមុត្តិ រួចចាកកិលេសដោយអំណាចពកហាននសមាបត្តិ ៨ គឺរូបជ្ឈាន ៤ និងអរូបជ្ឈាន ៤ គឺចំរើនឈានទាំង ៨ មានបឋមជ្ឈានជាដើមឲ្យកើតមានឡើងក្នុងសន្ដានចិត្តពេលណា កាលណោះជារួចចាកកិលេស គឺនីវរណធម៌ទាំង ៥ មានកាមច្ឆន្ទៈជាដើម ក្នុងពេលនោះ ដូច្នេះណោះជារួចចាកកិលេសដោយសង្កត់សង្កិន ដូចយកថ្មសង្កត់ស្មៅ, វេលាណាយកថ្មនោះចេញ ស្មៅក៏ដុះឡើងវិញដដែល យ៉ាងនេះ ហៅថា វិក្ខម្ភនវិមុត្តិ ។

៣)- សមុច្ឆេទវិមុត្តិ រួចចាកកិលេសដោយអំណាចអរិយមគ្គញាណ ៤ និងអរិយផលញាណ ៤, មគ្គញាណនិងផលញាណកើតមានឡើងពេលណា កិលេសក៏ដាច់សាបសូន្យអស់ទៅពុំមានសេសសល់ឡើយ, យ៉ាងនេះហៅថា សមុច្ឆេទវិមុត្តិ ។

បុគ្គលណាដែលរួចផុតស្រឡះចាកកិលេសាសវៈ បុគ្គលនុ៎ះ ហៅថា អរិយបុគ្គល ប្រែថា បុគ្គលប្រសើរ, បុគ្គលខ្ពង់ខ្ពស់ ឬគឺឧត្តមដ៏ថ្លៃ មាន ៨ពួកគឺ: បុគ្គលដែលបានសម្រេចសោតាបត្តិមគ្គ ១, សោតាបត្តិផល ១, សកទាគាមិមគ្គ ១, សកទាគាមិផល ១, អនាគាមិមគ្គ ១, អនាគាមិផល ១, អរហត្តមគ្គ ១, អរហត្តផល ១, ។

សោតាបន្នបុគ្គល លោកលះបង់បាននូវសំយោជនធម៌ ៣ គឺ:

សក្កាយទិដ្ឋិ ១, វិចិកិច្ឆា ១, សីលព្វតបរាមាសៈ ១ ។

សក្កាយទិដ្ឋិ សេចក្ដីយល់ខុសក្នុងខន្ធមាន ២០ គឺសេចក្ដីយល់ខុសក្នុងខន្ធ ទាំង៤ប្រការ បានដល់ការឃើញនូវរូបថាជាខ្លួន ១, ឃើញខ្លួនថាមានរូប ១, ឃើញថារូបក្នុងខ្លួន ១, ឃើញថាខ្លួនក្នុងរូប ១, ។ ឃើញនូវវេទនាថាជាខ្លួន១, ឃើញខ្លួនថាមានវេទនា ១, ឃើញថាវេទនាក្នុងខ្លួន១, ឃើញថាខ្លួនក្នុងវេទនា ១ ។ ឃើញនូវសញ្ញាថាជាខ្លួន១, ឃើញខ្លួនថាមានសញ្ញា ១, ឃើញថាសញ្ញាក្នុងខ្លួន ១, ឃើញថាខ្លួនក្នុងសញ្ញា ១, ។ ឃើញនូវសង្ខារទាំងឡាយថាជាខ្លួន ១, ឃើញខ្លួនថាមានសង្ខារទាំងឡាយ ១, ឃើញថាសង្ខារទាំងឡាយក្នុងខ្លួន ១, ឃើញថាខ្លួនក្នុងសង្ខារទាំងឡាយ១ ។ ឃើញនូវវិញ្ញាណថាជាខ្លួន១, ឃើញខ្លួនថាមានវិញ្ញាណ ១, ឃើញថាវិញ្ញាណក្នុងខ្លួន១, ឃើញថាខ្លួនក្នុងវិញ្ញាណ១ ។ ពួកសក្កាយទិដ្ឋិទាំង២០ ប្រការដែលបានពណ៌នាមកនេះ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ហៅថា អត្តវាទុបាទាន គឺសេចក្ដីប្រកាន់មាំថា ខ្លួន ៗ, អញ ៗ របស់បុថុជ្ជនបុគ្គលនោះ ៗ ដូចបានពោលមកជាសេចក្ដីសង្ខេបប៉ុណ្ណេះ ។ ព្រះសោតាបន្នបុគ្គល លោកលះបង់នូវសក្កាយទិដ្ឋិទាំង២០នេះដាច់ស្រឡះ ចាកសន្តាន របស់លោកឥតមានសេសសល់ឡើយ ។

វិចិកិច្ឆា សេចក្ដីសង្ស័យមិនដាច់ស្រេច ; អធិប្បាយៈ សេចក្ដីសង្ស័យនោះមាន ១៦ យ៉ាង ចាត់តាមកាលទាំង ៣ គឺ អតីត៨, អនាគត

៥. បច្ចុប្បន្ន ៦ ត្រូវជា ១៦ ។

សង្ស័យក្នុងអតីត ៥ នោះគឺ:

(១)- សង្ស័យថា ដូចជាអញរំពឹងទៅ ក្នុងកាលកន្លងទៅហើយ អាត្មាអញកើតជាអ្វីអេះ ! ;

(២)- សង្ស័យថា ក្នុងកាលដែលកន្លងទៅហើយ តើអាត្មាអញមិនបានកើតជាអ្វីទេ ឬអេះ ! ;

(៣)- សង្ស័យថា ក្នុងកាលដែលកន្លងទៅហើយ តើអាត្មាអញ ជាខត្តិយជាតិ ឬព្រាហ្មណជាតិ ឬកំជាអ្នកស្រែ អ្នកឈ្មួញទេអេះ ! ;

(៤)- សង្ស័យថា ក្នុងកាលដែលកន្លងទៅហើយ អាត្មាអញមានសណ្ឋានទ្រង់ទ្រាយ ធំ ឬតូច, ខ្មៅ ឬស, ល្អ ឬអាក្រក់អេះ ! ;

(៥)- សង្ស័យថា ក្នុងកាលដែលកន្លងទៅហើយ ដើមដំបូងអាត្មាអញកើតជាអ្វី ដល់មកខាងក្រោយអាត្មាអញកើតជាអ្វីទៀតអេះ ! ;

រួមមកត្រូវជាសង្ស័យក្នុងអតីត ៥ ប្រការ ។

សង្ស័យក្នុងអនាគត ៥ នោះគឺ:

(១)- សង្ស័យថា ក្នុងកាលខាងមុខអាត្មាអញ នឹងកើតជាអ្វីហ្ន៎ ! ;

(២)- សង្ស័យថា ក្នុងកាលខាងមុខអាត្មាអញនឹងកើតទៀតដែរឬហ្ន៎ ! ;

(៣)- សង្ស័យថា តើក្នុងកាលខាងមុខ អាត្មាអញ នឹងបានកើតជាខត្តិយជាតិ ឬព្រាហ្មណជាតិ ឬកំជាអ្នកស្រែ អ្នកឈ្មួញក្រីក្រលោម-

ហោមយ៉ាងណាទៅនេះ ! ;

(៤)- សង្ស័យថា នៅក្នុងកាលខាងមុខ អាត្មាអញនឹងកើតជាអ្នកមាន រូបកាយសណ្ឋានទ្រង់ទ្រាយ ធំ, តូច, ខ្ពស់, ទាប, ខ្មៅ, ស ដូចម្ដេចទៅហ្ន៎ ! ;

(៥)- សង្ស័យថា នៅក្នុងកាលខាងមុខអាត្មាអញនឹងកើតជាអ្វី តពីនោះទៅ នឹងទៅកើតជាអ្វីទៀតនេះ ! ; រួមជាសង្ស័យ ក្នុងអនាគត ៥ ប្រការ ។

សង្ស័យក្នុងបច្ចុប្បន្ន ៦ នោះគឺ :

(១)- សង្ស័យថា ដូចជាអញរំពឹងទៅ សព្វថ្ងៃនេះ បានឈ្មោះជាខ្លួនអញមែន ឬមិនមែនខ្លួនអញទេ ! ;

(២)- សង្ស័យថា ដូចជាអញគិតទៅ សព្វថ្ងៃនេះមិនបានឈ្មោះជាខ្លួនអញទេ ឬដូចម្ដេច ! ;

(៣)- សង្ស័យថា សព្វថ្ងៃនេះ បានឈ្មោះថាអាត្មាអញ កើតក្នុងខត្តិយជាតិ ឬព្រាហ្មណជាតិ ឬក៏ជាអ្នកស្រែ, អ្នកឈ្មួញ, អ្នកក្រ ឬជាដូចម្ដេច ! ;

(៤)- សង្ស័យថា សព្វថ្ងៃនេះ បានឈ្មោះថាអាត្មាអញកើត បានជារូបកាយពណ៌សម្បុរសណ្ឋានទ្រង់ទ្រាយ ធំ, តូច, ខ្ពស់, ទាប, ខ្មៅ, ស, ដូចម្ដេចទៅ ! ;

(៥)- សង្ស័យថា សត្វនេះមកពីទីណាមកកើតក្នុងទីនេះនេះ! ;

(៦)- សង្ស័យថា សត្វនេះមកកើតក្នុងទីនេះហើយ ទៅកើតក្នុងទីណាទៀតនេះ! ; រួមជាសង្ស័យក្នុងបច្ចុប្បន្ន ៦ ប្រការ ។

បូករួមទាំងអស់គឺសង្ស័យក្នុងអតីត ៥, អនាគត ៥, បច្ចុប្បន្ន ៦ ត្រូវជា ១៦ ប្រការ ដូចរៀបរាប់មកនេះ ។

ព្រះសោតាបន្នបុគ្គលលោកពិចារណាឃើញច្បាស់នូវសង្ខារទាំងឡាយ គឺកុសលសង្ខារក្ដី, អកុសលសង្ខារក្ដី, អនេញ្ជាភិសង្ខារក្ដី ឃើញថាសង្ខារទាំង ៣ នេះហើយដែលតាក់តែងជាតិ-គតដែលកន្លងទៅហើយផង, តាក់តែងជាតិ-គត ទៅក្នុងកាលខាងមុខផង, តាក់តែងជាតិ-គតក្នុងកាលជាបច្ចុប្បន្ននេះផង, សង្ខារទាំងបីនេះ ប្រៀបដូចជាភ្លើងឆេះ កំណើតរបស់សត្វ ដែលកំពុងកើត ឲ្យចាស់, ឲ្យឈឺ, ឲ្យស្លាប់ គប់ជាតិកំណើតមិនអស់, គប់ចាស់, គប់ឈឺ, គប់ស្លាប់មិនអស់, ជាតិកំណើតដែលកើត, ចាស់, ឈឺ, ស្លាប់ នេះកើតបន្តគ្នា ៗ លោកពិចារណាឃើញទោសរបស់សង្ខារទាំងបីដូច្នេះហើយ លោកក៏ព្យាយាមចំរើននូវធម៌ ដែលប្រជុំចុះក្នុងអរិយមគ្គប្រកបដោយអង្គ ៨ ប្រការមានសម្មាទិដ្ឋិជាដើម ដូចបានអធិប្បាយមកខាងដើមហើយ ដើម្បីរំលត់បង់នូវសង្ខារធម៌ទាំង ៣ ពួកដែលតាក់តែងជាតិ-គត របស់សត្វក្នុងត្រៃភពនោះឲ្យវិនាសសាបសូន្យអស់ពីសន្ដានរបស់លោក, លោកពិចារណាឃើញ

ព្រោះថា បើលះបង់នូវសង្ខារធម៌ទាំងឡាយនោះបានទើបបាននូវសេចក្ដីសុខ, បើមិនលះបង់នូវសង្ខារទាំងឡាយនោះមិនបានទេ នោះឈ្មោះថាមិនបាននូវសេចក្ដីសុខគ្រប់យ៉ាងឡើយ ៗ កាលបើលោកពិចារណាឃើញច្បាស់ដូច្នេះហើយ គឺអស់សេចក្ដីសង្ស័យក្នុងកំណើតដែលកើតក្នុងអតីត-កាល ៥, អស់សេចក្ដីសង្ស័យក្នុងកំណើតដែលកើតក្នុងអនាគតកាល ៥, អស់សេចក្ដីសង្ស័យក្នុងកំណើតដែលកើតក្នុងបច្ចុប្បន្នកាលនេះ ៦, សេចក្ដីសង្ស័យទាំង ១៦ នេះ ព្រះសោតាបន្នបុគ្គល លោកលះបង់ដាច់ស្រឡះចាកសន្តានពុំមានសេសសល់បន្តិចបន្តួចឡើយ ៗ ប្រៀបដូចទឹកសន្សើមដែលធ្លាប់នៅនឹងស្លឹកឈើក្នុងវេលាយប់, លុះព្រះអាទិត្យរះឡើងក៏រីងស្ងួតអស់ទៅ យ៉ាងណាមិញ ព្រះសោតាបន្នបុគ្គលទាំងឡាយ ក៏លះអស់សេចក្ដីសង្ស័យយ៉ាងនោះដែរ ៗ

សីលព្វតបរាមាសៈ ការប្រកាន់សីលវត្តរបស់ខ្លួនថាប្រសើរវិសេស, ឬហៅថា សីលព្វតុបាទាន គឺប្រកាន់យកមាំនូវសីលវត្ត គឺវត្តដែលធ្លាប់ជឿ, ធ្លាប់ប្រព្រឹត្តមកតាមទំនៀមទម្លាប់ ស្រុក - និគម - ជនបទក្លូប - ពំ នោះឯង ៗ ដូចមានសំដែងក្នុងសារណទីបិកាគាថា ថា :

ពហុំ វេ សរណំ យន្តិ បព្វតានិ វនានិ ច
អារាមរុក្ខចេត្យានិ មនុស្សា ភយតជ្ជិតា ៗ

ប្រែថា : មនុស្សទាំងឡាយមានចំនួនច្រើន កាលដែលមានភ័យ

គក់ស្លុតញាប់ញ័រគ្រប់សព្វគ្រាហើយ តែងធ្វើនូវសេចក្តីអន្តរាយប្អូនស្ងួនបង ស្រុកទាំងឡាយខ្លះ, ព្រៃទាំងឡាយខ្លះ, សាកសពនិងដើមឈើដែលជា ទេតិយទាំងឡាយខ្លះ ៗ មិនតែប៉ុណ្ណោះមនុស្សគ្រប់បក្សពួកខ្លះ តែងធ្វើនូវសេចក្តីអន្តរាយប្អូនស្ងួនបង់ស្រង់ចំពោះព្រះពុទ្ធខ្លះ, ព្រះធម៌ខ្លះ, ព្រះសង្ឃខ្លះ, សីលសមាធិបញ្ញាខ្លះ ជាព្រះពុទ្ធក្តី, ព្រះធម៌ក្តី, ព្រះសង្ឃក្តី, សីលសមាធិបញ្ញា ដែលខ្ញុំបានរក្សា, បានធ្វើ, បានចំរើន គោរពក្រាប់សាន មកហើយក្តី ទាំងអស់នេះ គួរតែមុះមុតខាងឯការបណ្តេញនូវសេចក្តីអន្តរាយ គ្រប់យ៉ាង គឺជួយការពារមិនឲ្យវិនាសផលដំរិក, មិនឲ្យឈឺ, មិនឲ្យស្លាប់, បើមានអន្តរាយ មានភ័យគក់ស្លុតញាប់ញ័រនឹងសេចក្តីស្លាប់ សេចក្តីវិនាសមកដល់ហើយ គឺគក់អន្ទះសារ បន់ស្រន់បួងសួងដល់ព្រះពុទ្ធ, ព្រះធម៌, ព្រះសង្ឃ, ដល់សីលសមាធិបញ្ញាទៅថា សូមឲ្យព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ និងសីលសមាធិបញ្ញាទាំងអស់នេះ ជួយការពារខ្ញុំផង អន្តរាយនោះ ៗ កុំឲ្យមកបៀតបៀនដល់ជីវិតរបស់ខ្ញុំឡើយ ព្រោះខ្ញុំជឿចំពោះ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ និងសីលសមាធិបញ្ញា តែប៉ុណ្ណោះ សូមលោកទាំងអស់នោះជួយខ្ញុំឲ្យបានរួចផុតពីសេចក្តីឈឺ, សេចក្តីស្លាប់, សេចក្តីទុក្ខ និងសេចក្តីវិនាសគ្រប់យ៉ាង ៗ ម្យ៉ាងទៀត កាលបើមានភ័យ ចិនះសេចក្តីឈឺមួយ ៗ ក៏ទៅសាកបាននិមន្តព្រះសង្ឃមកសូត្រធម៌បាចទឹក, ស្រោចទឹក, ស្តើងៃ, ធ្វើតាជាបន់ ដើម្បីឲ្យជាជម្ងឺ. ឲ្យជ្រះចៅថ្ងៃរបក្រោ

គ្រប់យ៉ាង ព្រោះប្រាថ្នាចង់ឲ្យតែជា · សេរី · សុខ · ចំរើន ។

បុគ្គលអ្នកប្រាថ្នាសុខ · ចំរើន · អាយុជីវិត ដោយធ្វើសេចក្តីបន់ស្រន់ បួងសួងអំពាវនាវហៅគេ ដូចបានពោលមកហើយខាងលើនេះ ឈ្មោះថា ចេះតែខុសរកផ្លូវសុខ · ចំរើន · អាយុជីវិត ។ ទីពឹងនោះឯង មិនមែនជា ទីពឹងដ៏ក្សេមទេ, ទីពឹងនោះឯងមិនមែនជាទីពឹងដ៏ឧត្តមទេ ; បុគ្គល មិនដែលដាច់ស្រឡះចាកទុក្ខទាំងពួង ព្រោះអាស្រ័យនូវទីពឹងនោះទេ ។

សេចក្តីដែលបានអធិប្បាយរៀបរាប់ដោយសង្ខេបប៉ុណ្ណោះ ហៅថា សីលព្វតបរាមាសៈ ។ ព្រោះហេតុនោះបុគ្គលណាគលះបង់សីលព្វតបរាមាសៈ នេះដាច់ស្រឡះចាកសង្ការរបស់លោកហើយ លោកមានសទ្ធាជ្រះថ្លាក្នុង ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ, លោកមានព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹង ទីរលឹកដ៏ឧត្តមលើសលែងប្រសើរលើសទៀត ហើយលោកឃើញនូវអរិយសច្ច ជាក់ច្បាស់ គឺឃើញច្បាស់នូវទុក្ខសច្ច បានដល់កងទុក្ខទាំង ១៦ កង ជាដើមគឺជាតិទុក្ខជាដើម, ឃើញច្បាស់នូវសមុទយសច្ច គឺតណ្ហាទាំង ៣ ប្រការមានកាមតណ្ហាជាដើម ជាហេតុនាំបង្កាលឲ្យកើតឡើងព្រមនៃ សេចក្តីទុក្ខ, ឃើញច្បាស់នូវនិរោធសច្ច គឺព្រះនិព្វានដែលជាទីរលត់បង់ នូវសេចក្តីទុក្ខ, ឃើញច្បាស់នូវមគ្គសច្ច បានដល់មគ្គមានអង្គ ៨ ដ៏ប្រ- សើរដែលញ៉ាំងសត្វឲ្យដល់នូវព្រះនិព្វាន ជាផ្លូវនាំចេញចាកសេចក្តីទុក្ខ ។ ហើយប្រាថ្នាប័ត្រពិត ។

ព្រះសោតាបន្នបុគ្គល លោកបានស្តាប់ព្រះធម៌ ក៏ឲ្យទានបង្គំព្រះមហាសមុទ្រដែលទ្រង់សំដែងពន្យល់ឲ្យឃើញច្បាស់នូវហេតុ និងបច្ច័យរបស់ធម៌ពិតនោះដូច្នេះថា ជរា និង មរណៈ កើតមានព្រោះជាតិជាបច្ច័យ ជាដែនកើត, ជាតិកើតមាន ព្រោះភព, ភពកើតមានព្រោះអវិជ្ជា តណ្ហា ឧបាទាន, អវិជ្ជា តណ្ហា ឧបាទាន ជាមូលហេតុ ជាបច្ច័យ ជាដែនកើតនៃជាតិ ជរា ព្យាធិ មរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ និងឧបាយាសៈ ។ កាលបើជាតិ និងកិលេសកើតឡើង នៃខន្ធមានរូបនាម ក៏ជាបច្ច័យ ជាដែនកើត នៃជរា ព្យាធិ និង មរណៈ គឺសេចក្តីចាស់, ឈឺ, ស្លាប់ ជាធម្មតា ដែលសត្វទាំងឡាយក្នុងលោកទាំងអស់ មិនអាចបំបិទគេចរៀសរួចទៅបានឡើយ ព្រោះហេតុអ្វី? ព្រោះថាសត្វទាំងឡាយ មិនុស្ស ទេវតា មារ ព្រហ្មទាំងអស់ត្រូវរួបស្ថិតនៅក្រោមលក្ខណៈ៣ គឺ អនិច្ចតា, ទុក្ខតា, អនត្តតា គឺសភាពជារបស់មិនទៀង, ទុក្ខ, មានការប្រែប្រួលជាធម្មតា មិនមានសត្វណាបុគ្គលណាមួយអាចនឹងហាមឃាត់ ឬអង្វរករបួងសួងបន់ស្រន់ ជាសូមកុំឲ្យចាស់, កុំឲ្យឈឺ, ស្លាប់ ដូច្នេះបានឡើយ ។ កាលបើលោកបានយល់ឃើញជាក់ច្បាស់ ដូចពោលមកនេះហើយ លោកក៏ញាណសទ្ធា ការជឿនោះឲ្យកាន់តែស៊ប់ស្ងួនក្នុងការគោរពប្រណិប័តន៍ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ, លោកបានគោរពប្រណិប័តន៍ព្រះធម៌ដែលពិត ឃើញ

ពិត ដោយបច្ចេកញ្ញាណនោះឡើយ ។ កាលបើលោកឃើញច្បាស់នូវធម៌ពិត ធម៌មែន ដូចបានពោលមកខាងលើនេះហើយ លោកក៏លែងលះបង់នូវសីលវត្ត គឺវត្តដែលធ្លាប់ប្រព្រឹត្ត ធ្លាប់ជឿមកថា ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជួយឲ្យជា, ជួយឲ្យរស់ នោះអស់ហើយ, លោកលែងគោរពល្បង, លែងផ្ទឹមកាន់ប្រឡូរហើយ ។ លោកលែងទារយកក្តួនតិពាស់, លែងទារយកជាតិឈើ, លែងទារយកស់ពីស្លាប់, លែងទារយកខ្មៀង, លែងទារយកបុះ, លែងទារយកខ្លឹមសារ ពីក្នុងរបស់ដែលមិនខ្មៀង, ដែលជាទុក្ខ, ដែលឥតខ្លឹមសារនោះហើយ ។ ដូច្នេះ ឈ្មោះជាជផុតស្រឡះចាកសីលព្វតបរាមាសៈ ជាសំយោជនកិលេសទី៣ ។ បុគ្គលដែលលះបង់បាននូវសំយោជនកិលេស ៣ គឺ សក្កាយទិដ្ឋិ វិចិកិច្ឆា និងសីលព្វតបរាមាសៈ ដូចបានអធិប្បាយរៀបរាប់មកខាងលើនេះ រៀកថាសោតាបន្នបុគ្គល ។

សោតាបន្នបុគ្គលនោះចែកចេញជា ៣ ពួក គឺ :

១)- ឯកពីជី លោកដែលមានពូជ គឺកំណើតមួយគត់ទៀតក្នុងឋលោកមួយជាតិទៀត;

២). គោលំគោលៈ លោកដែលទៅពីត្រកូលមួយទៅកាន់ត្រកូលមួយទៀត គឺទៅកើត ២ ជាតិ ១ ៣ ជាតិ ទើបធ្វើឲ្យជាក់ច្បាស់នូវអរហត្តផលបាន;

៣)· សត្តក្ខត្តុំបរមៈ លោកដែលត្រាច់ត្រាក់ទៅកើតក្នុងមនុស្សលោក និងទេវលោកយ៉ាងច្រើនបំផុតត្រឹម ៧ ជាតិទៀត ទើបបានធ្វើឲ្យជាក់ច្បាស់នូវអរហត្តផលបាន ។

សោតាបន្នបុគ្គលទាំងនេះ តែងពិចារណានូវបច្ចវេក្ខណកិច្ច ៥ យ៉ាងគឺ:

១)· មគ្គំ បច្ចវេក្ខណ ពិចារណានូវមគ្គដោយន័យថា: អាត្មាអញមកតាមផ្លូវណា ;

២)· ផលំ បច្ចវេក្ខណ ពិចារណានូវផលជាអានិសង្សដែលខ្លួនត្រូវបាន;

៣)· បហីនកិលេសេ បច្ចវេក្ខណ ពិចារណានូវកិលេសដែលខ្លួនលះហើយ ថាកិលេសទាំងឡាយនេះ អញលះបានហើយ ;

៤)· អវសិដ្ឋកិលេសេ បច្ចវេក្ខណ ពិចារណានូវកិលេសដែលសេសសល់ ថាកិលេសទាំងអស់ដែលសល់នៅនេះ ត្រូវលះដោយមគ្គខាងលើ;

៥)· និព្វានំ បច្ចវេក្ខណ ពិចារណានូវព្រះនិព្វាន ថាធម៌នេះហើយដែលជាអារម្មណ៍ឲ្យត្រាស់ដឹង ។

សកទាគាមី, អនាគាមី, អរហន្ត ទាំង ៣ ពួកនេះ ពុំបានលើកយកមកអធិប្បាយក្នុងទីនេះទេ ព្រោះបានអធិប្បាយខាងដើមខ្លះហើយ ឬមានក្នុងសៀវភៅនៅត្រៃយមគ្គាអធិប្បាយដោយសង្ខេបហើយ ។

ចិត្តដែលព្រះយោគាវចរចំរុងយាមបង្កើនឲ្យច្រើនឡើង ៗ នោះមាន អំណាចកាចបមីនកំចាត់បង់នូវស្រៀវ គឺ នីវរណបក្កិលេស ឬសំយោជន. កិលេសណាមួយហើយបានឡើងដល់ជាន់ចតុត្ថជ្ឈាន ឬបានសំរេចដល់ ជាន់មគ្គផល មានសោតាបត្តិមគ្គនិងសោតាបត្តិផលជាដើម នោះឈ្មោះជា ចិត្តមានអារម្មណ៍មូលតែមួយ ជាចិត្តស្អាតបរិសុទ្ធ ព្រោះដោយអំណាចឈាន ឬដោយអំណាច មគ្គ ផល នោះឯង, ចិត្តយ៉ាងនេះហើយដែលឈ្មោះថា សម្មាសមាធិ ចាត់ជាអង្គមគ្គទី ៨ ។

លក្ខណៈ- កិច្ច និងផលរបស់សម្មាសមាធិ

លក្ខណៈ= អវិក្ខេបលក្ខណោ សម្មាសមាធិមានកិរិយាមិន អណ្ដែតអណ្ដូងនៃចិត្តជាលក្ខណៈ;

កិច្ច= សមាធានរសោ សម្មាសមាធិមានកិរិយាតម្រង់ទុក ដោយប្រពៃជាកិច្ច;

ផល= មិច្ឆាសមាធិប្បហានបច្ចុប្បដ្ឋានោ សម្មាស- មាធិមានកិរិយាលះបង់នូវសមាធិខុសជាផល ។

សម្មាសមាធិនេះ ចាត់ជាមនោកម្ម ព្រោះជាអំពើត្រូវធ្វើដោយផ្លូវ ចិត្ត ចាត់ជាសមាធិក្ខន្ធ ។

អដ្ឋង្គិកមគ្គទាំង៨ប្រការដូចបានអធិប្បាយមកនេះ មានសម្មាទិដ្ឋិជាប្រ. ធាន ទុកដូចជាមគ្គុទ្ទេសក៍អ្នកនាំផ្លូវ គឺដឹកនាំតម្រង់អង្គមគ្គទាំង ៧ ខាងចុង

ឲ្យធ្វើដំណើរទៅបានស្រួល កុំឲ្យភ្លាត់ធ្លាក់ទៅក្នុងមិច្ឆាភាព ព្រោះថា បើបុគ្គលណា បានស្ថិតនៅក្នុងសម្មាទិដ្ឋិហើយ អង្គមគ្គទាំង៧ខាងចុងនេះក៏កើតឡើងៗ គ្នាជាលំដាប់ ដល់បុគ្គលនោះ ជាបន្តបន្ទាប់ដល់ចប់ចុង គឺទៅដល់គ្នានឹងព្រះនិព្វាន ដូចមានព្រះពុទ្ធដីកាដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែងក្នុងគម្ពីរទីឃនិកាយ មហាវគ្គ ត្រង់ជនវសភសូត្រ ថា :

សម្មាទិដ្ឋិស្ស ភោ សម្មាសង្កប្បោ បហោតិ ម្នាលភិក្ខុទាំងឡាយ សម្មាសង្កប្បៈ រមែងកើតមានដល់បុគ្គល ដែលស្ថិតនៅក្នុងសម្មាទិដ្ឋិ ។

សម្មាសង្កប្បស្ស សម្មាវាចា បហោតិ សម្មាវាចា រមែងកើតមានដល់បុគ្គលដែលស្ថិតនៅក្នុងសម្មាសង្កប្បៈ ។

សម្មាវាចស្ស សម្មាកម្មន្តោ បហោតិ សម្មាកម្មន្តៈ រមែងកើតមានដល់បុគ្គលដែលស្ថិតនៅក្នុងសម្មាវាចា ។

សម្មាកម្មន្តស្ស សម្មាអាជីវោ បហោតិ សម្មាអាជីវៈ រមែងកើតមានដល់បុគ្គលដែលស្ថិតនៅក្នុងសម្មាកម្មន្តៈ ។

សម្មាអាជីវស្ស សម្មាវាយាមោ បហោតិ សម្មាវាយាមៈ រមែងកើតមានដល់បុគ្គលដែលស្ថិតនៅក្នុងសម្មាអាជីវៈ ។

សម្មាវាយាមស្ស សម្មាសតិ បហោតិ សម្មាសតិ រមែងកើតមានដល់បុគ្គលដែលស្ថិតនៅក្នុងសម្មាវាយាមៈ ។

សម្មាសតិស្ស សម្មាសមាធិ បហោតិ សម្មាសមាធិ រមែងកើតមានដល់បុគ្គលដែលស្ថិតនៅក្នុងសម្មាសតិ ។

សម្មាសមាធិស្ស សម្មាញាណំ បហោតិ សម្មាញាណ (សេចក្តីដឹងដោយប្រពៃ បានដល់មគ្គញាណនិងផលញាណ) រមែងកើតមានដល់បុគ្គលដែលស្ថិតនៅក្នុងសម្មាសមាធិ ។

សម្មាញាណស្ស សម្មាវិមុត្តិ បហោតិ សម្មាវិមុត្តិ (ការរួចស្រឡះចាកអាសវៈ) បានដល់មគ្គវិមុត្តិ និងផលវិមុត្តិរមែងកើតឡើងដល់បុគ្គលដែលស្ថិតនៅក្នុងសម្មាញាណ ។

ធម្មយាតាធិប្បាយោ សង្ខេបេន និដ្ឋិតោ ឯវំ ។

ការផ្សាយសៀវភៅ នេះជា eBook បាន បង្កើតឡើងដោយ

មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេន ជា eBook ដោយ **ម៉ាន ផាន្នី**

តុលា ឆ្នាំ ២០១៥

គាំទ្រដោយ កូនប្រុស ស្រី

លោក ស៊ី ដារា និងលោកស្រី សុន ដាវី ព្រមទាំងលោកស្រី បុប្ផា ដឺឡូប៉ែស

ដើម្បី ឧទិសកុសល ដល់វិញ្ញាណក្ខន្ធ

លោកឪពុក សង្វារ ដឺ ឡូប៉ិស និងលោកម្តាយ ឌិន សៅឌុន

សូមអរគុណ

ខ្ទៅ យុនសំរ៉ង

ប្រធាន

មូលនិធិខ្មែរសម្រាប់ការសិក្សា

www.elibraryofcambodia.org

## មានលក់ដុំ និង លក់រាយ

សៀវភៅចម្រុះគ្រប់មុខគ្រប់ប្រភេទ នៅ " បណ្ណាគារម៉ែត្រូតន់ "

# 136$E_0$ វិថីខេមរភូមិន្ទ

ទូរស័ព្ទលេខ **012 706 581**

**097 905 00 55**

សូមនិមន្ត និង អញ្ជើញដោយមេត្រីភាព ។